សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences E´conomiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌតុលាការកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយនិស្សិត

ឈ្មោះ៖ **លោក. ថាន់ ចាន់ថាន:**

**កញ្ញា. បាន សំរិត**

សាស្ត្រាចារ្យណែនាំ

លោកសាស្ត្រាចារ្យ. **ហ៊ាង ឡេង**


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាប័ត្រ | **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា | ២០១៦ |
| ជំនាន់ទី | ២០ | ឆ្នាំសរសេរសារណា | ២០២០ |

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ថាន់ ចាន់ថាន:** និងកញ្ញា **ចាន សំរិត** ក្នុងនាមយើងខ្ញុំទាំងពីរជានិស្សិតផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចថ្នាក់បរិញ្ញាបត្រជំនាន់ទី ២០ក្នុងឆ្នាំសិក្សា ២០១៦-២០២០។

**យើងខ្ញុំសូមលំអោនកាយវាចារចិត្តគោរពប្រតិបត្តិសម្តែងនូវកតញ្ញូកតវេទីតាធ៌មដឹងគុណយ៉ាងជ្រាលជ្រៅទីបំផុតជូនចំពោះអ្នកមានគុណរួមមាន:**

**លោកឪពុក នេត វណ្ណថាន់** **លោកឪពុក ស៊ូ ធឿន**

**អ្នកម្តាយ ទេព សាឡុន** **អ្នកម្តាយ យ៉ាង សាម៉េត**

**និង បងប្រុសបង្កើតឧត្តមសេនីយ៍ទោបានប្រាក់ នឹងភរិយាមាសម៉ានិត្យ**

ដែលលោកបានផ្តល់កំណើត ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សារូបកូនតាំងពីតូចបាតជើងក្រហមននៀលរហូតដល់កូនចំរើនវ័យលូតលាស់ពេញរូបរាងដូចសព្វថ្ងៃនេះ។ មិនតែប៉ុណ្ណោះលោកទាំងពីរបានអប់រំបង្រៀនប្រៀនប្រដៅកូនដោយផ្តល់ដំបូន្មានល្អៗក្នុងជីវិតមកដល់ពេលនេះ រហូតដល់កូនទទួលបានជោគជ័យជាមួយ នឹងលទ្ធផលជាទីគាប់ប្រសើរនាថ្នាក់ឧត្តមសិក្សា នឹងបានផ្តល់អោយកូនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាធនធានមនុស្សដែលសង្គមជាតិបច្ចុប្បន្នត្រូវការដើម្បីបំរើដល់ប្រយោជន៍ជាតិមាតុភូមិ។ សូមលោកទាំងពីរមេត្តាទទួលនូវការគោរព នឹងការដឹងគុណពីកូនប្រុស និងស្រីរបស់លោកទាំងពីរ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីដែលជាព្រឹទ្ធបុរស លោកគ្រូ អ្នកគ្រូដែលជាសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ នឹងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលលោកបានខិតខំបង្រៀន នឹងផ្តល់នូវចំណេះដឹងក្នុងការជួយតម្រង់ទិសដៅរូបយើងខ្ញុំទាំងពីរតាំងពីរការសិក្សាថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាប័ត្រនេះ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។**

ជាពិសេសជូនចំពោះលោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលលោកគ្រូបានបង្ហាត់បង្ហាញនូវគំនិតជាច្រើនក្នុងការស្វះស្វែង ស្រាវជ្រាវប្រធានបទមួយនេះ ដោយលោកគ្រូបានខិតខំចំណាយពេលវេលាដ៏មានតម្លៃរបស់លោកគ្រូក្នុងការជ្រោមជ្រែងការស្រាវជ្រាវមួយនេះអោយមានភាពរលូតទៅមុខរហូតពីដើមដល់ចប់ក្នុងកិច្ចការសិក្សាស្រាវជ្រាវសារណាមួយនេះ អោយលេចចេញជារូបភាពឡើងមកនេះ ក៏អាស្រ័យដោយលោកគ្រូជាអ្នកណែនាំ។ ហើយក៏សូមអរគុណដល់លោក លោកស្រីដែលជាបណ្ណារក្ស និស្សិតរៀមច្បង នឹងមិត្តនិស្សិតទាំងអស់គ្នាដែលបានគាំទ្រនូវកម្លាំងចិត្ត ព្រមទាំងផ្តល់ជាគំនិតយោបល់ល្អៗជំរុញអោយការស្រាវជ្រាវមានលក្ខណៈ

កាន់តែប្រសើរ  ដើម្បីទុកជាឯកសារក្នុងការស្រាវជ្រាវ  នឹងព្រមទាំងការស្វែងយល់ជាមួយចំណេះដឹងដល់និស្សិត ជំនាន់ក្រោយទៀត។  ជាចុងក្រោយយើងខ្ញុំសូមគោរព ជូនពរចំពោះលោកអ្នកមានគុណ និងលោកសាស្ត្រាចារ្យ ដូចដែលបានរៀបរាប់ខាងលើ អោយជួបប្រទះនូវពុទ្ធពរ ទាំងបួនប្រការគឺ អាយុ  វណ្ណៈ  សុខៈ  ពលៈ   នឹងសេចក្តីសុខសប្បាយចូលមានដល់លោកអ្នកមានគុណ និងលោកសាស្ត្រាចារ្យទាំងអស់កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តជំនាន់ទី២០ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៦-២០២០។ ក្នុងឱកាសមានតម្លៃមួយនេះ ដែលសាកលវិទ្យាល័យផ្តល់អោយយើងខ្ញុំទាំងពីរបានសម្រេចចិត្តជ្រើសរើស នឹងរៀបចំស្រាវជ្រាវតាក់តែងនូវសារណាមួយក្រោមប្រធានបទស្តីអំពី "**ដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌតុលាការកម្ពុជា**" ដែលបានកើតចេញពីការខិតខំសិក្សាស្រាវជ្រាវនាពេលកន្លងមកនេះ។

ការស្រាវជ្រាវនូវប្រធានបទនេះ គោលបំណងដើម្បីស្វែងយល់ដឹងអោយស៊ីជម្រៅនូវដំណើរការនៃនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌរបស់តុលាការកម្ពុជា ពីដើមចមដំបូងនៃបទល្មើសរហូតដល់ការចេញសេចក្តីសម្រេចនូវសាលក្រមរបស់សាលាជម្រះក្តីជាន់ទាប ឬសាលដីការបស់សាលាជម្រះក្តីជាន់ខ្ពស់របស់តុលាការកម្ពុជា។

ការស្រាវជ្រាវនេះគឺជាលក្ខខណ្ឌយ៉ាងសំខាន់មួយ ក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដែលទាមទារអោយនិស្សិតគោរពអោយបានភ្ជាប់ភ្ជួនខ្លួននូវលក្ខខណ្ឌទាំងនេះ ដើម្បីបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ។ មួយវិញទៀតដើម្បីឆ្លើយតបទៅនឹងទឹកចិត្តដ៏មានតម្លៃក្នុងការណែនាំចង្អុលបង្ហាញនឹងចែករំលែកនូវចំណេះដឹងព្រមទាំងគំនិតយោបល់របស់យើងខ្ញុំទាំងពីរដើម្បីបញ្ចប់ការស្រាវជ្រាវបានដោយជោគជ័យ។

ទន្ទឹមនឹងនេះ ប្រធានបទស្តីពី"**ដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌតុលាការកម្ពុជា**" គឺជាគំនិតដ៏ស្ដួចស្ដើងមួយ ដែលបានលេចរូបរាងឡើងដោយសារការខិតខំស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់ដែលគ្រាន់បន្សល់ទុកជាដើមទន់បន្តិចមួយដល់មិត្តនិស្សិត អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយទុកជាគំរូឯកសារក្នុងការសិក្សា ស្រាវជ្រាវ ស្វែងយល់បន្តទៀត។ យើងខ្ញុំទាំងពីរក៏ជឿជាក់ថាសារណាមួយនេះ ក៏នៅមានចន្លោះប្រហោងដែលមិនទាន់គ្រប់ជ្រុងជ្រោយ នឹងល្អឥតខ្ចោះនៅឡើយទេក៏ដោយសារចំនុចខ្លះមានលក្ខណៈស្មុគស្មាញច្រើន នឹងទាក់ទងបទពិសោធន៏របស់យើងខ្ញុំទាំងពីរនៅមានកម្រិត តែទោះជាយ៉ាងណាក្តីក៏យើងខ្ញុំសង្ឃឹមថា និស្សិតនិងមិត្តអ្នកអានទាំងអស់ពិតជាមានការអធ្យាស្រ័យនូវរាល់កំហុសឆ្គងទាំងឡាយណា ដែលកើតមានឡើងដោយអចេតនាក្តី។ យើងខ្ញុំនៅរង់ចាំរាល់ការរិះគន់ទាំងអស់ក្នុងន័យជាការស្ថាបនាពីសំណាក់សាស្រ្តាចារ្យនិស្សិតនឹងអ្នកសិក្សាស្រាវជ្រាវទាំងអស់ដោយក្តីរីករាយបំផុត។ ហើយចំពោះសារណាមួយនេះ យើងខ្ញុំទាំងពីរបានចាប់ផ្តើមស្រាវជ្រាវពីថ្ងៃទី០១ ខែមិនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២០។ ក្នុងរយៈពេលនេះ យើងខ្ញុំបានប្រើប្រាស់ពេលវេលាច្រើនក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធ នឹងប្រធានបទនឹងការពិគ្រោះ

យោបល់ ជាមួយលោកគ្រូសាស្ត្រាចារ្យដើម្បីធ្វើការរៀបចំតាក់តែងសារណាមួយនេះដែលអាចយកជាការបានទៅតាមពេលវេលាដែលបានកំណត់នឹងទៅតាមទំហំនៃប្រធានបទរបស់យើងខ្ញុំទាំងពីរ។

ចុងបញ្ចប់ក្នុងនាមយើងខ្ញុំទាំងពីរ ជាអ្នករៀបរៀងនូវសារណាមួយនេះឡើងមកក្នុងគោលបំណងដែលសង្ឃឹមថាស្នាដៃមួយនេះ នឹងក្លាយជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ នឹងជាជំនួយដល់ការពង្រីកចំណេះដឹងបន្ថែមដល់និស្សិតដែលកំពុងសិក្សាទៅតាមតម្រូវការរៀងៗខ្លួន។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌ**

**ផ្នែកទី១៖ បទល្មើសព្រហ្មទណ្ឌ** ........ ៧

**១.១ ធាតុនីត្យានុកូល ឬធាតុច្បាប់** ........ ៧

**១.២ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ** ........ ៨

**១.២.១ បទល្មើសបានសម្រេច** ........ ៩

**១.២.២ បទល្មើសមិនបានសម្រេច** ........ ៩

**១.៣ ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ** ........ ៩

**១.៣.១ បទល្មើសដោយចេតនា** ........ ១០

**១.៣.២បទល្មើសដោយអចេតនា** ........ ១០

**ផ្នែកទី២៖ ការទទួលខុសត្រូវ និងមិនទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ១១

**២.១ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ១១

**២.១.១ រូបវ័ន្តបុគ្គល** ........ ១២

២.១.១.១ ចារី ........ ១២

២.១.១.២ សហចារី ........ ១២

២.១.១.៣ អ្នកផ្តើមគំនិត ........ ១២

២.១.១.៤ អ្នកសមគំនិត ........ ១៣

**២.១.២ បុគ្គលនីតិបុគ្គល** ........ ១៤

**២.២ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ១៤

**២.២.១ វិបល្លាសស្មារតី** ........ ១៥

**២.២.២ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ** ........ ១៥

**២.២.៣ ការការពារស្របច្បាប់** ........ ១៦

២.២.៤ សច្ចាធារណ៍ នៃការការពារស្របច្បាប់ ....................................................... ១៦

២.២.៥ ស្ថានភាពចាំបាច់ ....................................................... ១៧

២.២.៦ អានុភាពនៃកម្លាំង ឬការបង្ខំ ....................................................... ១៧

ផ្នែកទី៣៖ ទោសព្រហ្មទណ្ឌ ....................................................... ១៨

៣.១ មូលទោស ....................................................... ១៨

៣.២ អនុទោស(ទោសបន្ថែម) ....................................................... ១៨

៣.៣ ទោសជំនួស ....................................................... ១៩

## ជំពូកទី២

## ដំណើរការរឿងក្ដីព្រហ្មទណ្ឌ

ផ្នែកទី១៖ ភាគីក្នុងរឿងក្ដីព្រហ្មទណ្ឌ ....................................................... ២១

១.១ ជនល្មើស ....................................................... ២១

១.២ ជនរងគ្រោះ ....................................................... ២១

១.៣ ដើមបណ្ដឹងរដ្ឋប្បវេណី ....................................................... ២២

១.៤ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ....................................................... ២២

១.៥ តតិយជនផ្សេងទៀត ....................................................... ២២

ផ្នែកទី២៖ នគរបាលយុត្តិធម៌ ....................................................... ២៣

២.១ សមាសភាពនគរបាលយុត្តិធម៌ ....................................................... ២៣

២.១.១ មន្ត្រីនគរបាលយុត្តិធម៌ ....................................................... ២៤

២.១.២ ភ្នាក់ងារនគរបាលយុត្តិធម៌ ....................................................... ២៤

២.១.៣ មន្ត្រីរាជការ នឹងភ្នាក់ងារសាធារណៈដទៃទៀត ....................................................... ២៥

២.២ សមត្ថកិច្ចនគរបាលយុត្តិធម៌ ....................................................... ២៥

២.២.១ សមត្ថកិច្ចដែនដី ....................................................... ២៥

២.២.២ សមត្ថកិច្ចសម្ភារៈ ....................................................... ២៦

២.៣ បេសកម្មរបស់នគរបាលយុត្តិធម៌ ....................................................... ២៦

២.៣.១ ការស៊ើបអង្កេតករណីជាក់ស្ដែង ....................................................... ២៦

២.៣.១.១ ការចុះទៅកាន់ទីកន្លែងកើតហេតុ ........................................................ ២៧
២.៣.១.២ ការឃាត់ខ្លួន ........................................................ ២៧
២.៣.១.៣ ការឆែកឆេរ ........................................................ ២៨
២.៣.១.៤ ការចាប់យកវត្ថុតាង ........................................................ ២៨
២.៣.១.៥ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេសវិទ្យាសាស្ត្រ ........................................................ ២៩
២.៣.១.៦ ការបញ្ជូនកំណត់ហេតុ វត្ថុតាង នឹងបុគ្គលដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ............. ២៩
២.៣.១.៧ ការស្តាប់ចម្លើយ នឹងការសន្ទនា ........................................................ ២៩
**២.៣.២ ការស៊ើបអង្កេតករណីបឋម** ........................................................ ៣០
២.៣.២.១ កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ ........................................................ ៣០
២.៣.២.២ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ........................................................ ៣១
២.៣.២.៣ ការហាមឃាត់មិនអោយស្តាប់សារសំលេងឯកឯងជាអាទិ៍ ........................................................ ៣១
២.៣.២.៤ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា ........................................................ ៣១
២.៣.២.៥ និទ្ទេសដែលចុះនៅក្នុងកំណត់ហេតុ ........................................................ ៣១
២.៣.២.៦ ការឆែកឆេរ ........................................................ ៣២
២.៣.២.៧ ការបញ្ជាឲ្យចូលខ្លួន ........................................................ ៣២
២.៣.២.៨ កំណត់ហេតុស្រង់ចម្លើយ ........................................................ ៣៣
២.៣.២.៩ ការឃាត់ខ្លួនជនសង្ស័យ ........................................................ ៣៣
២.៣.២.១០ ការអនុវត្តដីកាចាត់ឲ្យសើបសួរជំនួស ........................................................ ៣៣
២.៣.២.១១ ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននិងដីកាបង្គាប់ឲ្យចាប់ខ្លួន ........................................................ ៣៤
**ផ្នែកទី៣៖ អង្គការអយ្យការ(ព្រះរាជអាជ្ញា)** ........................................................ ៣៥
**៣.១ សមាសភាពនៃចៅក្រមអយ្យការ** ........................................................ ៣៥
**៣.១.១ មុខងាររបស់ចៅក្រមអយ្យការអមតុលាការកំពូល** ........................................................ ៣៦
**៣.១.២ មុខងាររបស់ចៅក្រមអយ្យការអមសាលាឧទ្ធរណ៍** ........................................................ ៣៦
**៣.១.៣ មុខងាររបស់ចៅក្រមអយ្យការអមសាលាដំបូង** ........................................................ ៣៧
**៣.២ សមត្ថកិច្ចរបស់អយ្យការ** ........................................................ ៣៧

**៣.២.១ សមត្ថកិច្ចដែនដីរបស់អយ្យការ** ............................................................................ ៣៧
**៣.២.២ សមត្ថកិច្ចក្នុងការធ្វើចំណាត់ការលើសំណុំរឿង** ............................................................ ៣៨
៣.២.២.១ ការធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ................................................ ៣៨
៣.២.២.២ ការធ្វើសេចក្តីសម្រេចរការចោទប្រកាន់ ................................................................ ៤១
**ផ្នែកទី៤៖ យុត្តាធិការស៊ើបសួរ(ចៅក្រមស៊ើបសួរ)** ............................................................................ ៤៥
**៤.១ សមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួរ** ............................................................................ ៤៦
**៤.១.១ សមត្ថកិច្ចក្នុងការបើកការស៊ើបសួរ** ............................................................................ ៤៦
៤.១.១.១ ការបើកការស៊ើបសួរដោយតំណាងអយ្យការ ............................................................ ៤៦
៤.១.១.២ ការបើកការស៊ើបសួរដោយភាគីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី .................... ៤៧
**៤.១.២ សមត្ថកិច្ចក្នុងការបិទកិច្ចនៃការស៊ើបសួរ** ............................................................ ៤៨
៤.១.២.១ ការបិទការស៊ើបសួរតាមរយៈដីកាសន្និដ្ឋាន ............................................................ ៤៩
៤.១.២.២ ការបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ .................................................... ៥០
**៤.២ វិធានការនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ............................................................ ៥១
**៤.២.១ ការជូនដំណឹងពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ** ............................................ ៥១
**៤.២.២ ការសួរចម្លើយជនត្រូវចោទ** ............................................................................ ៥២
**៤.២.៣ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី** ............................................................ ៥៣
**៤.២.៤ ការស្តាប់ចម្លើយសាក្សី** ............................................................................ ៥៤
**៤.២.៥ ការឆែកឆេរ និងការចាប់យកវត្ថុតាង** ............................................................ ៥៤
**៤.២.៦ ការធ្វើកោសលវិច័យ** ............................................................................ ៥៥
**៤.២.៧ ការស្តាប់ទូរស័ព្ទ** ............................................................................ ៥៦
**៤.២.៨ ការចាត់ឲ្យស៊ើបសួរជំនួស** ............................................................................ ៥៦
**៤.៣ វិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ** ............................................................ ៥៧
**៤.៣.១ ដីកាបង្គាប់ឲ្យចូលខ្លួន** ............................................................................ ៥៧
**៤.៣.២ ដីកាបង្គាប់ឲ្យនាំខ្លួន** ............................................................................ ៥៨
**៤.៣.៣ ដីកាបង្គាប់ឲ្យចាប់ខ្លួន** ............................................................................ ៥៨

**៤.៣.៤ ដីកាបង្គាប់ឲ្យឃុំខ្លួន** ........ ៥៩
៤.៣.៤.១ មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ........ ៥៩
៤.៣.៤.២ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ........ ៥៩
**៤.៣.៥ ការសម្រេចមិនឃុំខ្លួន** ........ ៦១
**៤.៣.៦ ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ** ........ ៦១
៤.៣.៦.១ តាមរយៈការសម្រេចចៅក្រមស៊ើបសួរ ........ ៦១
៤.៣.៦.២ តាមរយៈពាក្យបណ្ដឹងព្រះរាជអាជ្ញា ........ ៦២
៤.៣.៦.៣ តាមរយៈបណ្ដឹងជនត្រូវចោទ ........ ៦២
៤.៣.៦.៤ ការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៦២
**៤.៣.៧ មោឃៈភាពនៃការស៊ើបសួរ** ........ ៦៣

## ជំពូកទី៣

## ការជំនុំជម្រះ

**ផ្នែកទី១៖ នីតិវិធីមុនពេលជំនុំជម្រះ(មុនសវនាការ)** ........ ៦៤
**១.១ ការទទួលពាក្យបណ្ដឹង** ........ ៦៤
**១.១.១ តាមរយៈដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ** ........ ៦៤
**១.១.២ តាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា** ........ ៦៥
**១.១.៣ តាមរយៈការកំណត់ហេតុចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា** ........ ៦៥
**ផ្នែកទី២៖ នីតិវិធីពេលជំនុំជម្រះ (សវនាការ)** ........ ៦៦
**២.១ ដំណើរការពិភាក្សាដេញដោលក្នុងសវនាការជំនុំជម្រះ** ........ ៦៦
**២.២ សក្ខីកម្ម នឹងភស្តុតាង** ........ ៦៧
**២.៣ សេចក្ដីសន្និដ្ឋានចុងក្រោយ** ........ ៦៧
**២.៤ ការពិភាក្សាសម្រេច នឹងសាលក្រម** ........ ៦៨
**ផ្នែកទី៣៖ នីតិវិធីក្រោយពេលជំនុំជម្រះ(ក្រោយសវនាការ)** ........ ៦៨
**៣.១ ការធ្វើបណ្ដឹងបើកផ្លូវតវ៉ា(បណ្ដឹងទាស់)** ........ ៦៩
**៣.១.១ ពិរុទ្ធជន** ........ ៦៩

**៣.១.២ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី** ........ ៧០
**៣.២ ការធ្វើបណ្តឹងឧទ្ធរណ៍** ........ ៧២
**៣.២.១ លក្ខខណ្ឌទម្រង់នៃការធ្វើបណ្តឹងឧទ្ធរណ៍** ........ ៧៣
**៣.២.២ នីតិវិធីចំពោះមុខសាលាឧទ្ធរណ៍** ........ ៧៣
៣.២.២.១ ការកំណត់កាលបរិច្ឆេទសវនាការ ........ ៧៤
៣.២.២.២ ការធ្វើរបាយការណ៍ ........ ៧៤
៣.២.២.៣ ដំណាក់កាលសវនាការ ........ ៧៤
៣.២.២.៤ ការប្រកាសសាលដីកា ........ ៧៥
**៣.៣ ការធ្វើបណ្តឹងសាទុក្ខ** ........ ៧៨
**៣.៣.១ ទម្រង់នៃបណ្តឹងសាទុក្ខ** ........ ៧៨
**៣.៣.២ មូលហេតុនៃបណ្តឹងសាទុក្ខ** ........ ៧៩
**៣.៣.៣ នីតិវិធីនៅចំពោះមុខតុលាការកំពូល** ........ ៧៩
៣.៣.៣.១ នីតិវិធីមុនពេលសវនាការ ........ ៧៩
៣.៣.៣.២ នីតិវិធីនាពេលសវនាការ ........ ៨០
៣.៣.៣.៣ ការប្រកាសសាលដីកា ........ ៨០
៣.៣.៣.៤ ការជំនុំជម្រះពេញអង្គ ........ ៨១
**៣.៤ ការធ្វើបណ្តឹងសើរើ** ........ ៨១
**៣.៤.១. ទម្រង់នៃបណ្តឹងសើរើ** ........ ៨១
**៣.៤.២. មូលហេតុនៃការធ្វើបណ្តឹងសើរើ** ........ ៨២
**៣.៤.៣. នីតិវិធីបណ្តឹងសើរើ** ........ ៨២
**សេចក្តីសន្និដ្ឋាន** ........ ៨៤
**អនុសាសន៍** ........ ៨៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ប្រវត្តិសាស្ត្រការកកើតនៃមនុស្សជាតិ គឺបានកើតឡើងរាប់សិបលានឆ្នាំមកហើយដែលសិក្សាឃើញថា មនុស្សកើតចេញពីសត្វម្យ៉ាងដែលខុសពីសត្វធម្មតា ត្រង់មនុស្សមានមនោសញ្ចេតនាវិចារណៈញ្ញាណចេះត្រិះរិះ ពិចារណាដឹងខុសដឹងត្រូវខុសពីសត្វធម្មតា ដែលរស់នៅដោយសភាវៈគតិដែលជាទម្លាប់របស់ខ្លួនទៅតាម ធម្មជាតិ។ យើងសាកក្រលេកទៅមើលអតីតកាលនៃការរស់នៅរបស់មនុស្សវិញដំបូងឡើយ គឺពួកគេរស់នៅ ដាច់ដោយឡែកៗទីទៃពីគ្នានិងស្វែងរកអាហារ ចំណី ត្រី សត្វ បរិភោគតាមធម្មតាដោយគ្មានកើតខ្វល់ពីបញ្ហាអ្វី ទាំងអស់ ប៉ុន្តែក្រោយមកការរស់នៅរបស់ពួកគេមានការជួបឧបសគ្គជាច្រើនដែលរំខានដល់ជីវិតរស់នៅរបស់ខ្លួន ដោយសារបញ្ហាកត្តាធម្មជាតិដូចជា ទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត រន្ទះបាញ់ជាដើមដែលជាមូលហេតុធ្វើ អោយរំខានក្តីសុខសុភមង្គលក្នុងការរស់នៅរបស់ពួកគេ។ ពេលនោះមនុស្សចាប់ផ្តើមរស់នៅដោយប្រមូលផ្តុំគ្នាជា កុលសម្ព័ន្ធ សំរាប់ពិភាក្សាដោះស្រាយរួមជាមួយគ្នា អំពីបញ្ហាប្រឈមក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ ហើយ ដោយផ្តល់សិទ្ធដល់មនុស្សម្នាក់ៗជាគ្រប់គ្រងកុលសម្ព័ន្ធនោះហៅថា ម្ចាស់កុលសម្ព័ន្ធ(មេកន្ទាញ)ដែលម្ចាស់ កុលសម្ព័ន្ធនេះ ហើយជាអ្នកដែលមានសិទ្ធិអំណាចសម្រេចរាល់កិច្ចក្នុងកុលសម្ព័ន្ធទាំងមូល។ ក្រោយមកបន្តិច ជីវិតរបស់ពួកគេក៏បានសុខបន្តិចហើយ ដោយមិនយូរប៉ុន្មានពួកគេក៏ជួបប្រទះនៅបញ្ហាក្នុងរស់នៅកុលសម្ព័ន្ធវិញ ដោយមាននូវការបំពានគ្នាទៅវិញទៅមកដូចជា ការលួច ការដណ្តើម ចំណីអាហារគ្នា ការខឹងច្រណែន ស្អប់គ្នាជា ដើម ដែលបង្កអោយមានជម្លោះទាស់ទែងកើតឡើងជាអំពើហឹង្សា។ ហើយនៅពេលនោះក៏ការចាប់ផ្តើមមាននូវ ការកាប់សម្លាប់គ្នា កត្តាបែបហើយនេះដែលម្ចាស់កុលសម្ព័ន្ធបានក្លាយខ្លួនជាអាជ្ញាកណ្តាល ឬជាអ្នកវិនិច្ឆ័យ សម្រេចសេចក្តីលើហេតុការណ៍ទាំងនោះ ដោយគេប្រើនូវវិធីម៉្យាងដែលហៅថា "ច្បាប់ព្រៃ" ដោយពួកគេយល់ ឃើញថាបើមាននរណាម្នាក់ធ្វើអោយគេស្លាប់នោះ ពួកគេនិងសម្លាប់អ្នកនោះវិញដើម្បីអោយស្មើភាពគ្នា តែបើ អ្នកណាធ្វើអោយគេពិការដៃនោះ គឺនឹងត្រូវគេកាត់ដៃអ្នកនោះវិញដូចគ្នា ហើយបើអ្នកណាធ្វើអោយគេខ្វាក់ភ្នែក នោះ និងត្រូវគេខ្វេះភ្នែកអ្នកនោះវិញដូចគ្នាទើបគេគិតថាស្មើភាពគ្នា និងយុត្តិធ៌មសំរាប់មនុស្សសម័យកាល នោះ។ ប៉ុន្តែនៅពេលដែលសង្គមមនុស្សមានការវិវត្តន៍ ពួកគេក៏ផ្លាស់ប្តូរនូវការវិនិច្ឆ័យកាត់សេចក្តីបែបនេះ ដោយ ពួកគេយល់ថាការសម្រេចសេចក្តីបែបនេះមានលក្ខណៈព្រៃផ្សៃ សាហាវ ឃោឃៅពេក ហើយបន្សល់ទុកទ្ធជា សោកនាដកម្មដ៏គួរអោយសោកសង្រែងជាខ្លាំងពន់ពេកអនេកកប្បការចំពោះការពិការភាពរបស់អ្នកទទួលដែល បានរងទណ្ឌកម្ម បែបព្រៃផ្សៃទាំងនោះ ដោយក្រលេកមើលឃើញលើអំពើអមនុស្សធ៌មសាហាវឃោងខ្នងបែបនេះ ហើយ ទើបសមាជិកសង្គមទាំងអស់នាំគ្នាសម្រេចជាឆន្ទះរួមគ្នាមួយសម្រាប់សង្គមដើម្បីដោះស្រាយបញ្ហា ទាំងនោះដែលឆន្ទះរួមមួយនោះហៅថា "ច្បាប់" ចំណុចនេះហើយដែលបង្ហាញពីប្រវត្តិការកើតឡើងចេញ ពីឆន្ទះរួមរបស់សមាជិកសង្គម ហើយពួកគេក៏សង្កេតឃើញថាមានលេចឡើងនូវទស្សនៈរបស់អ្នកទស្សនៈវិទូ

ជនជាតិស្វីសម្នាក់ឈ្មោះ "ស្សង់ស្សាក់ រូសសូ" ដែលមានលក្ខណៈល្បីដាច់គេបំផុតនៅក្នុងសតវត្សទី ១៨នាសម័យកាលនោះ។ ហើយបើក្រលេកមកមើលប្រទេសកម្ពុជាយើងនាសម័យអង្គរវិញនោះ គេសង្កេតឃើញថាយើងពុំទាន់មានច្បាប់អ្វីនោះទេ ការសម្រេចសេចក្តីនូវសម័យកាលនោះ គឺអាស្រ័យលើការសម្រេចវិនិច្ឆ័យរបស់ព្រះមហាក្សត្រ។ ព្រះមហាក្សត្រ គឺជាចៅក្រមឬអាជ្ញាកណ្តាលដ៏កំពូលក្នុងការដោះស្រាយវិវាទជូនប្រជារាស្ត្រ។ ព្រះមហាក្សត្រទ្រង់បានរៀបចំជំនួបទទួលរាស្ត្រក្នុងសវនាការ ហើយអ្នកចូលរួមថ្វាយយោបល់មានឥស្សរៈជនជាន់ខ្ពស់ប្រចាំព្រះរាជវាំងឬនៅពេលខ្លះ គឺប្រជាកសិករតូចតាច។ សម័យកាលនោះច្បាប់ឬបទបញ្ញត្តិផ្សេងៗត្រូវបានភ្នាក់ងាររាជការ ដើរស្រែកប្រកូតប្រកាស ឬចារនៅលើផ្ទាំងសិលា ហើយដាក់តាំងផ្សព្វផ្សាយ នៅតាមច្រកចេញចូលទៅតាមទីកន្លែងសក្ការៈដូចជាប្រាសាទ ឬក្លោងទ្វារព្រះបរមរាជវាំងជាដើម ហើយដើម្បីរក្សានូវបទបញ្ញាត្តិទាំងនោះ ក៏មានការចារិកនៅលើស្បែកសត្វ និងលាបស្មុគក្ស័ណ៌។ល។ លុះដល់ក្រោយសម័យអង្គរច្បាប់ទម្លាប់បានបង្កើតបន្តិចម្តងៗជាបន្តបន្ទាប់។ សិលាចរឹកបានបង្ហាញថាប្រជារាស្ត្រត្រូវតែគោរពវិធានផ្សេងៗដែលបានកំណត់ ហើយចំពោះការដែលមិនគោរពនឹងបណ្តាលអោយមានការដាក់ទណ្ឌកម្មដែលធានាដោយអាជ្ញាធរសាធារណៈ។ នៅក្នុងគ្រឹស្តសករាជ្យ ៦២០ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាច្បាប់ខ្មែរក៏ត្រូវបានរៀបរៀងដែលហើយបន្ទាប់មកមានការកែប្រែលំអរ និង ពិនិត្យឡើងវិញក្នុងរជ្ជកាលព្រះបាទអង្គឌួង (១៨៤៧-១៨៦០)។ គេសង្កេតឃើញថាច្បាប់ទាំងនោះត្រូវបានទទួលដោយអាណាព្យាបាលបារាំងពិសេសនៅក្រោយឆ្នាំ ១៩១០។ នាសម័យកាលបច្ចុប្បន្នគេបានចាត់បញ្ចូលប្រព័ន្ធច្បាប់ចម្បងៗនៅលើពិភពលោកដូចជា ច្បាប់ស៊ីវិល ច្បាប់ខមិន ច្បាប់សង្គមនិយម ច្បាប់ឥស្លាម។ ហើយចំពោះប្រព័ន្ធតុលាការនៅកម្ពុជាសម័យបុរាណបានទទួលឥទ្ធិពលពីប្រវត្តិសាស្ត្រដែលជាច្បាប់ខ្មែរបុរាណ ច្បាប់ផ្ទាល់មាត់និងពោរពេញទៅដោយសាសនា។ ព្រះមហាក្សត្រជាតំណាងអទិទេព ដែលមានអំណាចគ្រប់យ៉ាងរាប់ទាំងអំណាចធ្វើសវនាការដោះស្រាយរឿងក្តីគ្រប់ប្រភេទផងដែរ។ អ្នកជួយព្រះមហាក្សត្រគឺយមរាជដែលចាត់ទុកដូចជា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នាសម័យបច្ចុប្បន្ន។ យមរាជគឺជាអ្នកទទួលបន្ទុកដាក់ទណ្ឌកម្មនិងពិន័យ ចាប់តាំងពីទណ្ឌកម្មតូចតាចរហូតដល់ទោសប្រហារជីវិត។ នៅសតវត្សទី១៧ ចាប់ផ្តើមមានការចងក្រងសេចក្តីសម្រេច ដោយព្រះមហាក្សត្របង្កើតបានជាប្រភពនៃច្បាប់ខ្មែរសម័យនោះ។ សន្ធិសញ្ញាខ្មែរ-បារាំងដែលបានចុះហត្ថលេខានៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៨៦ ដើម្បីបង្កើតរបបអនាធិបតេយ្យបារាំងនៅកម្ពុជា យុត្តាធិការដែលខ្មែរធ្លាប់មានកន្លងមកនៅតែបន្តអនុវត្តដដែល។ ពេលនោះយុត្តាធិការខ្មែរមានសមត្ថកិច្ចដោះស្រាយវិវាទរវាងខ្មែរនឹងខ្មែរ ចំណែកយុត្តាធិការបារាំងមានសមត្ថកិច្ចដោះស្រាយជម្លោះរវាងជនបរទេសនិងជនបរទេស។ ផ្ទុយទៅវិញប្រសិនបើមានវិវាទ ជាលក្ខណៈចម្រុះរវាងខ្មែរនិងជនបរទេសនោះយុត្តាធិការបារាំងជាអ្នកមានសមត្ថកិច្ច។ នៅឆ្នាំ១៩៩៨ មានការចាប់ផ្តើមកែប្រែប្រព័ន្ធយុត្តិធម៌ខ្មែរតាមបែបបារាំង។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ ព្រះមហាក្សត្រខ្មែរ ព្រះបាទស៊ីសុវត្ថិ បានប្រកាសឲ្យប្រើក្រមរដ្ឋ

ប្បវេណីថ្មី។ ចំណែកក្រមនីតិវិធីរដ្ឋប្បវេណី ក៏ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៣៨ ដែលក្នុងនោះស្ថាប័នតុលាការខ្មែរ មានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងស្ថាប័នតុលាការបារាំងដែលសបញ្ជាក់ថា ប្រទេសកម្ពុជា ចាប់ផ្តើមទទួលយកប្រព័ន្ធច្បាប់សរសេរជាប្រព័ន្ធច្បាប់ស៊ីវិលចាប់ពីពេលនោះមក។ នៅក្នុងចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ប្រព័ន្ធតុលាការខ្មែរបានបាត់បង់ទាំងស្រុងមិនតែប៉ុណ្ណោះ ចៅក្រមនឹងអ្នកច្បាប់ត្រូវបានសម្លាប់ស្ទើរតែទាំងអស់។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ បន្ទាប់ពីឆ្លងកាត់នូវដំណាក់កាលដ៏ខ្មៅងងឹតមួយអស់រយះពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត។ រដ្ឋធម្មនុញ្ញមួយនៃរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាក៏ត្រូវបានអនុម័តនៅឆ្នាំ១៩៨១។ ក្រិតច្បាប់ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ បានបង្កើតតុលាការប្រជាជនបដិវត្តន៍ខេត្តក្រុង។ ប្រព័ន្ធតុលាការនៅក្នុងចន្លោះឆ្នាំ ១៩៧៩-១៩៨៥ គឺមានតែតុលាការបដិវត្តន៍ខេត្តក្រុងប៉ុណ្ណោះ(សាលាដំបូង) ដែលជាតុលាការសម្រាប់កាត់ក្តីនិងជំនុំជម្រះលើកទី១និងលើកចុងក្រោយ។ សាលក្រមដែលចេញដោយតុលាការនេះ ត្រូវបានត្រួតពិនិត្យមើលឡើងវិញដោយក្រសួងយុត្តិធម៌និងសម្រេចចុងក្រោយដោយក្រុមប្រឹក្សារដ្ឋ(ក្រុមប្រឹក្សារដ្ឋជាអង្គការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា)។ ក្រុមប្រឹក្សារដ្ឋអាចពិនិត្យមើលឡើងវិញ តាមសំណើររបស់ក្រសួងយុត្តិធម៌ ឬរដ្ឋសភានូវសេចក្តីសម្រេចរបស់តុលាការ។ ប្រើក្រុមប្រឹក្សារដ្ឋពិនិត្យឃើញថាសាលក្រមដែលចេញដោយតុលាការខេត្តក្រុងមិនត្រឹមត្រូវនោះ ក្រុមប្រឹក្សារដ្ឋបញ្ជូនសាលក្រមនោះទៅតុលាការខេត្តក្រុងវិញដោយឲ្យកាត់ក្តីសារជាថ្មីតាមការណែនាំរបស់ក្រុមប្រឹក្សារដ្ឋដោយប្រើសមាសធាតុថ្មី។ ពេលនោះក្រុមប្រឹក្សារដ្ឋដើរតួជំនួសតុលាការកំពូលផងជំនួសមហាអយ្យការអមតុលាការកំពូលផង។ នៅក្នុងឆ្នាំ១៩៨៥ តុលាការកំពូលក៏ត្រូវបានបង្កើតឡើងដោយទទួលយកនាទីដែលក្រុមប្រឹក្សារដ្ឋមានកន្លងមក។ ក្រោយពេលអាជ្ញាធរអង្គការសហប្រជាជាតិនៅកម្ពុជាហៅកាត់ថា "អ៊ុន តាក់" ចូលមកប្រព័ន្ធតុលាការក៏បានផ្លាស់ប្តូរដោយបង្កើតបន្ថែមនូវសាលាឧទ្ធរណ៍ដោយច្បាប់ព្រហ្មទណ្ឌអន្តរកាល និងបំពេញបន្ថែមដោយច្បាប់ចុះថ្ងៃទី ០៨ កុម្ភៈ ឆ្នាំ ១៩៩៣។ ដូច្នេះចាប់ពីឆ្នាំ១៩៩៣មកប្រព័ន្ធតុលាការកម្ពុជាមាន ៣កម្រិតគឺ សាលាដំបូង សាលាឧទ្ធរណ៍ នឹងតុលាការកំពូល។

## ក. លំនាំបញ្ហានៃការស្រាវជ្រាវ

ដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌតុលាការកម្ពុជា គឺជាកិច្ចដំណើរការមួយនៃនីតិវិធីព្រហ្មទណ្ឌដែលរៀបរាប់ទាក់ទងតាំងពីដំណើរការដំបូងដែលជាតួនាទីរបស់នគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរហូតដល់ចៅក្រមជំនុំជម្រះចេញនូវសេចក្តីសម្រេចដែលមានច្រើនដំណាក់កាលទម្រាំនឹងដល់នូវកិច្ចបញ្ចប់ចុងក្រោយ និងដែលរាប់រៀបរាប់អំពីលំហូរនៃនីតិវិធីជំនុំជម្រះនៅសាលាដំបូងរហូតដល់សាលាឧទ្ធរណ៍ និងតុលាការកំពូលដែលបិទនូវផ្លូវបណ្តឹងនៃការតវ៉ា។ កត្តាទាំងអស់នេះហើយដែលជាលក្ខណះស្មុគស្មាញរបស់

ប្រធានបទដែលតម្រូវអោយមានការវែកញែកនៃនីតិវិធីនីមួយៗអោយបានច្បាស់លាស់និងដាច់ឡែកពីគ្នា ដើម្បីកុំអោយនូវមានមន្ទិលសង្ស័យក្នុងនីតិវិធីនីមួយៗខាងលើនេះ។

ដូច្នេះដើម្បីស្វែងយល់ឲ្យកាន់តែស៊ីជម្រៅ ទាមទារឲ្យមានការបកស្រាយអោយបានច្បាស់លាស់បន្ថែមចំពោះចំណុចនីមួយៗ ដើម្បីងាយស្រួលក្នុងការស្វែងយល់របស់និស្សិត អ្នកសិក្សា ស្រាវជ្រាវទាំងអស់។ ហើយចំពោះសារណានេះ ទៀបសោតនិងរៀបរាប់បកស្រាយពីសារណាតាមកម្រិតថ្នាក់បរិញ្ញាបត្រ ដើម្បីជាការចែករំលែកជាពុទ្ធិចំណេះដឹងជូនដល់មិត្តអ្នកសិក្សា ស្រាវជ្រាវទាំងឡាយណាដែលមានគោលបំណងចង់សិក្សាស្រាវជ្រាវស្វែងយល់ពីដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌនេះថាមាននីតិវិធីបែបណាដើម្បីជាចំណេះដឹង និងជាពិសេសសម្រាប់អ្នកដែលចង់ខ្លួនជាអ្នកអនុវត្តច្បាប់ ជានគរបាលយុត្តិធម៌ អយ្យការ ចៅក្រមក្នុងថ្ងៃអនាគតជាដើម។ ហើយយើងខ្ញុំសង្ឃឹមថាសារណាមួយនេះ និងចូលខ្លួនបំរើជាប្រយោជន៍ប្រើប្រាស់តាមតែតម្រូវការដែលជាចំលែកនូវពុទ្ធិតូចមួយនៃនីតិវិធីព្រហ្មទណ្ឌ ដែលសម្រាប់ពង្រឹងដល់ភាពត្រឹមត្រូវនៃការអនុវត្តនីតិវិធីក៏ដូចជាដំណើរការនៃការដឹកនាំនីតិវិធីព្រហ្មទណ្ឌផងដែរ។

## ខ. ចំណោទបញ្ហានៃការដោះស្រាយ

ដើម្បីជាការយល់ដឹងអោយកាន់តែច្បាស់លាស់ស៊ីជម្រៅនូវ "ដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌតុលាការកម្ពុជា" យើងត្រូវដឹងនូវការចំណុចសំខាន់ៗមួយចំនួនដែលជាគោលការណ៍ពាក់ព័ន្ធនិងដំណើរការនៃនីតិវិធី តួនាទីតួអង្គដែលសំខាន់ៗ ក្នុងដំណើរការនៃនីតិវិធីខាងលើរបស់យើងដូចជា៖

- តើដំណើរការរឿងក្តីព្រហ្មទណ្ឌជាអ្វី?
- តើដំណើរការរឿងក្តីព្រហ្មទណ្ឌមានគោលការណ៍ដែលពាក់ព័ន្ធដល់កិច្ចនៃនីតិវិធីតុលាការនោះមានអ្វីខ្លះ?
- តើដំណើរការរឿងក្តីព្រហ្មទណ្ឌនោះមានតួអង្គសំខាន់អ្វីខ្លះ?
- តើដំណើរការរឿងក្តីព្រហ្មទណ្ឌ តួអង្គសំខាន់ៗនោះមានតួនាទីភារៈកិច្ចក្នុងដំណើរការនៃការអនុវត្តនីតិវិធីដូចម្តេច?
- តើដំណើរការក្នុងសាលាជម្រះក្តីតាមជាន់ថ្នាក់នីមួយៗក្នុងមាននីតិវិធីបែបបទដូចម្តេច?

## គ. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះមានគោលបំណងក្នុងការចែករំលែកនូវពុទ្ធិចំណេះដឹងខ្លះៗ ឬជាផ្នែកមួយនៃដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌដែលជានីតិវិធីរបស់តុលាការដែលមានសារៈប្រយោជន៍យ៉ាងសំខាន់ណាស់ក្នុងប្រព័ន្ធតុលាការ ឬវិស័យយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា។ ហើយម្យ៉ាងវិញទៀត តើតួអង្គសំខាន់ៗក្នុងនីតិវិធីតុលាការមានតួនាទីភារៈកិច្ចចូលរួមក្នុងកិច្ចនីតិវិធីដូចម្តេចខ្លះ? ហើយយើងខ្ញុំជឿជាក់ថាកិច្ចការស្រាវជ្រាវមួយនេះ គឺជាស្នាដៃមួយដែលកើតចេញពីស្រាវជ្រាវរបស់យើងខ្ញុំដើម្បីទុកជាជំនួយដល់និស្សិត មិត្តអ្នកសិក្សា

ស្រាវជ្រាវទាំងឡាយណា ដែលចង់ស្វែងយល់ពីដំណើរការរឿងក្តីព្រហ្មទណ្ឌដែលជានីតិវិធីនៃតុលាការរបស់ព្រះរាជាណាចក្រកម្ពុជា ហើយក៏ជាផលប្រយោជន៍មួយដល់អ្នកទាំងឡាយណាដែលមានគោលបំណងប្រកបអាជីពវិជ្ជាជីវៈក្នុងវិស័យយុត្តិធម៌។

## ឃ. ទំហំ នឹងដែនដីកំណត់នៃការស្រាវជ្រាវ

សម្រាប់កិច្ចការសិក្សាស្រាវជ្រាវមួយនេះ គឺផ្តោតទៅលើការសិក្សាទាក់ទងនិងដំណើរការដោះស្រាយរឿងក្តីព្រហ្មទណ្ឌរបស់តុលាការកម្ពុជាដែលជាតួនាទី និងភារៈកិច្ចស្ថិតក្នុងអធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា និងសិក្សាព៌ណនាអំពីការដំណើរការនៃនីតិវិធីចាប់ផ្តើមតាំងពីដំណាក់កាលដំបូង រហូតដល់មានការជំនុំជម្រះចេញនូវសេចក្តីសម្រេចរបស់តុលាការហើយក៏បានបង្ហាញអំពីតួនាទី និងភារៈកិច្ចរបស់តួអង្គនីមួយៗនៅក្នុងសាលាជម្រះក្តីផងដែរ ហើយរៀបរាប់តាំងពីដំណាក់ការប្រព្រឹត្តបទល្មើស រហូតដល់ដំណាក់ការនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ រហូតដល់ចៅក្រមជំនុំជម្រះចេញសេចក្តីសម្រេចហើយក៏បង្ហាញដំណាក់ការជំនុំជម្រះរបស់សាលាជំនុំជម្រះជាន់ទាប រហូតដល់សាលាជំនុំជម្រះជាន់ខ្ពស់របស់តុលាការកំពូលផងដែរ។

## ង. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានអត្ថប្រយោជន៍ជាជំនួយស្មារតី ជាពុទ្ធិ នឹងពង្រឹងចំណេះដឹង ក៏ដូចជាផ្តល់ជាជំនួយផ្នែកធនធានចំណេះដឹងសម្រាប់បំពេញមុខងារក្នុងវិស័យយុត្តិធម៌របស់តុលាការ និងអ្នកដែលបំពេញមុខងារជាអ្នកអនុវត្តច្បាប់។ ជាពិសេសមិត្តអ្នកសិក្សាស្រាវជ្រាវ ប្រជាពលរដ្ឋគ្រប់រូប អាចសិក្សាស្វែងយល់បានអំពីតួនាទី និងភារៈកិច្ចរបស់តួអង្គសំខាន់ៗនីមួយៗផ្សេងគ្នា និងជាគោលការណ៍ មូលដ្ឋានគ្រឹះនៃដំណើរការនីតិវិធីរបស់តុលាការ ចំពោះរឿងក្តីព្រហ្មទណ្ឌអោយបានយល់ដឹងកាន់តែច្បាស់លាស់។

## ច. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះការប្រមូលទិន្នន័យឯកសារផ្សេងៗដែលទាក់ទងប្រធានបទនេះ យើងខ្ញុំបានព្យាយាមស្រាវជ្រាវជាលក្ខណៈទូទៅនៃប្រធានបទ គឺតាមប្រព័ន្ធអ៊ីនធើណេត ក៏ដូចជាការសាកសួរពិគ្រោះសុំយោបល់ពីសំណាក់លោកគ្រូសាស្រ្តាចារ្យណែនាំ នឹងសាស្រ្តាចារ្យច្បាប់នៅសាកលវិទ្យាល័យផ្ទាល់ និស្សិតរាមច្បង មិត្តរួមថ្នាក់ មិត្តរួមការងារ និងមន្រ្តីរាជការតាមស្ថាប័នរដ្ឋនីមួយៗដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវរបស់ប្រធានបទយើងខ្ញុំ។ ជាពិសេសនោះ គឺការស្វែងរកឯកសារដែលមានលក្ខណៈជាលាយលក្ខណ៏អក្សរផ្សេងៗ ដែលយើងខ្ញុំបានស្វះស្វែងរកពីប្រភពជាច្រើនដូចជាតាមបណ្ណាល័យនានា តាំងក្នុងសាលានឹងនៅខាងក្រៅ ដូចជាតាមបណ្ណាសារដ្ឋានជាតិក្នុងរាជធានីភ្នំពេញ តាមតូបលក់សៀវភៅដូចជាពន្លឺវិជ្ជា បណ្ណាគារ និងគេហៈទំព័រជាតិធំៗ និងច្បាប់បរទេសមួយចំនួនទៀត ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការធ្វើអោយការស្រាវជ្រាវសារណានេះលេចជារូបរាងឡើងបានដោយជោគជ័យ។

**ឆ. រចនាសម្ព័ន្ធការស្រាវជ្រាវ**

សារណានេះយើងខ្ញុំបានរៀបរៀងនឹងចែកចេញជា ៣(បី)ជំពូកធំៗ៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃរឿងក្តីព្រហ្មទណ្ឌ ។**

តើនៅក្នុងសញ្ញាណទូទៅ ឬទិដ្ឋភាពទូទៅនៃបទល្មើសព្រហ្មទណ្ឌនេះមានអ្វីខ្លះ?

តើក្នុងសញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌមានរចនាសម្ព័ន្ធដូចម្តេច? ហើយមានគោលការណ៍សំខាន់ៗអ្វីខ្លះដែលពាក់ព័ន្ធ?

**ជំពូកទី២៖ ដំណើរការរឿងក្តីព្រហ្មទណ្ឌ ។**

តើដំណើរការនៃរឿងក្តីព្រហ្មទណ្ឌជាអ្វី? ហើយក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌនេះមានតួអង្គសំខាន់ៗណាខ្លះ? ហើយចំពោះតួអង្គសំខាន់ៗទាំងអស់នោះមានតួនាទី និងភារៈកិច្ចដូចម្តេចខ្លះ?

**ជំពូកទី៣៖ ការជំនុំជម្រះ ។**

តើការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌមានដំណើរការដូចម្តេច? ហើយមាននីតិវិធីនៃដំណើរការរឿងក្តីនេះដូចម្តេចខ្លះ? ហើយមានរចនាសម្ព័ន្ធនៃការជំនុំជម្រះអ្វីខ្លះ?

តើការជំនុំជម្រះនៃតុលាការជាន់ថ្នាក់នីមួយៗមានភាពខុសគ្នា និងមានលក្ខណះហាក់ប្រហែលគ្នាដូចម្តេចខ្លះ?

តើសេចក្តីសម្រេចរបស់តុលាការជាន់ថ្នាក់នីមួយៗខុសគ្នាដូចម្តេច?

# ជំពូកទី១

# សញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌ

បទបញ្ញាត្តិក្នុងក្រមព្រហ្មទណ្ឌបានចែងអំពីបទល្មើស និងទោសដែលត្រូវអនុវត្តទៅលើបុគ្គលដែលប្រព្រឹត្តល្មើស និងច្បាប់ព្រហ្មទណ្ឌនេះ[1]។ ក្រមព្រហ្មទណ្ឌត្រូវបានចាត់ទុកថាជាច្បាប់ទូទៅ ហើយក៏មានច្បាប់ពិសេសដោយឡែក និងច្បាប់អន្តរជាតិមួយចំនួនផ្សេងទៀតដែលត្រូវយកមកអនុវត្តទន្ទឹមនិងគ្នានេះផងដែរមានដូចជាច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីចរាចរណ៍ និងកតិកាសញ្ញាអន្តរជាតិជាដើម។ សរុបជារួមមកច្បាប់ព្រហ្មទណ្ឌកម្ពុជារមែងចែងពីបទល្មើស ទោស និងការទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។

## ផ្នែកទី១៖ បទល្មើសព្រហ្មទណ្ឌ

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើទាំងឡាយណាដែលប្រព្រឹត្តដោយចេតនាក្តីឬដោយអចេតនាក្តី ដោយសកម្មក្តី ដោយប្រយោលក្តីដែលអំពើទាំងនោះបណ្តាលអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈឬសន្តិសុខសង្គមដែលបង្ករជាវិព្យសនកម្ម និងចលាចលដល់សង្គមជាតិហើយដែលត្រូវបានកំណត់ទុកជាមុនថាជាបទល្មើសព្រហ្មទណ្ឌដែលជាបញ្ញាត្តិមានចែងទុកជាមុនក្នុងក្រមព្រហ្មទណ្ឌ។ បទល្មើសព្រហ្មទណ្ឌភាគច្រើនបង្ករឡើងដោយអំពើហឹង្សា និងប៉ះពាល់ដល់ផ្លូវកាយ ផ្លូវចិត្ត និងកិត្តិយសរបស់ជនរងគ្រោះដោយសារអំពើបំពាន និងបញ្ញាត្តិនៃច្បាប់ព្រហ្មទណ្ឌនោះ។ ជាទូទៅបទល្មើសព្រហ្មទណ្ឌនីមួយៗតែងតែមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ជាដាច់ខាតហើយប្រសិនបើខ្វះធាតុផ្សំណាមួយ គឺមិនអាចចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌបានឡើយ ដើម្បីកំណត់ថាអំពើណាមួយជាបទល្មើសព្រហ្មទណ្ឌបានលុះត្រាតែមានធាតុផ្សំចំនួនបីសំខាន់ៗជាចម្បងគឺ៖ ធាតុនីត្យានុកូល(**ធាតុច្បាប់**) ធាតុសត្យានុម័ត(**ធាតុសម្ភារៈ**) និងធាតុអន្តោម័ត(**ធាតុចិត្តសាស្ត្រ**)។

### ១.១. ធាតុនីត្យានុកូល ឬធាតុច្បាប់

ធាតុនីត្យានុកូលឬធាតុច្បាប់ គឺជាធាតុចាំបាច់ដើម្បីកំណត់ថាអំពើណាមួយជាបទល្មើសព្រហ្មទណ្ឌបានលុះត្រាតែមានបទបញ្ញាត្តិចែងច្បាស់លាស់ ក្នុងក្រមព្រហ្មទណ្ឌជាធរមានថាជាបទល្មើសព្រហ្មទណ្ឌ[2]។ ប្រសិនបើពុំមានបទបញ្ញាត្តិច្បាប់ ឬពុំបានចែងច្បាស់លាស់ថាអំពើនោះជាបទល្មើសព្រហ្មទណ្ឌនោះទេ យើងក៏មិនអាចចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌបានឡើយ។ ហេតុដូចនេះហើយបានជាមានគោលការណ៍បារាំងមួយបានចែងថា "គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង" ឬម្យ៉ាងទៀតថា "គ្មានបទល្មើសណាមួយដែលច្បាប់ពុំបានចែងនោះទេ"។ លើសពីនេះទៅទៀតគេឃើញមានគោលការណ៍បារាំងមួយផ្សេងទៀតបានចែងថា

[1] មាត្រា ១នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[2] មាត្រា ៣នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

"អ្វីៗទាំងអស់ដែលគេមិនបានហាមឃាត់ទេនោះ គឺត្រូវបានគេអនុញ្ញាតអោយធ្វើ" មានន័យថាអ្វីដែលច្បាប់ពុំបានចែងថាជាបទល្មើសនោះទេ គឺជាសិទ្ធដែលច្បាប់អនុញ្ញាត្តិផ្តល់អោយយើងធ្វើសកម្មភាពទាំងនោះ[3]។ ដោយផ្អែកទៅតាមគោលការណ៍ទាំងពីរខាងលើនេះ ចៅក្រមក៏មិនអាចធ្វើការចោទប្រកាន់ឬផ្តន្ទាទោសជនណាម្នាក់ដោយពឹងផ្អែកទៅលើការឃើញបទល្មើសថ្មីនោះទេ ពីព្រោះមានតែច្បាប់ដែលអនុម័តដោយរដ្ឋសភាទេ ដែលបានបញ្ញាតិថាអំពើណាមួយជាបទល្មើសព្រហ្មទណ្ឌដែលបានចាត់ថ្នាក់ថា ជាបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុ ទើបចៅក្រមអាចចោទប្រកាន់ថាជាបទល្មើសព្រហ្មទណ្ឌបាន។ ម្យ៉ាងវិញទៀតចៅក្រមក៏មិនអាចបន្ថែមឬបន្ថយនូវសេចក្តីខ្វះខាតនៃច្បាប់បានឡើយ ហើយក៏មិនអាចអនុវត្តនូវទោសដែលក្រៅពីច្បាប់បានចែងទុកជាមុននោះបានឡើយ[4]។ ដូច្នេះមានន័យថា មានតែអំពើដែលបង្កើតជាបទល្មើសនូវពេលដែលអំពើនោះត្រូវបានចែងក្នុងបទបញ្ញាត្តិនៃក្រមព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបអាចត្រូវចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌបាន ហើយក៏មានតែទោសដែលបានចែងក្នុងបទបញ្ញាត្តិក្រមព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបអាចសម្រេចប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌបាន។ គោលការណ៍នេះ គឺដើម្បីអាចធានាបាននូវការអនុវត្តដោយមិនរំលោភបំពាន ឬខុសនូវបទបញ្ញត្តិច្បាប់ដោយចៅក្រមទៅលើជនណាមួយ។ ប៉ុន្តែក៏មានមតិខ្លះពោលថាគោលការណ៍ "គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង" នោះវាហាក់ដូចជាផ្តល់លទ្ធភាពច្រើនទៅអោយជនខិលខូចដោយអាចអោយជនទាំងនោះឆ្លៀតឱកាស ចន្លោះប្រហោងនៃច្បាប់ដើម្បីប្រព្រឹត្តិនូវអំពើណាមួយផ្សេងទៀតដែលច្បាប់មិនបានហាមឃាត់ ដែលអាចបណ្តាលអោយប៉ះពាល់ទៅដល់ផលប្រយោជន៏ឯកជន ឬប៉ះពាល់ផលប្រយោជន៏សាធារណះផងដែរដូចជា ករណីការប្រើជញ្ជីងដែលមានរង្វាស់ខ្វាតមិនត្រឹមត្រូវការគិតថ្លៃខ្ពស់ចំពោះអាហារដែលបរិភោគរួចដោយមិនបានបង្ហាញតារាងតម្លៃជាមុន។ ប៉ុន្តែត្រង់ចំណុចទាំងនេះខាងលើ មិនមានន័យថាចៅក្រមមិនមានសិទ្ធិបកស្រាយច្បាប់ដែលមហាជនមានការភន្ត័ច្រឡំនោះទេ។

### ១.២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ

ធាតុសម្ភារៈឬធាតុសត្យានុម័ត គឺជាអំពើប្រព្រឹត្តទាំងឡាយណាដែលប្រព្រឹត្តក្រោមរូបភាពសកម្មក្តី ឬអកម្មក្តី ប៉ុន្តែអំពើទាំងឡាយនោះបណ្តាលអោយប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពបុគ្គល ទ្រព្យសម្បត្តិសាធារណះ ឬឯកជន និងមានចរិតគ្រោះថ្នាក់ដល់សង្គម។ ធាតុសម្ភារៈឬធាតុសត្យានុម័តនេះ ជាតួអង្គមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបានប្រសិនបើមនុស្សមិនមានការប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់នោះទេ ក៏មិនមានលទ្ធផលអាក្រក់កើតឡើងជាវិព្យសនកម្មដល់សង្គមផងដែរ។ អំពើប្រព្រឹត្តដោយមនុស្សនេះបានបញ្ជាក់យ៉ាងច្បាស់

[3] ជាអនុសាសន៏របស់ឯកឧត្តម កើត រិទ្ធ ,ប៊ុន ហ៊ុន ,ផូវ សំភីក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៧

[4] មាត្រា ៦នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

អំពីឆន្ទៈដែលសម្តែងចេញមកខាងក្រៅ និងដែលជាសញ្ញាសម្គាល់មួយយ៉ាងសំខាន់របស់ធាតុសម្ភារៈឬធាតុសត្យានុម័ត។ ដើម្បីសម្រេចនូវអំពើល្មើសរបស់ខ្លួន ជនល្មើសប្រើប្រាស់គ្រប់មធ្យោបាយឧបករណ៍ កលល្បិចប្រព្រឹត្តក្នុងស្ថានភាពនិងពេលវេលាដែលយល់ឃើញថាអំណោយផលដល់ការប្រព្រឹត្តបទល្មើសរបស់គេ។

### ១.២.១. បទល្មើសបានសម្រេច

បទល្មើសបានសម្រេច គឺជាអំពើប្រព្រឹត្តទាំងឡាយណា ផលវិបាកឬលទ្ធផលចុងក្រោយបានបំពេញគោលបំណងឬគោលដៅដែលជនល្មើសចង់បាននោះដូចជា ឈ្មោះ(ក)បានធ្វើសកម្មភាពឆក់ខ្សែរក ឈ្មោះ(ខ) ហើយក៏ឆក់បានសម្រេចនូវខ្សែរកនោះហើយក៏គេចខ្លួនបាត់ទៅ។ ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចំពោះបទល្មើសបានសម្រេចនោះ គឺសំដៅទៅលើអំពើចំនួន ២(ពីរ)យ៉ាងគឺ៖ អំពើប្រព្រឹត្តដោយសកម្ម(បទល្មើសសកម្ម) និងអំពើប្រព្រឹត្តដោយអកម្ម(បទល្មើសអកម្ម)។

### ១.២.២. បទល្មើសមិនបានសម្រេច

បទល្មើសមិនបានសម្រេច គឺជាអំពើប្រព្រឹត្តដោយចេតនាក៏ប៉ុន្តែអំពើនោះមិនបានចប់សព្វគ្រប់សមទៅតាមបំណងនោះឡើយដោយសារមូលហេតុផ្សេងៗមកបង្អាក់សកម្មភាពទាំងនោះដូចជា៖

- ម្ចាស់គេមកទាន់ ឬអ្នកដទៃមកទាន់ដូចជាជនល្មើសកំពុងខ្វេះសោរម៉ូតូគេនៅក្រោមជណ្តើរស្រាប់តែម្ចាស់ម៉ូតូនោះមកដល់ ឬកំពុងខ្វេះសោរផ្ទះគេស្រាប់តែអ្នកជិតខាងមកទាន់ ជនល្មើសក៏រត់គេចខ្លួនទៅ។
- ជនល្មើសខ្វះទេពកោសលដូចជា ឈ្មោះ(ក)ចង់សម្លាប់ ឈ្មោះ(ខ)ហើយក៏លើកកាំភ្លើងបាញ់តម្រង់ទៅ ឈ្មោះ(ខ)តែដោយសារគ្មានទេពកោសល្យក្នុងការប្រើប្រាស់កាំភ្លើងក៏បាញ់ខុស។ បទល្មើសមិនបានសម្រេចជាមូលហេតុនាំអោយគេអាចចោទប្រកាន់ពីបទប៉ុនប៉ងនេះហើយក៏ត្រូវផ្តន្ទាទោសដូចគ្នាជាមួយនិងបទល្មើសបានសម្រេចដែរ[5]។

## ១.៣. ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ

ធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រ គឺសំដៅទៅលើស្ថានភាពផ្លូវចិត្តរបស់ជនល្មើសដែលអំពើប្រព្រឹត្តមួយ។ ប្រសិនបើគ្រាន់តែមានធាតុនីត្យានុកូលឬធាតុច្បាប់ និងធាតុសត្យានុម័តឬធាតុសម្ភារៈនោះ វាមិនទាន់គ្រប់គ្រាន់ទេ គឺដាច់ខាតត្រូវតែមានធាតុអត្តនោម័តឬធាតុចិត្តសាស្ត្របន្ថែមទៀតទើបអាចមានលក្ខណៈគ្រប់គ្រាន់ជាបទល្មើសបើពុំដូច្នេះទេគេមិនអាចចាត់ទុកថាជាបទល្មើសបានឡើយ។

ធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រ គឺជាឆន្ទៈផ្លូវចិត្តគំនិតខាងក្នុងរបស់ជនល្មើសដែលវាស្តែងមកខាងក្រៅតាមរយៈធាតុសម្ភារៈឬធាតុសត្យានុម័ត ដូចជាកាយវិការឬអំពើប្រព្រឹត្តរបស់ជនល្មើស។ គេអាចនិយាយបានម៉្យាងទៀតថា ធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រនេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតជាមួយនិងធាតុសម្ភារៈឬ

[5] ដកស្រង់ចេញពីសៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរាងដោយលោក ផេង គឹមស្រ៊ុន

ធាតុសត្យានុម័ត។ ធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រច្រើនតែសម្តែងឡើងក្រោមរូបភាពដូចជាកំហុស គោលបំណងនិងកត្តាទៀតផ្សេងៗដែលជំរុញអោយមានការប្រព្រឹត្តបទល្មើសកើតឡើង។ តាមការសិក្សាស្រាវជ្រាវខាងផ្នែកចិត្តសាស្ត្រជាមូលដ្ឋានគេបានបែងចែកជាពីរធំៗ៖ ចេតនាប្រព្រឹត្តបទល្មើស(បទល្មើសចេតនា) និងអចេតនាប្រព្រឹត្តបទល្មើស(បទល្មើសអចេតនា)។

### ១.៣.១. បទល្មើសដោយចេតនា

បទល្មើសដោយចេតនាឬចេតនាប្រព្រឹត្តបទល្មើស គឺជាឆន្ទៈឆ្ពោះទៅរកការសម្រេចបទល្មើសបានសេចក្តីថាពេលប្រព្រឹត្តអំពើល្មើសមួយជនល្មើសយល់ដឹងច្បាស់លាស់នូវកំរិតគ្រោះថ្នាក់ដល់សង្គមនៃអំពើរបស់ខ្លួន និងដឹងជាមុននូវផលវិបាកដែលនឹងកើតឡើង ដោយសារអំពើប្រព្រឹត្តរបស់ខ្លួនហើយចង់អោយផលវិបាកនោះបានកើតមានឡើង។

- ឆន្ទៈក្នុងនីតិព្រហ្មទណ្ឌ៖ គឺជាពន្លកនៃផ្នត់គំនិតរបស់ជនល្មើសនោះយកមកធ្វើជាមូលដ្ឋានដើម្បីឈានទៅដល់ការសម្រេចបំណងរបស់ខ្លួនដូចជា លទ្ធផលចុងក្រោយដែលជនល្មើសនោះមានបំណងគឺចង់សម្រេចអោយបាន។ ក្នុងករណីនេះ យើងមិនត្រូវភ័ន្តច្រឡំរវាងឆន្ទៈ និងផលវិបាកនៃបទល្មើសឡើយពីព្រោះឆន្ទៈ គឺជាធាតុមួយស្ថិតនូវក្នុងធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រ ចំណែកឯផលលំបាកវិញវាស្ថិតនៅក្នុងធាតុសត្យានុម័ត ឬធាតុសម្ភារៈដូចជា ឈ្មោះ(ក)សម្លាប់ ឈ្មោះ(ខ)ដែលជាគូប្រជែងក្នុងរឿងស្នេហាជាមួយខ្លួន។ ការស្លាប់របស់ ឈ្មោះ(ខ)គឺជាផលវិបាកដែលជាលទ្ធផលជាក់ស្តែងរបស់ឈ្មោះ(ក)បានបង្កឡើងដើម្បីសម្រេចនូវឆន្ទៈរបស់ខ្លួន។ ដូច្នេះឆន្ទៈ គឺជាលក្ខណៈសម្គាល់នៃធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រដែលវាឆ្លុះបញ្ចាំងអាការៈផ្នែកខាងក្នុងនៃចិត្តគំនិតរបស់ ឈ្មោះ(ក)ដែលហៅថា "គោលបំណង"។ តាមនីតិវិទ្យាឆន្ទៈ គឺជាព្រឹត្តហេតុមួយប្រកបដោយមនសិការនិងដោយសេរីបានសេចក្តីថាមិនមែនដោយភាពវិកលចរិតទេហើយមិនមែនដោយការបង្ខិតបង្ខំរបស់អ្នកដទៃណាឡើយ។ នៅពេលប្រព្រឹត្តបទល្មើសជនល្មើសយល់ច្បាស់ថាកំរិតគ្រោះថ្នាក់ដល់សង្គមនៃអំពើរបស់ខ្លួននិងកើតមានឡើងជាដាច់ខាតហើយអំពើល្មើសច្បាប់នោះត្រូវកើតឡើង ឬផុសចេញពីគំនិតផ្ទាល់របស់ជនល្មើសពោល គឺគ្មានការបង្ខិតបង្ខំពីសំណាក់អ្នកដទៃឡើយ។

### ១.៣.២. បទល្មើសដោយអចេតនា

បទល្មើសអចេតនាឬអចេតនាប្រព្រឹត្តបទល្មើស គឺជាបទល្មើសដែលកើតឡើងទោះបីជាចារីពុំមានបំណងក្នុងការប្រព្រឹត្តបទល្មើសក៏ដោយ។ ចំពោះបទល្មើសដោយអចេតនាភាពសុចរិតរបស់ចារីពុំមែនជាធាតុផ្សំបទល្មើសទេ បានសេចក្តីថាទោះបីជាពុំមានបំណងទុច្ចរិតក៏ដោយ ក៏នូវតែមានបទល្មើសកើតឡើងបានដដែលដូចជាបទមនុស្សឃាតអចេតនា។ សព្វថ្ងៃយើងសង្កេតឃើញថាប្រជាជនដែលរស់នៅរាជធានីភ្នំពេញចូលចិត្តនូវ

លម្អគេហដ្ឋានរបស់គាត់ដោយការដាំផ្កាក្នុងផើងផ្កាសំរាប់តាំងលម្អផ្ទះនៅតាមរង់ជាខាងមុខផ្ទះ ហើយដោយគាត់មិនបានប្រុងប្រយ័ត្នក៏បានចងភ្ជាប់ផើងផ្កានោះមិនអោយធ្លាក់ឡើយ ប៉ុន្តែថ្ងៃមួយមានភ្លៀងខ្យល់ខ្លាំងបោកអោយធ្លាក់ផើងផ្កានោះធ្លាក់ចុះមកក្រោមចំក្បាលបុរសម្នាក់ស្លាប់ជាដើម[6]។

## ផ្នែកទី២៖ ការទទួលខុសត្រូវ និងមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើរបស់ខ្លួនតែប៉ុណ្ណោះ។ ត្រង់ចំណុចនេះក្នុងក្រមព្រហ្មទណ្ឌហៅថាគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។

### ២.១. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺសំដៅដល់ការទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួន[7]។ ចំពោះអំពើផ្ទាល់ខ្លួនត្រង់ចំណុចនេះ គឺមានន័យថាបើបុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើស បុគ្គលនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនផងដែរ។ ករណីនេះ គឺខុសពីរឿងក្តីរដ្ឋប្បវេណីមានន័យថាក្នុងរឿងរដ្ឋប្បវេណីច្បាប់អនុញ្ញាតអោយអ្នកដទៃទទួលខុសត្រូវជំនួសបាន។ ប៉ុន្តែនៅក្នុងរឿងព្រហ្មទណ្ឌអ្នកណាជាអ្នកប្រព្រឹត្តបទល្មើសអ្នកនោះ គឺជាអ្នកទទួលខុសត្រូវ ដែលសុភាសិតខ្មែរយើងបានពោលថា “អ្នកណាធ្វើ អ្នកនោះទទួល” មូលហេតុនេះ ហើយមិនអាចអោយអ្នកដទៃចូលទៅទទួលទោសជំនួសនោះទេ ទោះបីទោសនោះជាទោសប្រភេទអ្វីមួយក៏ដោយដូចជា មូលទោស គឺជាទោសដាក់ពន្ធនាគារនិងទោសពិន័យជាប្រាក់។ ប្រសិនបើជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ គឺច្បាប់មិនអនុញ្ញាតអោយអ្នកដទៃចូលទៅទទួលទោសជាប់ពន្ធនាគារជំនួសអោយជននោះបានទេ។ សូម្បីតែការបង់ប្រាក់ពិន័យ ក៏ច្បាប់មិនអនុញ្ញាតអោយអ្នកដទៃទៅបង់ប្រាក់ជំនួសដែរ ព្រោះគោលបំណងនៃទោសព្រហ្មទណ្ឌ គឺមានគោលដៅធ្វើអោយជននោះខ្លាចរអានិងដើម្បីបង្ការដល់សណ្តាប់ធ្នាប់ដល់សាធារណះជន។ ដូច្នេះការដាក់ទណ្ឌកម្មគោលបំណង គឺធ្វើអោយទណ្ឌិតមានអារម្មណ៍មួយទទួលរងថាអ្វីដែលគាត់ប្រព្រឹត្តគឺខុស ហើយនៅពេលដែលខុសនោះ ថាគាត់ត្រូវបានទទួលនូវផលវិបាកអ្វីខ្លះចំពោះខ្លួនឯងផ្ទាល់នូវអំពើរបស់ខ្លួនដែលប្រព្រឹត្តនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺមានចែងយ៉ាងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌចំពោះបុគ្គលដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖ ជាមនុស្ស កំពុងមានជីវិត សមត្ថភាពទទួលខុសត្រូវ ករណីប្រធានស័ក្ត។ ហើយចំពោះបុគ្គលនោះក្រមព្រហ្មទណ្ឌត្រូវបានបែងចែកជាពីរធំៗគឺ៖ រូបវន្តបុគ្គល និងនីតិបុគ្គល។

---

[6] ដកស្រង់ចេញពីសៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរាងដោយលោក ផេង គឹមស៊្រុន

[7] មាត្រា ២៤នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

### ២.១.១. រូបវ័ន្តបុគ្គល

យោងតាមក្រមព្រហ្មទណ្ឌរូបវ័ន្តបុគ្គលដែលទទួលខុសត្រូវព្រហ្មទណ្ឌមានឋានៈដូចជា៖ ចារី សហចារី អ្នកផ្ដើមគំនិត និងអ្នកសមគំនិត។

#### ២.១.១.១. ចារី

ជនដែលត្រូវបានចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកចំពោះបទមជ្ឈិម[8]ដូចជា ឈ្មោះ(ក)បានសម្លាប់ឈ្មោះ(ខ)ដោយផ្ទាល់ដៃដោយការបាញ់កាំភ្លើងជាច្រើនគ្រាប់ ឈ្មោះ(ក)ត្រូវបានគេហៅថា គឺជាចារីនៃបទល្មើសនោះ។

#### ២.១.១.២. សហចារី

ជនដែលត្រូវបានចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ ហើយក៏ត្រូវបានចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក[9]ដូចជា ឈ្មោះ(ក)ជាអ្នកឆក់ខ្សែរកពី ឈ្មោះ(គ)បានសម្រេចដោយអោយ ឈ្មោះ(ខ)ជាអ្នកបើកម៉ូតូដឹក ឈ្មោះ(ក)នោះអោយធ្វើនូវសកម្មភាពឆក់ខ្សែរកពីឈ្មោះ(គ)។ ដូច្នេះ ឈ្មោះ(ក)និង ឈ្មោះ(ខ)ត្រូវបានហៅថាគឺជាសហចារីនៃបទល្មើស។

#### ២.១.១.៣. អ្នកផ្ដើមគំនិត

ជនដែលត្រូវចាត់ទុកជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែល៖

- ជំរុញអោយប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះតាមការណែនាំឬការបញ្ជា។
- បង្កអោយមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្ដល់អំណោយដោយការសន្យា ឬការគំរាមកំហែងការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញាឬអំណាចរបស់ខ្លួន។ អ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋឬបទមជ្ឈិមត្រូវផ្ដន្ទាទោសដូចគ្នា និងចារីដែរ។ ប៉ុន្តែលុះត្រាបទល្មើសនោះបានសម្រេច ឬបានប៉ុនប៉ង[10]។ មូលហេតុនេះ គឺដើម្បីអោយអ្នកផ្ដើមគំនិតមានទោសលុះត្រាតែ៖

➢ ***អំពើចម្បងនោះមានទោស***៖បទឧក្រិដ្ឋ ឬបទមជ្ឈិមបានសម្រេច ឬត្រូវបានប៉ុនប៉ងដូចជា ក្នុងករណី ឈ្មោះ(ក)បានបញ្ជាអោយ ឈ្មោះ(ខ)ទៅសម្លាប់ ឈ្មោះ(គ)។ ប្រសិនបើ ឈ្មោះ(ខ)នោះមិនសម្លាប់ ឈ្មោះ(គ)ទេនោះ គឺមានន័យថាអំពើចម្បងនោះពុំមានទោសទេពីព្រោះថាពុំមានបទល្មើស

---

[8] មាត្រា ២៥នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩
[9] មាត្រា ២៦នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩
[10] មាត្រា ២៨នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

កើតឡើង។ ដូច្នេះអ្នកផ្ដើមគំនិតក៏ពុំមានទោសដែរ ក្នុងករណីនេះអំពើរបស់ឈ្មោះ "ក"ពុំមែនជាការផ្ដើមគំនិតដែលអាចផ្ដន្ទាទោសបានទេ ប៉ុន្តែអំពើនេះអាចត្រូវផ្ដន្ទាទោសក្រោមឈ្មោះបទល្មើសមួយផ្សេងទៀត គឺជាបទញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែទៅដល់ ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀលទៅ ៤លានរៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ[11]។

- ***ធាតុផ្សំសត្យានុម័តនៃការផ្ដើមគំនិត៖*** សំដៅលើការជំរុញតាមការណែនាំឬបញ្ជា ការបង្កដោយផ្ដល់អំណោយដោយការសន្យាឬដោយការគំរាមកំហែង ការញុះញង់ ការលួងលោម ឬដោយការរំលោភអាជ្ញាឬអំណាចរបស់ខ្លួន។
- ***ធាតុផ្សំអន្តោម័តនៃការផ្ដើមគំនិត៖*** អ្នកផ្ដើមគំនិតមានបំណងប្រព្រឹត្តអំពើផ្ដើមគំនិត គឺមានន័យថាអ្នកផ្ដើមគំនិតដឹងថាអំពើរបស់ចារីជាបទល្មើសហើយខ្លួននៅតែមានចេតនាផ្ដើមគំនិតអោយបទល្មើសនោះអាចកើតមានឡើងទៀត។

**២.១.១.៤. អ្នកសមគំនិត**

ជនដែលត្រូវបានចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋឬបទមជ្ឈិមនោះដោយផ្ដល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិត នឹងអាចត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬប៉ុនប៉ង។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្ដន្ទាទោសដូចគ្នានិងចារីដែរ[12]។ ក្នុងលក្ខណះប្រហាក់ប្រហែលគ្នានិងការផ្ដើមគំនិតដែលការសមគំនិតត្រូវបំពេញលក្ខណះបីយ៉ាងដើម្បីអោយមានទោសគឺ៖

- ***អំពើចម្បងនោះមានទោស៖*** បទឧក្រិដ្ឋ ឬបទមជ្ឈិមបានសម្រេច ឬត្រូវបានប៉ុនប៉ង។
- ***ធាតុផ្សំសត្យានុម័តនៃអ្នកសមគំនិត៖*** សំដៅទៅលើការផ្ដល់ជំនួយ ឬការឧបត្ថម្ភដូចជា ក្នុងករណីការផ្ដល់ជាម៉ូតូ ឬក៏សម្ភារះមួយចំនួនសំរាប់ឆ្កឹះសោរអោយចារីយកទៅប្រើប្រាស់ជាមធ្យោបាយក្នុងការប្រព្រឹត្តអំពើលួចគាស់ផ្ទះគេយកទ្រព្យសម្បត្តិអ្នកដទៃជាដើម។
- ***ធាតុផ្សំអន្តោម័តនៃអ្នកសមគំនិត៖*** អ្នកសមគំនិតដឹងថាអំពើរបស់ចារីជាបទល្មើសហើយ ខ្លួននៅតែមានចេតនាផ្ដល់ជំនួយ ឬឧបត្ថម្ភទៀតដូចជា ក្នុងករណី ឈ្មោះ(ក)បានអោយរថយន្ត ឈ្មោះ(ខ) ប្រើហើយ ឈ្មោះ(ខ)ដោយបានយករថយន្តនេះទៅប្រើប្រាស់ដើម្បីធ្វើជាមធ្យោបាយក្នុងការប្រព្រឹត្ត

[11] មាត្រា ៤៩៥នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[12] មាត្រា ២៩នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

អំពើលួច។ ប៉ុន្តែក្នុងករណីដែល ឈ្មោះ(ក)ពុំបានដឹងថា ឈ្មោះ(ខ)និងយករថយន្តរបស់ខ្លួនទៅប្រើប្រាស់ប្រព្រឹត្តបទល្មើសនោះទេ ឈ្មោះ(ក)មិនអាចមានទោសពីការសមគំនិតបានឡើយ ពីព្រោះពុំមានធាតុអត្តនោម័ត។

❖ **សម្គាល់៖** ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈឹមអាចត្រូវផ្តន្ទាទោសបានកាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ៖

- ចារីបានចាប់ផ្តើមអនុវត្តបទល្មើសគឺមានន័យថាចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស។
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្តតែត្រូវបានរាំងស្ទះឬអាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។ ហើយចំពោះអំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមអនុវត្តទេ។ ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទលហុពុំទទួលការផ្តន្ទាទោសទេ។

### ២.១.២. បុគ្គលនីតិបុគ្គល

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល មិនចោទជាចម្ងល់ឡើយនាពេលបច្ចុប្បន្ននេះ។ ប៉ុន្តែសព្វថ្ងៃនេះការវិវត្តន៏នៃច្បាប់ព្រហ្មទណ្ឌបានឈានដល់ដំណាក់កាលមួយ ដោយអោយមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលចំពោះទង្វើរបស់ខ្លួន។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងពីលក្ខខណ្ឌទូទៅនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល និងទោសដែលត្រូវអនុវត្តលើនីតិបុគ្គលនោះ។ នីតិបុគ្គល គឺជាក្រុមមនុស្សឬមូលនិធិដែលមានបុគ្គលភាពគតិយុត្តិ(ភាពជាបុគ្គលមានសិទ្ធ និងកាតព្វកិច្ចហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចដូចជា រដ្ឋ ឃុំ/សង្កាត់ ក្រុមហ៊ុន សមាគម សហគ្រាសជាដើម។ ក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តិផ្សេងទៀតនីតិបុគ្គលត្រូវបានលើកលែងតែរដ្ឋចេញ គ្រៅពីនេះគឺអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ហើយចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលមិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ[13]។

## ២.២. ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

អនីតិជនអាយុក្រោម ១៤ឆ្នាំមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ[14]។ ទោះបីជារកឃើញថាបានប្រព្រឹត្តនូវបទល្មើសក៏ដោយ ក៏ការទទួលខុសត្រូវព្រហ្មទណ្ឌលែងមានទោសទៅវិញក្នុងករណីដែលច្បាប់បានចែង។

[13] មាត្រា ៤២នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[14] មាត្រា ៣៩នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

### ២.២.១. វិបល្លាសស្មារតី

វិបល្លាសស្មារតី គឺសំដៅទៅលើវិបត្តិដែលធ្វើឲ្យមាននូវភាពរឹករវដល់សកម្មភាពនៃសរសៃប្រសាទរបស់មនុស្សដែលធ្វើអោយមនុស្សបាត់បង់ដឹងខុសត្រូវរបស់ខ្លួនជននោះ មិនតម្រូវអោយទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ដោយសារតែប្រព័ន្ធសរសៃប្រសាទមានសកម្មភាពមិនប្រក្រតី ចារីបានបាត់បង់នូវលទ្ធភាពការយល់ដឹងពីពិភពខាងក្រៅជុំវិញខ្លួន ហើយពុំអាចត្រួតពិនិត្យសកម្មភាពរបស់ខ្លួនបាន។ ហើយដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌគេត្រូវរកភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃភាពវិបល្លាសស្មារតីដែលកើតមានចំពោះចារីនូវពេលប្រព្រឹត្តអំពើល្មើស។ ជាទូទៅភស្តុតាងនៃវិបល្លាសស្មារតីត្រូវបានបញ្ជាក់ដោយវេជ្ជបណ្ឌិតជំនាញ ប៉ុន្តែគំនិតយោបល់ទាំងនោះពុំមានអានុភាពចងជាកាតព្វកិច្ចអោយចៅក្រមត្រូវតែជឿនោះទេ ពោលគឺចៅក្រមអាចជឿក៏បានឬមិនជឿក៏បានដូចជា ជនម្នាក់បានប្រើប្រាស់គ្រឿងញៀន ឬថ្នាំសម្រើបបណ្តាលអោយមានការលំបាកក្នុងការទប់ស្កាត់កាមតណ្ហារបស់ខ្លួន ហើយក៏ទៅរំលោភសេពសន្ថវៈនារីនៅក្បែរបន្ទប់ដែលខ្លួនរស់នៅនោះ។ ជនល្មើសមិនអាចលើកសំអាងហេតុពីការប្រើប្រាស់ថ្នាំសម្រើប ឬគ្រឿងញៀនធ្វើអោយខ្លួនមិនអាចគ្រប់គ្រងខ្លួនឯងបានដើម្បីអោយរួចផុតពីកាទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ[15]។

### ២.២.២. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

ក្នុងករណីខ្លះ ច្បាប់អនុញ្ញាតអោយប្រព្រឹត្តអំពើណាមួយបាន។ ប្រសិនបើបុគ្គលដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុវត្តតាមច្បាប់អនុញ្ញាត បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ[16]។

- ការឃាត់ខ្លួនជនសង្ស័យដោយមន្ត្រីនគរបាលយុត្តិធម៌
- ការចាប់ខ្លួនជនប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែងដោយប្រជាពលរដ្ឋ
- ការវះកាត់ដោយគ្រូពេទ្យទៅលើអ្នកជំងឺ ជួនកាលទំនៀមទម្លាប់របស់ប្រទេសតម្រូវមិនឲ្យចាត់ទុកអំពើណាមួយថាជាបទល្មើសទេ។
- ការបញ្ជារបស់អាជ្ញាធរ គឺជាយុត្តិកម្ម(ការធ្វើឲ្យត្រឹមត្រូវតាមច្បាប់)នៃបទល្មើសលុះត្រាតែអាជ្ញាធរដែលបញ្ជា គឺជាអាជ្ញាធរស្របច្បាប់។ ការបញ្ជាពីនយោជក ឬឪពុកម្តាយមិនមែនជាការបញ្ជាពីអាជ្ញាធរស្របច្បាប់ទេ។
- ការបញ្ជាមានលក្ខណៈនីត្យានុកូល គឺប្រសិនបើការបញ្ជាមានលក្ខណៈខុសច្បាប់យ៉ាងជាក់ច្បាស់ ក្រមព្រហ្មទណ្ឌតម្រូវអោយអ្នកទទួលបញ្ជាអនីត្យានុកូលទទួលទោសតាមបញ្ញត្តិច្បាប់។ ការវាយតម្លៃកំណត់ថាការបញ្ជាណាជាអនីត្យានុកូលអាស្រ័យទៅលើសមត្ថភាពបទពិសោធន៍ និងឋានៈរបស់អ្នក

[15] មាត្រា ៣១នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩
[16] មាត្រា ៣២នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

ទទួលបញ្ជាដូចជា ក្នុងករណីការបញ្ជាអោយធ្វើទារុណកម្ម ការបញ្ជាអោយបាញ់សម្លាប់ជនដែលមានវិវាទជាមួយនៅក្នុងគ្រោះថ្នាក់ចរាចរណ៍ជាដើម។

ជាករណីលើកលែងទោះបីជាច្បាប់ជាធរមានអនុញ្ញាត ឬមានបញ្ជារបស់អាជ្ញាធរស្របច្បាប់ក៏ដោយក៏មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដែរកាលបើអំពើប្រព្រឹត្តនេះជាបទឧក្រិដ្ឋប្រឆាំងនិងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម ឬបទប្រល័យពូជសាសន៏។ ទោះបីជាច្បាប់ជាធរមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានអនុញ្ញាតអោយមានការសម្លាប់មនុស្សដូចក្នុងសម័យកាលនោះក្តី ក៏ជនទាំងឡាយដែលធ្វើតាមការអនុញ្ញាតដោយច្បាប់នោះ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដោយលើកសំអាងពីការអនុញ្ញាតដោយច្បាប់បានឡើយ។

### ២.២.៣. ការការពារស្របច្បាប់

ការការពារស្របច្បាប់ដោយមិនអោយបុគ្គលណាប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ដោយមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ហើយចំពោះលក្ខខណ្ឌការការពារស្របច្បាប់នោះមានដូចជា៖

- បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការការពារអ្នកដទៃឬការពារទ្រព្យសម្បត្តិប្រឈមមុខ និងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង
- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ នឹងទម្ងន់នៃការឈ្លានពាន[17]។

ក្នុងករណីសកម្មភាពដែលមិនមែនជាការការពារស្របច្បាប់ដូចជា ករណីមួយបន្ទាប់ពីមានការទាស់ទែងគ្នាជាមួយបុរសម្នាក់ហើយក្រោយមកឃើញបុរសនោះកំពុងដើរកម្សាន្តមុំផ្ទះខ្លួន ម្ចាស់ផ្ទះក៏វាយបុរសនោះតែម្តងព្រោះភ័យខ្លាចមានការវាយប្រហារលើខ្លួនជាមុនដែលតាមការពិតបុរសជាជនរងគ្រោះនោះ ពុំទាន់ទាំងមានសកម្មភាពហិង្សាណាមួយទាល់តែសោះ។ ដូច្នេះក្នុងករណីនេះ ត្រូវបានចាត់ទុកថាការការពារស្របច្បាប់ទេ គឺត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។

### ២.២.៤. សច្ចាធារណ៍ នៃការការពារស្របច្បាប់

ត្រូវសន្មត់ថាជាការការពារស្របច្បាប់នូវក្នុងករណីដូចជា៖

- បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ដោយការកាប់គាស់ទម្លុះទម្លាយដោយហឹង្សាឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សរស់នៅ។
- បទល្មើសបានប្រព្រឹត្តដើម្បីការការពារខ្លួនប្រឆាំងនិងការលួចឬការប្លន់ដែលអនុវត្តដោយហិង្សា។

[17] មាត្រា ៣៣នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

សច្ចាធារណ៍នៃការការពារស្របច្បាប់ពុំមានលក្ខណៈដាច់ខាតទេ។ សច្ចាធារណ៍នេះអាចត្រូវរំលាយដោយភស្តុតាងផ្ទុយ[18]។

### ២.២.៥. ស្ថានភាពចាំបាច់

ស្ថានភាពចាំបាច់ជាស្ថានភាពរបស់បុគ្គលម្នាក់ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយដោយសារចារីមានបំណងស្ការផលប្រយោជន៍មួយផ្សេងទៀតដែលត្រូវបានគំរាមគំហែងដោយមហន្តរាយបច្ចុប្បន្នឬជៀបនិងការកើតឡើង។ ក្រមព្រហ្មទណ្ឌចែងថាបុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខណៈដូចខាងក្រោម៖

- បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការការពារខ្លួន ការពារអ្នកដទៃឬការពារទ្រព្យសម្បត្តិប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមានឬដែលនឹងកើតមាន និង
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនឹងទម្ងន់នៃគ្រោះថ្នាក់[19]។
- ដើម្បីកុំអោយកូនអត់អាហារស្លាប់ ម្តាយសុខចិត្តលួចបាយរបស់គេដើម្បីចិញ្ចឹមកូន។
- ដើម្បីបញ្ចៀសកុំអោយឡានខ្លួនត្រូវភ្លើងឆេះអស់ បុរសម្នាក់រត់ទៅយកបំពងពន្លត់អគ្គីភ័យរបស់អ្នកដទៃមកពន្លត់ដោយគ្មានការអនុញ្ញាត។
- ដើម្បីបញ្ចៀសកុំអោយគេឃើញខ្លួនស្រាតនននលគ្មានខោអាវនារីម្នាក់បង្ខំចិត្តលួចខោអាវគេមកបិតបាំងរាងកាយខ្លួន។

### ២.២.៦. អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំងឬការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បានទេ បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំងនិងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំងនិងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន[20]។ ប៉ុន្តែក្នុងករណីមានភស្តុតាងមានកំលាំងអ្វីមួយបានបង្ខំជនណាម្នាក់អោយប្រព្រឹត្តបទល្មើសអ្វីមួយ ហើយជននោះកាលមិនអាចទប់ទល់និងកំលាំងនោះបានទេ ក៏ប្រព្រឹត្តបទល្មើសនោះ។ ដូច្នេះជនប្រព្រឹត្តបទល្មើសនេះមិនត្រូវអោយទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឡើយ។ ហើយកម្លាំងនិងការបង្ខំនេះត្រូវតែកើតចេញពីករណីប្រធានសក្តិដូចជា កម្លាំងធម្មជាតិរន្ទះបាញ់កង់ឡានបណ្តាលអោយអ្នកបើកបរកិនអ្នកថ្មើរជើងម្នាក់ស្លាប់[21]។

[18] មាត្រា ៣៤នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[19] មាត្រា ៣៥នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[20] មាត្រា ៣៦នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[21] មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បកស្រាយដោយឯ.ឧ ហ៊ី សោភា,ប៊ុន ហ៊ុន,កើត រិទ្ធ,ផូវ សំភី,លោកស្រី ចាំង ស៊ីណាត ឆ្នាំ២០១១

❖ **<u>សំគាល់៖</u>** ក្នុងករណីអភ័យឯកសិទ្ធគ្រួសារ មិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបានទេ៖

- អំពើមិនអាចលួចទ្រព្យសម្បត្តិរបស់បុព្វញាតិឬបច្ឆាញាតិ។
- អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ[22]។

## ផ្នែកទី៣៖ ទោសព្រហ្មទណ្ឌ

ទោសព្រហ្មទណ្ឌ គឺសំដៅទៅលើទណ្ឌកម្មដែលត្រូវបានប្រកាសដោយតុលាការសម្រាប់ការអនុវត្តចំពោះបុគ្គលដែលមានបានប្រព្រឹត្តបទល្មើស។ ហើយវាមានលក្ខណៈសំខាន់ណាស់សំរាប់បទល្មើសព្រោះវាកំណត់ពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ។ ម្យ៉ាងទៀត ដោយផ្អែកទៅលើគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោសចៅក្រមអាចប្រកាសតែទោសណាដែលច្បាប់កំណត់តែប៉ុណ្ណោះ។ ចំពោះទោសព្រហ្មទណ្ឌ គឺជាទណ្ឌកម្មផ្តន្ទាទោសដោយសង្គមតាមរយៈច្បាប់ទៅលើជនណាដែលប្រព្រឹត្តបទល្មើស។ ហើយទោសព្រហ្មទណ្ឌទៀបសោត គឺក្នុងគោលដៅការពារប្រយោជន៍សាធារណៈដែលជាប្រយោជន៍របស់សង្គមទាំងមូល។ ហើយបើយោងតាមក្រមព្រហ្មទណ្ឌបានបែងចែកទោសព្រហ្មទណ្ឌជា ៣(បី)ប្រភេទគឺ៖ មូលទោស អនុទោស ទោសជំនួស។

### ៣.១ មូលទោស

មូលទោស គឺជាទោសមូលដ្ឋានដែលយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ ហើយគ្រប់បទល្មើសទាំងអស់សុទ្ធតែត្រូវផ្តន្ទាទោសយ៉ាងហោចណាស់ក៏មានមូលទោសមួយដែរ ព្រោះជាទោសមួយដ៏ចាំបាច់សំរាប់ភ្ជាប់ទៅ និងបទល្មើស។ ហើយតាមរយៈបញ្ញត្តិនៃក្រមព្រហ្មទណ្ឌចែងថា មូលទោសមាន ២(ពីរ)ប្រភេទគឺ៖

- ទោសដាក់ពន្ធនាគារ៖ គឺជាទោសដាក់គុកនិងដកហូតសេរីភាពរបស់បុគ្គលដែលប្រព្រឹត្តបទល្មើស ក្នុងរយៈពេលកំណត់មួយនៅក្នុងពន្ធនាគារ។
- ទោសពិន័យជាប្រាក់៖ គឺជាទោសដែលតម្រូវអោយបុគ្គលដែលប្រព្រឹត្តបទល្មើសបង់ប្រាក់ពិន័យនូវចំនួនកំណត់មួយ ហើយត្រូវគិតជាប្រាក់រៀល។ ហើយប្រាក់ពិន័យដែលទទួលបានត្រូវបង់ចូលជាថវិកាជាតិដោយត្រូវយកទៅទុកនៅក្នុងរតនាគារជាតិ[23]។

### ៣.២. អនុទោស(ទោសបន្ថែម)

អនុទោស គឺជាទោសបន្ថែមឬជាទោសបន្ទាប់បន្សំដែលសំដៅដល់ទោសដែលត្រូវបញ្ចូលបន្ថែមទៅក្នុងមូលទោស។ ការដាក់បញ្ចូលទៅក្នុងមូលទោសនេះសំដៅដល់ការបន្ថែមលើមូលទោស ដើម្បីបង្ការការប្រព្រឹត្ត

[22] មាត្រា ៣៥៥នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩
[23] មាត្រា ៤៣នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

បទល្មើសជាថ្មី។ ទោសបន្ថែមបង្កើតឡើងក្នុងគោលបំណងអោយការដាក់ទណ្ឌកម្មមានកម្រិតសមស្របទៅនឹងអំពើល្មើសដែលបានប្រព្រឹត្ត ឬនិយាយម្យ៉ាងទៀតថា ដើម្បីធានាដល់ការអនុវត្តគោលការណ៍ឯកត្តកម្មនៃទោស។

### ៣.៣. ទោសជំនួស

ទោសជំនួស គឺជាទោសដែលត្រូវប្រកាសជំនួសមូលទោសនិងសម្រាប់អនុវត្តជំនួសមូលទោសចំពោះការប្រព្រឹត្តបទល្មើសណាមួយ។ ទោសជំនួសត្រូវបានចែកជា ២(ពីរ)គឺៈទោសការងារសហាគមន៍ ទោសស្តីបន្ទោស។

- **ទោសការងារសហាគមន៍ៈ** តុលាការអាចប្រកាសទោសការងារសហាគមន៍បានកាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរិមាតិចជាង ឬស្មើនឹង ៣(បី)ឆ្នាំ។ ហើយការងារសហាគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០(សាមសិប)ម៉ោងទៅ ២០០(ពីររយ)ម៉ោងនូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀតដល់សមាគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល[24]។

បែបបទនៃការអនុវត្តទោសការងារសហាគមន៍ត្រូវកំណត់ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ។ ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។

- **ទោសស្តីបន្ទោសៈ** គឺជាប្រភេទនៃទោសមួយដែលមានគោលបំណងបន្ធូរបន្ថយដល់ការទទួលទណ្ឌកម្មមកត្រឹមជាការស្តីបន្ទោសប៉ុណ្ណោះ ចំពោះទណ្ឌិតដែលបានប្រព្រឹត្តបទល្មើសដែលពុំមានលក្ខណៈធ្ងន់ធ្ងរ។ ហើយទោសប្រភេទនេះក៏មិនខុសពីប្រភេទទោសដទៃផងដែរ គឺបង្កើតឡើងក្នុងគោលបំណងដាក់ទណ្ឌកម្មដល់ទណ្ឌិតអោយសមស្របទៅនឹងទម្ងន់នៃបទល្មើស។

❖ ***<u>សំគាល់ៈ</u>*** ចំពោះគោលការណ៍ខាងក្រោមនេះមិនទាន់ឃើញមានការអនុវត្តនូវឡើយទេ ដូចជាៈ

  ➢ ទោសពាក់កណ្តាលសេរីភាព គឺកាលណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើរនិង ៦(ប្រាំមួយ)ខែតុលាការអាចសម្រេចថាទោសត្រូវអនុវត្តក្រោមពាក់កណ្តាលសេរីភាព ដើម្បីអនុញ្ញាតឲ្យទណ្ឌិតអាចបំពេញសកម្មភាពលើវិជ្ជាជីវៈ ទទួលបានការសិក្សា ឬការបណ្តុះបណ្តាល ឬការពិនិត្យព្យាបាលជម្ងឺ ឬជួយឧបត្ថម្ភដល់សេចក្តីតម្រូវការរបស់គ្រួសារ[25]។

---

[24] មាត្រា ៧២នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[25] មាត្រា ១២៧នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

- ទោសបែងចែកជាប្រភាគ គឺជាទោសកាលណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើរ ១(មួយ)ឆ្នាំតុលាការអាចសម្រេចថា ទោសនេះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណះជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម[26]។

[26] មាត្រា ១៣២នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

# ជំពូកទី២
# ដំណើរការរឿងក្តីព្រហ្មទណ្ឌ
## ផ្នែកទី១៖ ភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ

ជាធម្មតាភាគីក្នុងរឿងក្តីព្រហ្មទណ្ឌយ៉ាងហោចណាស់មាន គឺមានម្ចាស់បណ្តឹងអាជ្ញា ជនល្មើស ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

### ១.១. ជនល្មើស

ក្នុងដំណាក់កាលដំបូងនៃនីតិវិធីនូវពេលដែលជនម្នាក់ ត្រូវបានឃាត់ខ្លួនដោយនគរបាលយុត្តិធម៌ គេហៅថា "**ជនសង្ស័យ**"ក្នុងករណីបទល្មើសមិនជាក់ស្តែង ឬគេអាចហៅថា "**ជនល្មើស**"តែម្តងក្នុងករណីបទល្មើសជាក់ស្តែង។ បន្ទាប់ពីនគរបាលយុត្តិធម៌បញ្ជូនសំណុំរឿងទៅដល់ក្នុងដំណាក់កាលស្ថាប័នអយ្យការ ព្រះរាជអាជ្ញា បានចាប់ផ្តើមធ្វើការចោទប្រកាន់នោះ ជនសង្ស័យឬជនល្មើសត្រូវបានគេហៅថា "**ជនត្រូវចោទ**"។ ហើយបន្ទាប់មកព្រះរាជអាជ្ញាបញ្ជូនជនត្រូវចោទទៅដល់ក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរចាប់ផ្តើមពិនិត្យស្វែងរកការពិតរួចហើយក៏ចោទប្រកាន់ជនត្រូវចោទនោះ ត្រូវបានគេហៅថា "**ជនជាប់ចោទ**"។ បន្ទាប់មកទៀតជនជាប់ចោទនោះ ត្រូវបានបញ្ជូនបន្តមកដល់ក្នុងដំណាក់កាលចៅក្រមជំនុំជម្រះ ចៅក្រមជំនុំជម្រះចាប់ផ្តើមធ្វើការជំនុំជម្រះលើជនជាប់ចោទនោះក្រោយមកចៅក្រមជំនុំជម្រះចេញសេចក្តីសម្រេចផ្តន្ទាទោសជនជាប់ចោទនោះ ហើយជនជាប់ចោទនោះត្រូវបានគេហៅថា "**ពិរុទ្ធជន**"។ ប្រសិនបើពិរុទ្ធជននេះបន្តប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍ ឬប្តឹងសាទុក្ខលើសេចក្តីសម្រេចផ្តន្ទាទោសលើរូបខ្លួនគេហៅថា ជនជាប់ចោទវិញ ហើយមាននូវសេចក្តីសម្រេចផ្តន្ទាទោសម្តងទៀតលើជនជាប់ចោទនោះគេហៅថា ជនជាប់ចោទវិញ រហូតដល់សេចក្តីសម្រេចផ្តន្ទាទោសចូលជាស្ថាពរនោះ ជនជាប់ចោទឬពិរុទ្ធជននោះ ត្រូវគេហៅថា "**ទណ្ឌិត**"[27]។

### ១.២. ជនរងគ្រោះ

ជនរងគ្រោះ គឺជាបុគ្គលដែលរងគ្រោះដោយផ្ទាល់ ពីអំពើល្មើសរបស់ជនល្មើសដែលប្រព្រឹត្តបទល្មើស។ ការខូចខាតដែលជនរងគ្រោះអ្នកទទួលរងវិព្យសនកម្ម គឺអាចជាវិព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬខាងផ្លូវចិត្តជាដើម។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌអ្នកមានសិទ្ធិធ្វើការបណ្តឹងដើម្បីទាមទារវិព្យសនកម្មនោះបានមានដូចជា អាណាព្យាបាលស្របច្បាប់របស់ជនរងគ្រោះ សមាគមដែលទទួលសិទ្ធិពីជនរងគ្រោះ ឬទាយាទរបស់មរណជន។ ហើយវិព្យសនកម្មអាចត្រូវបានជួសជុសដោយការសងជម្ងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ឬដោយការបដិទាន(ធ្វើអោយដូចសភាពដើមវិញ)នូវទ្រព្យសម្បត្តិ ដែលគេ

[27] សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៥

បានបំផ្លាញឬធ្វើអោយខូចខាត។ សំណងជម្ងឺចិត្តត្រូវមានលក្ខណៈធន់ល្មមជាមួយ និងវិព្យសនកម្មដែលបានទទួលរង។

**១.៣. ដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណី មានក្នុងរឿងក្តីព្រហ្មទណ្ឌនៅពេលដែលជនរងគ្រោះនៃរឿងក្តីនោះជាអនីតិជន ឬជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅឬជនស្ថិតក្រោមហិតូបត្ថម្ភ ដែលត្រូវតម្រូវចាំបាច់អោយអ្នកមានសិទ្ធិគ្រប់គ្រងទៅលើជនរងគ្រោះដែលជាអនីតិជន។ ជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅ ឬជនស្ថិតក្រោមហិតូបត្ថម្ភ ឬសិទ្ធិវន្តរបស់ជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងរដ្ឋប្បវេណីពីជនល្មើសដែលជនរងគ្រោះបានទទួលរងនូវការខូចខាត ទោះបីជាការខូចខាតនេះជាវិព្យសនកម្មផ្លូវចិត្តក៏ដោយ។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើឡើងក្នុងនាមផលប្រយោជន៍របស់ជនរងគ្រោះ និងអាចធ្វើនូវពេលណាក៏បាន ដរាបណាចៅក្រមមិនទាន់សម្រេចលើអង្គសេចក្តី។

**១.៤. អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី**

អ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺជាជនទាំងឡាយណាដែលច្បាប់តម្រូវអោយទទួលខុសត្រូវអំពើរបស់អ្នកដែលបង្កទៅលើអ្នកដទៃ ដែលជាជនជាប់ចោទក្នុងនីតិវិធីព្រហ្មទណ្ឌ។ អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី គឺជាអ្នកផ្តល់ចម្លើយនៃបណ្តឹងរដ្ឋប្បវេណីរួមមាន៖

- ឪពុកម្តាយ អាណាព្យាបាល
- និយោជក
- ក្រុមហ៊ុនធានារ៉ាប់រង ក៏អាចត្រូវតុលាការកោះហៅឲ្យចូលរួមក្នុងរឿងក្តីព្រហ្មទណ្ឌដែរ ប្រសិនបើជនជាប់ចោទបានទិញការធានារ៉ាប់រងក្នុងការទទួលខុសត្រូវចំពោះករណីគ្រោះថ្នាក់ចរាចរណ៍ជាដើម។

**១.៥. តតិយជនផ្សេងទៀត**

ប្រសិនបើតុលាការអាចនិងផ្តន្ទាទោសដែលពាក់ព័ន្ធនិងវត្ថុណាមួយដូចជា ការបិទគ្រឹះស្ថានដែលជាទ្រព្យសម្បត្តិឯកជនដែលអាចប៉ះពាល់ផលប្រយោជន៍របស់តតិយជន ជននេះអាចបង្ហាញពីអំណះអំណាងផ្សេងៗដើម្បីការពារផលប្រយោជន៍របស់ខ្លួន[28]។

[28] មេរៀននីតិវិធីព្រហ្មទណ្ឌរៀបដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីចាត ឆ្នាំ២០១៥

## ផ្នែកទី២៖ នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ។ នគរបាលយុត្តិធម៌មានភារៈកិច្ចធ្វើការត្រួតពិនិត្យទៅលើបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដើម្បីកំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាងផងដែរ[29]។

### ២.១. សមាសភាពនគរបាលយុត្តិធម៌

ក្រមនីតិវិធីព្រហ្មទណ្ឌកំណត់អំពីសមាសភាពនគរបាលយុត្តិធម៌ដូចតទៅ៖

- មន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលយុត្តិធម៌
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកបានប្រគល់អំណាចអោយធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន[30]។

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ព្រះរាជអាជ្ញាមានអំណាចលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត កាលណាមន្ត្រីទាំងអស់បានបំពេញនូវមុខងាររបស់ខ្លួនជានគរបាលយុត្តិធម៌។ ម្យ៉ាងវិញទៀត កាលណាអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ក្រៅពីនេះ នគរបាលយុត្តិធម៌ក៏ត្រូវស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ផងដែរ ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌បាន[31]។ បន្ទាប់ពីមានការរាយការណ៍ពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរដល់អគ្គព្រះរាជអាជ្ញាប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីផ្តើមដំណើរការនីតិវិធី[32]។ ក្រៅពីនេះ អគ្គព្រះរាជអាជ្ញាក៏អាចចេញវិធានការវិន័យដោយផ្ទាល់ទៅលើមន្ត្រីនគរបាលយុត្តិធម៌ដែរ ក្នុងករណីបើមានកំហុសធ្ងន់ធ្ងរក្រោយពីកោះហៅមន្ត្រីនគរបាលយុត្តិធម៌នោះមកផ្តល់សេចក្តីសង្ខេបរួចមក។ សេចក្តីសម្រេចដាក់វិន័យអាចជា៖

- ហាមឃាត់មិនអោយបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំយ៉ាងច្រើនបំផុត។

---

[29] មាត្រា ៥៦នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[30] មាត្រា ៥៧នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[31] មាត្រា ៥៩នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[32] មាត្រា ៦៤នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

- ហាមឃាត់មិនអោយបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ។

ចំពោះសេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់មន្ត្រីក្រសួងមហាផ្ទៃឬក្រសួងការពារជាតិ។ សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅមន្ត្រីក្រសួងយុត្តិធម៌ក្នុងអំឡុងរយៈពេល ១៥(ដប់ប្រាំ)ដោយថ្ងៃគិតចាប់ពីថ្ងៃទទួលដំណឹងហើយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវសម្រេចក្នុងអំឡុងពេលយ៉ាងយូរបំផុត ១(មួយ)ខែគិតចាប់ពីថ្ងៃទទួលប្តឹង។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបដិសេធការហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់បាន។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពុំអាចប្តឹងតវ៉ាទៀតបានទេ[33]។

### ២.១.១. មន្ត្រីនគរបាលយុត្តិធម៌

សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌មានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌អាចទទួលបានតាមរបៀបពីរយ៉ាងគឺ៖

- តាមការប្រឡងសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌
- តាមមុខងារដដែល និងឋានន្តរស័ក្តរបស់មន្ត្រីនគរបាលយុត្តិធម៌តាមក្រមនីតិវិធីក្រមព្រហ្មទណ្ឌ មន្ត្រីនគរបាលម្នាក់ៗត្រូវស្បថនៅមុខសាលាឧទ្ធរណ៍[34]។

ក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់ថាមន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗត្រូវស្បថថាខ្លួននឹងបំពេញភក្តីភាពនូវមុខងាររបស់ខ្លួន។ ការសម្បថត្រូវធ្វើនៅមុខតុលាការឧទ្ធរណ៍[35]។

### ២.១.២. ភ្នាក់ងារនគរបាលយុត្តិធម៌

សមាសភាពភ្នាក់ងារនគរបាលយុត្តិធម៌ បានចែងកំណត់ថាភ្នាក់ងារនគរបាលយុត្តិធម៌ដែលមានគុណសម្បត្តិអាចជាភ្នាក់ងារនគរបាលយុត្តិធម៌ដូចជា៖

- នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។
- ភ្នាក់ងារនគរបាលជាតិផ្សេងៗទៀត។
- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។
- យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ[36]។

ក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងអំពីភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្បថថាបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។ ការសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើឡើងនៅសាលាដំបូង[37]។

---

[33] មាត្រា ៦៦នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[34] មាត្រា ៦០នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[35] មាត្រា ៦៣នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[36] មាត្រា ៧៦នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[37] មាត្រា ៧៧នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

### ២.១.៣. មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

ក្រមនីតិវិធីព្រហ្មទណ្ឌកំណត់អោយមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈប្រភេទនេះ គឺត្រូវស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងាររបស់ខ្លួនជានគរបាលយុត្តិធម៌។ ចំពោះបែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌និងក្រសួងពាក់ព័ន្ធ។ មន្ត្រីរាជការដូចជាខាងភ្នាក់ងារសាធារណៈដទៃទៀត ត្រូវស្បថនៅសាលាដំបូង។ មន្ត្រីរាជការនិងភ្នាក់ងារទាំងនេះ ត្រូវធ្វើរបាយការណ៍ ដែលមានតម្លៃត្រឹមតែជាពត៌មានធម្មតាប៉ុណ្ណោះ។ រាល់កំហុសក្នុងការបំពេញមុខងាររបស់ខ្លួនត្រូវអោយដំណឹងដល់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលបានប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬភ្នាក់ងារនោះនៅក្រោមឱវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ[38]។

## ២.២. សមត្ថកិច្ចនគរបាលយុត្តិធម៌

### ២.២.១. សមត្ថកិច្ចដែនដី

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗមានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីអង្គភាពដែលខ្លួនត្រូវបានចាត់តាំងអោយទៅបម្រើការងារ។ ការកំណត់មណ្ឌលរដ្ឋបាលដែលជាដែនដីសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌មានបញ្ជាក់នៅក្នុងសេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌នោះ។ ហេតុនេះមន្ត្រីនគរបាលដែលត្រូវបានចាត់តាំងអោយទៅ បម្រើការនៅស្រុកណាមួយនៃខេត្តណាមួយ មានសមត្ថកិច្ចដែនដីនៅស្រុកនោះប៉ុណ្ណោះ។ លើកលែងតែករណីគឺៈ

- នៅក្រុងភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចលើវិសាលភាពនៃក្រុងទាំងមូល។
- ការអនុញ្ញាតអោយបំពេញប្រតិបត្តិការនៅលើវិសាសភាពនៃដែនដីជាតិទាំងមូលដោយព្រះរាជអាជ្ញាជាលាយល័ក្ខណអក្សរ ឬដោយផ្ទាល់មាត់ ក្នុងករណីបទល្មើសជាក់ស្តែង។
- ការអនុញ្ញាតអោយបំពញប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូលដោយចៅក្រមស៊ើបសួរនៅក្នុងដីកាចាត់អោយស៊ើបសួរជំនួស[39]។

ក្នុងករណីដែលមានពន្លាតដែនដីសមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី[40]។

[38] មាត្រា ៨២នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[39] មាត្រា ៦៧នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[40] មាត្រា ៦៨នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

### ២.២.២. សមត្ថកិច្ចសម្ភារៈ

ក្រមនីតិវិធីព្រហ្មទណ្ឌ កងរាជអាវុធក៏ជានគរបាលយុត្តិធម៌ដែរ។ ដូច្នេះកងរាជអាវុធហត្ថអាចបំពេញមុខងារជានគរបាលយុត្តិធម៌នូវក្នុងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ។ ប៉ុន្តែចំពោះបទល្មើសយោធាមានតែកងរាជអាវុធហត្ថទេដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌[41]។

## ២.៣. បេសកម្មរបស់នគរបាលយុត្តិធម៌

ក្រមនីតិវិធីព្រហ្មទណ្ឌកំណត់បេសកម្មរបស់មន្ត្រីនគរបាលយុត្តធម៌ដូចជា៖

- ពិនិត្យមើលបទល្មើសជាអាទ៍ បទលហុ។
- ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់ខ្លួន។

ចំពោះការពិនិត្យមើលបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍។ របាយការណ៍នេះមានតម្លៃត្រឹមតែពត៌មានធម្មតាប៉ុណ្ណោះ។ ក្នុងករណីណាក៏ដោយភ្នាក់ងារនគរបាលយុត្តិធម៌ ពុំអាចបំពេញកិច្ចការទាំងឡាយដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌។ កិច្ចការទាំងឡាយដែលត្រូវបំពេញដោយបំពានលើការហាមឃាត់នេះត្រូវចាត់ទុកមោឃះ[42]។

### ២.៣.១. ការស៊ើបអង្កេតករណីជាក់ស្តែង

ការស៊ើបអង្កេតករណីជាក់ស្តែងត្រូវបើកក្នុងករណីឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង។ ចំពោះបទល្មើសជាក់ស្តែងជាបទល្មើសដែលកំពុងប្រព្រឹត្តបទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម និងបទល្មើសដែលកំពុងប្រព្រឹត្តិហើយចាត់ទុកជាបទល្មើសជាក់ស្តែង កាលណាក្រោយពេលមានបទល្មើសរួចបន្តិចមកជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកចាប់ប្រដាប់ប្រភីង ឬបុគ្គលដែលគេរកឃើញមានវត្ថុឬមានស្លាកស្នាមឬមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តិបទល្មើស[43]។ ក្នុងករណីដែលចាត់ទុកដូចជាបទល្មើសជាក់ស្តែងដែរ ទោះបីស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយគ្រប់បទឧក្រិដ្ឋ ឬមជ្ឈឹមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះសុំអោយព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។ ក្នុងករណីចុងក្រោយនេះភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។

[41] មាត្រា ៨១នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[42] មាត្រា ៧៨នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[43] មាត្រា ៨៦នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

**២.៣.១.១. ចុះទៅកាន់ទីកន្លែងកើតហេតុ**

ដើម្បីធ្វើការពិនិត្យលើបទល្មើស ក្រោយពីរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ហាមឃាត់បុគ្គលគ្រប់រូបកុំអោយទៅទីណាឆ្ងាយពីទីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការណ៍របស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។

**២.៣.១.២. ការឃាត់ខ្លួន**

ដើម្បីឆ្លើយតបនិងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនគ្រប់បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលនោះហើយនាំខ្លួនជននោះទៅជូនមន្ត្រីនគរបាលយុត្តិធម៌ដែលស្ថិតនៅជិតបំផុត។ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលជាប់ស័ង្សយថាបានចូលរួមក្នុងបទល្មើស និងបុគ្គលដែលអាចផ្តល់ពត៌មានស្តីអំពីរឿងហេតុ។ ក្នុងករណីការឃាត់ខ្លួនអាចធ្វើបានលុះត្រាតែបុគ្គលនោះប្រកែកមិនព្រមផ្តល់ពត៌មាននិងការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ហើយក្រោយពីការឃាត់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម[44]។ ចំពោះរយៈពេលនៃការឃាត់ខ្លួនគឺ ៤៨(សែសិបប្រាំបី)ម៉ោងគិតចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ការពន្យាពេលនៃការឃាត់ខ្លួន ២៤(ម្ភៃបួន)ម៉ោងទៀតអាចធ្វើបានលុះត្រាតែមានលក្ខខណ្ឌដូចតទៅៈ

- មានតម្រុយអោយឃើញពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួនជានីតិជន ក្នុងបទឧក្រិដ្ឋ។
- ការពន្យារពេលជាវិធានការចាំបាច់ ដើម្បីអោយការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។
- ការអនុញ្ញាតដោយព្រះរាជអាជ្ញា ជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។

ចំពោះការឃាត់ខ្លួនអនីតិជនអាចធ្វើបានចំពោះតែអនីតិជនអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំប៉ុណ្ណោះ ចំពោះអនីតិជនក្រោម ១៤(ដប់បួន)ឆ្នាំមិនអាចឃាត់ខ្លួនបានឡើយ។ រយៈពេលការឃាត់ខ្លួនចំពោះអនីតិជនប្រែប្រួលតាមប្រភេទនៃបទល្មើសៈ

➢ **<u>ចំពោះបទឧក្រិដ្ឋ</u>**

✓ អនីតិជនមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៦(ដប់ប្រាំមួយ)ឆ្នាំ គឺមិនហួសពី ៣៦(សាបសិបប្រាំមួយ)ម៉ោង។

✓ អនីតិជនដែលមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ គឺមិនហួសពី ៤៨(សែសិបប្រាំបី)ម៉ោង។

➢ **<u>ចំពោះបទមជ្ឈិម</u>**

[44] មាត្រា ៩៦នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

- ✓ អនីតិជនដែលមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ គឺមិនហួសពី ២៤ (ម្ភៃបួន)ម៉ោង។
- ✓ អនីតិជនដែលមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ គឺមិនហួសពី ៣៦ (សាបសិបប្រាំមួយ)ម៉ោង[45]។

ក្នុងរយៈពេលនៃការឃាត់ខ្លួនបុគ្គលដែលឃាត់ខ្លួនមានសិទ្ធិសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើសកុំអោយតែជននោះមានការទាក់ទិននូវក្នុងរឿងជាមួយនោះ។ ទំនាក់ទំនងនេះអាចធ្វើបានក្នុងរយៈពេល ៣០(សាបសិប)នាទី[46]។ ក្រៅពីនេះការទទួលជំនួយពីគ្រូពេទ្យក្នុងពេលឃាត់ខ្លួនក៏អាចធ្វើបានដែរតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌[47]។ សម្រាប់ការឃាត់ខ្លួនអនីតិជនមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនពត៌មានគ្រប់មធ្យោបាយដល់ ឪពុកម្តាយដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារៈកិច្ចលើអនីតិជននេះ[48]។

### ២.៣.១.៣. ការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរបានដោយទទួលបាននូវការអនុញ្ញាតពីព្រះរាជអាជ្ញាទោះបីជាលាយលក្ខណ៏អក្សរ ឬផ្ទាល់មាត់ក៏ដោយ។ ការឆែកឆេរត្រូវប្រព្រឹត្តទៅនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ ការឆែកឆេរមិនអាចចាប់ផ្តើមធ្វើមុនម៉ោង ៦(ប្រាំមួយ)ព្រឹកក្រោយម៉ោង ១៨(ដប់ប្រាំបី)ល្ងាចបានឡើយ។ ក្នុងករណីដែលឆែកឆេរត្រូវធ្វើនៅក្នុងការិយាល័យមេធាវីមន្ត្រីនគរបាលយុត្តិធម៌ពុំអាចធ្វើការឆែកឆេរបានឡើយមានតែព្រះរាជអាជ្ញាឬចៅក្រមស៊ើបសួរប៉ុណ្ណោះ ដែលអាចឆែកឆេរបានចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូប្រធានគណៈមេធាវី ឬមេធាវីសាមី។ ចំពោះអាគារសារពត៌មាន មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន តែត្រូវធ្វើនៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ដែលធានារ៉ាប់រងកុំអោយការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរជាអ្នកសារពត៌មាននិងធ្វើអោយយឺតយ៉ាវដល់ការផ្សព្វផ្សាយពត៌មាននេះដោយមិនត្រឹមត្រូវ[49]។

### ២.៣.១.៤. ការចាប់យកវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌អាចចាប់យកវត្ថុតាងបាន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ។ ក្រោយពីបាននូវបង្ហាញវត្ថុតាងដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើល

---

[45] មាត្រា ៨៧នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[46] មាត្រា ៩៨នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[47] មាត្រា ៩៩នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[48] មាត្រា ១០០នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[49] មាត្រា ៩១នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

រួចមន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលមានរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់បាន[50]។ ក្នុងករណីនេះព្រះរាជអាជ្ញាមានសមត្ថកិច្ចអាចបង្គាប់ឲ្យប្រគល់វត្ថុចាប់បានទៅម្ចាស់ដើមវិញ ប្រសិនបើកម្មសិទ្ធិលើវត្ថុនោះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ ហើយវត្ថុនោះពុំមែនជាវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬទ្រព្យសម្បត្តិទេ។ ប្រសិនបើព្រះរាជអាជ្ញាពុំព្រមប្រគល់អោយវិញទេ អ្នកប្តឹងសុំអោយប្រគល់វត្ថុចាប់បាននោះ អាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន។[51]

**២.៣.១.៥. ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ**

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បានមន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ។ ប៉ុន្តែត្រូវអោយបុគ្គលនោះស្បថតាមសាសនា ឬជំនឿរបស់ខ្លួន និងជួយដោយភក្តីភាពដល់តុលាការជាមុនសិន ប្រសិនបើបុគ្គលនេះពុំមានឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញ[52]។

**២.៣.១.៦. ការបញ្ចូលកំណត់ហេតុ វត្ថុតាង និងបុគ្គលដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា**

ក្រោយការបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា។ ប្រសិនបើមានបុគ្គលឃាត់ខ្លួននូវពេលផុតកំណត់ពេលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌សុំសេចក្តីសម្រេចពីព្រះរាជអាជ្ញា ថាតើត្រូវបញ្ជូនខ្លួនជននេះទៅព្រះរាជអាជ្ញា ឬដោះលែងអោយមានសេរីភាពឡើងវិញ។ ប្រសិនបើព្រះរាជអាជ្ញាសម្រេចថាអោយបញ្ជូន មន្ត្រីនគរបាលយុត្តិធម៌និងបញ្ជូនខ្លួនបុគ្គលនោះទៅព្រះរាជអាជ្ញាក្នុងរយះពេលដ៏ឆាប់បំផុត តាមការដែលអាចធ្វើទៅបាន។ ប្រសិនបើមានការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយនៃការដឹកជញ្ជូនរយះពេលបន្ថែមអាចផ្តល់អោយដោយព្រះរាជអាជ្ញា។

**២.៣.១.៧. ការស្តាប់ចម្លើយ និងការសន្ទនា**

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ពត៌មានស្តីពីរឿងហេតុបាន។ ក្នុងន័យនេះ ជនសង្ស័យក៏អាចអោយមន្ត្រីនគរបាលយុត្តិធម៌ស្តាប់ចម្លើយបានដែរ។ ប្រសិនបើមានការរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឲ្យចូលខ្លួនបាន។ បញ្ជាចូលខ្លួនអនុញ្ញាតអោយមន្ត្រីនគរបានយុត្តិធម៌ប្រើប្រាស់កំលាំងសាធារណះដើម្បីបង្ខំបុគ្គលនោះអោយចូលបង្ហាញខ្លួនបាន។ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនអនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌ បង្គាប់ឲ្យស្តាប់ ឬថតសម្លេងសន្ទនាតាមទូរស័ព្ទ ចាប់និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ សារពត៌មានទូរសារ ឬសារតាមអ៊ិនធើណេតឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌទទួលស្គាល់អំណាចនេះតែសម្រាប់ចៅក្រមស៊ើបសួរប៉ុណ្ណោះ។ ផ្ទុយ

[50] មាត្រា ៩២នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩
[51] មាត្រា ១១៩នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩
[52] មាត្រា ៩៥នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

ទៅវិញ មានករណីអញ្ញត្រកម្មមួយចំនួនដែលគួរគត់ចំណាំថាមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងនិងភេរវកម្ម ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរអាចអនុញ្ញាតអោយអ្នកស៊ើបអង្កេត តាមដាន និងដាក់ខ្សែទូរស័ព្ទក្រោមការលបស្តាប់និងថត[53]។ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ អាចអនុញ្ញាតអោយអ្នកស៊ើបអង្កេត តាមដាន និងដាក់ខ្សែទូរស័ព្ទតាមការលបស្តាប់។ បើវិធានការនេះអនុញ្ញាតអោយព្រះរាជអាជ្ញា គឺអាចមានរយះពេលត្រឹមតែ២(ពីរ)ខែប៉ុណ្ណោះ។ ការបន្តត្រូវអនុញ្ញាតដោយចៅក្រមស៊ើបសួរ[54]។

- **សម្គាល់៖** ការមិនអនុវត្តតាមបទបញ្ញត្តិខាងលើ អាចប្រឈមនិងការផ្តន្ទាទោសពីបទប៉ះពាល់ដល់ការសំងាត់នៃការសន្ទនាតាមទូរស័ព្ទដែលមានចែងក្នុងក្រមព្រហ្មទណ្ឌបានកំណត់ថា៖ អំពើប្រព្រឹត្តដោយគំនិតទុច្ចរិត ស្តាប់ ឬធ្វើអោយច្របូកច្របល់ការសន្ទនាតាមទូរស័ព្ទត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១(មួយ)សែនរៀល ទៅ២(ពីរ)លានរៀល[55]។

### ២.៣.២. ការស៊ើបអង្កេតករណីបឋម

ការស៊ើបអង្កេតបឋម កាលណាបានដឹងពីអំពើដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិម បទលហុមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯងក៏បាន ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ ម្យ៉ាងទៀត ចំពោះថិរវេលានៃការស៊ើបអង្កេតបឋមមិនមានកំណត់ពេលវេលាជាក់លាក់ទេ។ ដំណើរកាលការស៊ើបអង្កេតបឋមនៅក្នុងករណីដែលបទឧក្រិដ្ឋ ឬមជ្ឈឹមមិនជាក់ស្តែងឬក្នុងករណីដែលថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងបានកន្លងផុត។ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងតែ ៧(ប្រាំពីរ)ថ្ងៃប៉ុណ្ណោះ គិតពីថ្ងៃប្រព្រឹត្តបទល្មើស[56]។ ក្នុងនីតិវិធីនៃការស៊ើបអង្កេតបឋម គឺមានវិធានមួយចំនួនដែលបានអនុវត្តដូចគ្នា និងការស៊ើបអង្កេតករណីជាក់ស្តែងដែរហើយមានវិធានមួយចំនួនទៀត គឺមានលក្ខណះខុសគ្នានិងការស៊ើបអង្កេតករណីជាក់ស្តែងដែរ ព្រោះអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងលក្ខខណ្ឌនៃការស៊ើបអង្កេតបឋមនេះ ត្រូវបានកំណត់តឹងរឹងជាងការស៊ើបអង្កេតក្នុងករណីជាក់ស្តែង។

#### ២.៣.២.១. កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ

ក្រមនីតិវិធីព្រហ្មទណ្ឌចំពោះការធ្វើកំណត់ហេតុ លើការស្រាវជ្រាវ និងការពិនិត្យមន្ត្រីនគរបាលយុត្តិធម៌នឹងត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវនិងការពិនិត្យរបស់ខ្លួន[57]។

[53] មាត្រា ២៧នៃច្បាប់ស្តីអំពីការប្រឆាំងអំពើពុករលួយ

[54] មាត្រា ៨៨នៃច្បាប់ស្តីពីការប្រឆាំង និងភេរវកម្ម

[55] មាត្រា ៣១៥នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១១

[56] មាត្រា ១០៦នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[57] មាត្រា ៩០នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

**២.៣.២.២. ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ**

ករណីចាំបាច់តម្រូវអោយមានការត្រួតពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បានមន្ត្រីនគរបាលយុត្តិធម៌ អាចពឹងដល់បុគ្គលគ្រប់រូបដែលមានវិជ្ជាជំនាញ ឬឯកទេស[58]។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីជំនាញអ្នកជំនាញ ហើយបញ្ជីនេះត្រូវបានបង្កើតឡើងដែលត្រូវបានរៀបចំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបែបបទនៃការចុះឈ្មោះ ឬការលុបឈ្មោះចេញអំពីបញ្ជីត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។

**២.៣.២.៣. ការហាមឃាត់មិនអោយស្តាប់សារសំលេងឯកឯងជាអាទិ៍**

មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់អោយស្តាប់ និងថតសំលេងនៃការសន្ទនាតាមទូរស័ព្ទបានឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ គឺពុំអាចបង្គាប់អោយចាប់និងថតការឆ្លើយឆ្លង ដែលចេញពីមធ្យោបាយទូរគមនាគមន៍ជាអាទិ៍ សារតាមទូរសារ និងអ៊ីនធើណេតជាដើមបានឡើយ ករណីនេះអាចត្រូវបានអនុញ្ញាតប្រសិនបើលក្ខខណ្ឌមួយចំនួនត្រូវបានបំពេញ។

**២.៣.២.៤. ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា**

ក្រោយពេលបញ្ចប់នៃកាស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញានោះ ការបញ្ជូននិងកំណត់ហេតុ និងវត្ថុតាងត្រូវធ្វើជាមួយ និងការបញ្ជូនខ្លួនបុគ្គលនេះផងដែរមានន័យថា បុគ្គលនិងវត្ថុតាងត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ដើម្បីធ្វើការពិនិត្យ និងចំណាត់ការបន្ត។

**២.៣.២.៥. និទ្ទេសដែលចុះនៅក្នុងកំណត់ហេតុ**

កំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះដូចជា៖

- ឈ្មោះនិងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌
- អង្គភាពមន្ត្រីនគរបាលយុត្តិធម៌
- កាលបរិច្ឆេទ។

ទំព័រនីមួយៗត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ ពាក្យឆូតលុបនិងការយោងត្រូវតែមានការបញ្ជាក់យល់ព្រមដោយមាននូវការចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រនៃកំណត់ហេតុ។ កំណត់ហេតុស្តីពីការស្តាប់ចម្លើយឬស្តីពីការឃាត់ខ្លួន នឹងត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធផងដែរ។

[58] មាត្រា ៩៥នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

### ២.៣.២.៦. ការឆែកឆេរ

ការស៊ើបអង្កេតបឋមទាក់ទងទៅនឹង បទឧក្រិដ្ឋឬបទមជ្ឈឹម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងបាន មុននិងធ្វើការឆែកឆេរមន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលនូវការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង។ សរុបមកមានន័យថា មុននិងអនុវត្តការងារនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលនូវការឯកភាពអោយបានច្បាស់លាស់ពីអ្នកកាន់កាប់ទីកន្លែងដែលត្រូវធ្វើការឆែកឆេរនោះ។ ការយល់ព្រមនេះគឺត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដែលសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែងនេះ។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរត្រូវសរសេរអោយបានច្បាស់លាស់នៅក្នុងកំណត់ហេតុថា អ្នកកាន់កាប់នេះមិនចេះអក្សរហើយយល់ព្រមអោយធ្វើការឆែកឆេរ។ ផ្ទុយទៅវិញ ក្នុងករណីអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬធ្វើការបដិសេធការឆែកឆេរនោះ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដីអាចចេញដីកាអនុញ្ញាតអោយឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញា។ ក្នុងករណីបែបនេះព្រះរាជអាជ្ញាត្រូវដឹកនាំ ឆែកឆេរដោយផ្ទាល់ហើយត្រូវធ្វើនូវចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬករណីគ្មានអ្នកកាន់កាប់ទីកន្លែងទេត្រូវធ្វើការឆែកឆេរនូវចំពោះមុខសាក្សីពីរនាក់ដែលសាក្សីនោះ ត្រូវធ្វើការចាត់តាំងដោយព្រះរាជអាជ្ញាហើយសាក្សីនោះមិនអាចជ្រើសរើសពីនគរបាល ឬកងរាជអាវុធហត្ថដែលរួមប្រតិបត្តិការងារនៅក្នុងការឆែកឆេរជាមួយខ្លួនបានឡើយ។ ម្យ៉ាងទៀតចំពោះពេលវេលានៃការឆែកឆេរ គឺអាចចាប់ផ្តើមឆែកឆេរមុនម៉ោង ៦(ប្រាំមួយ)ព្រឹកនិងក្រោយម៉ោង ១៨ (ដប់ប្រាំបី)ល្ងាចបានឡើយ។ ចំពោះការចាប់យកវត្ថុតាងវិញ មន្ត្រីនគរបាលយុត្តិធម៌អាចចាប់យកវត្ថុតាងបាន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបិទស្លាកនិងបោះត្រានៅលើវត្ថុតាងដែលខ្លួនបានចាប់យកនោះ។ បន្ទាប់មកក្រោយពីបានបង្ហាញវត្ថុតាងដែលខ្លួនបានចាប់យកនោះដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់អោយមើលរួច មន្ត្រីនគរបាលយុត្តិធម៌និងធ្វើកំណត់ហេតុចាប់យក។ កំណត់ហេតុស្តីពីការចាប់យកត្រូវចុះហត្ថលេខា ឬផ្តិតមេដៃដោយអ្នកកាន់កាប់ទីកន្លែងនៃការឆែកឆេរនោះ។

### ២.៣.២.៧. ការបញ្ជាឲ្យចូលខ្លួន

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ឬដែលអាចផ្តល់ពត៌មានស្តីអំពីរឿងហេតុ។ ករណីនេះបុគ្គលដែលត្រូវបានកោះហៅត្រូវតែបង្ហាញខ្លួន ក្នុងករណីបើមានរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចបញ្ជាឲ្យចូលខ្លួន។ ការបញ្ជាអោយចូលខ្លួននេះត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ កាលបរិច្ឆេទ និងមានចុះហត្ថលេខាដោយព្រះរាជអាជ្ញាព្រមទាំងមានការបោះត្រាផងដែរ។ ការបញ្ជាអោយចូលខ្លួន គឺជាអំណាចដែលធ្វើឡើងដោយព្រះរាជអាជ្ញាជាការអនុញ្ញាតមួយដែលផ្តល់អោយមន្ត្រីនគរបាលយុត្តិធម៌អាចមានសិទ្ធិប្រើប្រាស់

នូវកងកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ អោយចូលមកបង្ហាញខ្លួនបានក្នុងករណីបដិសេធមិនព្រមចូលតាមបញ្ជារបស់ព្រះរាជអាជ្ញា។

**២.៣.២.៨. កំណត់ហេតុស្រង់ចម្លើយ**

កាលណាមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយបុគ្គលដែលពាក់ព័ន្ធ ការស្តាប់ចម្លើយនីមួយៗត្រូវមានការធ្វើកំណត់ហេតុ។ ការធ្វើកំណត់ហេតុត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធដែលបានផ្តល់នោះ។ ករណីមានការចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែបាន ប៉ុន្តែមុននិងបំពេញការងារនេះ អ្នកបកប្រែត្រូវស្បថតាមសាសនា និងជំនឿរបស់ខ្លួនថា ខ្លួននិងបកប្រែអោយបានត្រឹមត្រូវ។ ជាមួយគ្នានេះអ្នកបកប្រែមិនត្រូវបានធ្វើការជ្រើសរើសនៅក្នុងចំណោមនគរបាលឬកងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធក្នុងរឿងជាមួយគ្នាដែលកំពុងធ្វើការស៊ើបអង្កេតបានឡើយ។

**២.៣.២.៩. ការឃាត់ខ្លួនជនសង្ស័យ**

ក្នុងដំណាក់កាលស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌អាចមានសិទ្ធិឃាត់ខ្លួនជនជាប់សង្ស័យបានដោយអនុវត្តនីតិវិធីនៃការឃាត់ខ្លួនក្នុងដំណាក់កាលស៊ើបអង្កេតជាក់ស្តែង។ មានន័យថាកាលណាស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋឬបទមជ្ឈិមនោះវិធានការនៃការឃាត់ខ្លួន ការបញ្ជូនខ្លួន ត្រូវអនុវត្តដូចគ្នាទៅនិងការស៊ើបអង្កេតក្នុងបទល្មើសជាក់ស្តែងដែរ។

**២.៣.២.១០. ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស**

តាមការអនុវត្តដីកាចាត់អោយស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិអោយចៅក្រមស៊ើបសួរនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត ឬដល់មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរជំនួសខ្លួន។ ដីកាចាត់អោយស៊ើបសួរជំនួសមិនមានលក្ខណៈជាទូទៅទេ ត្រូវតែណែនាំអោយបានច្បាស់លាស់។ ទន្ទឹមនិងនេះ ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់អោយស៊ើបសួរជំនួសបានគ្រប់ពេលវេលាទៅតាមសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ។ មន្ត្រីនគរបាលយុត្តិធម៌អនុវត្តនូវដីកាចាត់អោយស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនទៅចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ ក្នុងការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញកិច្ចដែលមានចែងនៅក្នុងដីកាចាត់អោយស៊ើបសួរជំនួសនូវក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែមានការពន្លាតសមត្ថកិច្ចដែនដីដោយផ្អែកលើស្ថានភាពចាំបាច់ជាមួយនិងការអនុញ្ញាតពីចៅក្រមស៊ើបសួរ ដែលជាអ្នកចេញដីកានោះ[59]។ ករណីអនុវត្តតួនាទីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្រាវជ្រាវនិងការពិនិត្យរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅនិងស្តាប់ចម្លើយសាក្សីបាន ហើយមុននិងឆ្លើយចំពោះ

[59] មាត្រា ៩៥នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

សំណួរសាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ជំនឿរបស់ខ្លួនថានិយាយតែការពិត។ ប៉ុន្តែសាក្សីដែលបានរៀបរាប់ដូចខាងក្រោមនេះ ច្បាប់បានចែងដោយមិនចាំបាច់ធ្វើសម្បថទេ ហើយសាក្សីទាំងនោះមានដូចជាៈ

- ឪពុកម្តាយ និងបុព្វញាតិគ្រប់រូបរបស់ជនត្រូវចោទ
- កូនប្រុសកូនស្រីនិងបច្ឆាញាតិគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ។
- បងប្អូនប្រុស ស្រីរបស់ជនត្រូវចោទ។
- សហព័ទ្ធ ឬប្តី ឬប្រពន្ធរបស់ជនត្រូវចោទទោះបីបានលែងលះគ្នាហើយក៏ដោយ។
- កុមារអាយុតិចជាង១៤(ដប់បួន)ឆ្នាំ។

### ២.៣.២.១១. ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននិងដីកាបង្គាប់ឲ្យចាប់ខ្លួន

ដើម្បីជាជំនួយដល់ការស៊ើបសួរនូវក្នុងគោលដៅស្វែងរកការពិតនោះចៅក្រមស៊ើបសួរ មានសិទ្ធិប្រគល់ដីកាបង្គាប់អោយនាំខ្លួន ដល់មន្ត្រីនគរបាលយុត្តិធម៌អោយអនុវត្តដីកានេះបាន។ ហើយចំពោះការអនុវត្តដីកាបង្គាប់អោយនាំខ្លួនត្រូវប្រគល់អោយមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់អោយនាំខ្លួនបានត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាលឬកងរាជអាវុធហត្ថតាមគ្រប់មធ្យាបាយ។ ដោយដើមដីកានេះត្រូវប្រគល់ជូនជាបន្ទាន់អោយដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានោះ។ ក្នុងការអនុវត្តការងារនេះ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលណាដែលពាក់ព័ន្ធមុនម៉ោង ៦(ប្រាំមួយ)ព្រឹកនិងក្រោយម៉ោង ១៨(ដប់ប្រាំបី)ល្ងាចបានទេ។ ជាមួយគ្នានេះ នូវរាល់ការលំបាករបស់ខ្លួនពេលអនុវត្តនូវបេសកកម្មនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងពីការលំបាករបស់ខ្លួននោះ ជូនទៅចៅក្រមស៊ើបសួរដែលជាម្ចាស់ដីកា។ ក្នុងករណីដែលបុគ្គលពាក់ព័ន្ធត្រូវបានមន្ត្រីនគរបាលនាំមកបង្ហាញខ្លួននូវចំពោះមុខចៅក្រមស៊ើបសួរ។ ប៉ុន្តែប្រសិនបើមានមូលហេតុនៃកាលៈទេសៈតម្រូវដូចជា ករណីមានការយឺតយ៉ាវដោយសារការដឹកជញ្ជូនជាដើម ដែលជាហេតុធ្វើអោយបុគ្គលដែលពាក់ព័ន្ធ គឺមិនអាចត្រូវបានបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបុគ្គលនេះ ត្រូវតែនាំខ្លួនទៅអង្គភាពនគរបាលឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ត្រដល់ចៅក្រមស៊ើបសួរឬដល់អ្នកជំនួស។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនូវថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធនិងត្រូវបានដោះលែងអោយមានសេរីភាពឡើងវិញ។ ចំពោះការអនុវត្តដីកាបង្គាប់អោយចាប់ខ្លួនវិញ ក្នុងករណីបន្ទាន់ត្រូវផ្សព្វផ្សាយតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយហើយការអនុវត្តដីកាបង្គាប់អោយចាប់ខ្លួននេះ ត្រូវតែប្រគល់អោយមន្ត្រីនគរបាលយុត្តិធម៌។ ចំណែកដើមដីកាត្រូវប្រគល់ក្នុងរយៈពេលខ្លីបំផុតទៅមន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានោះ។ ដូច្នេះការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦(ប្រាំមួយ)ព្រឹកនិងក្រោយម៉ោង ១៨(ដប់ប្រាំបី)ល្ងាចបាន

ឡើយ។ នៅពេលអនុវត្តបេសកកម្មរបស់ខ្លួន ករណីដែលមានការលំបាកមន្ត្រីនគរបាលយុត្តិធម៌ត្រូវអោយដំណឹងអំពីការលំបាកនោះ ដល់ចៅក្រមស៊ើបសួរ។ បុគ្គលដែលពាក់ព័ន្ធត្រូវបានគេនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលខ្លីបំផុត ប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនូវឡើយ។ ប្រសិនបើបុគ្គលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬមួយអ្នកជំនួសចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនបុគ្គលនេះ បុគ្គលនោះត្រូវបាននាំទៅជួបព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនដើម្បីស្តាប់ចម្លើយ បន្ទាប់ពីស្តាប់ចម្លើយនោះរួចត្រូវតែបញ្ជូនទៅចៅក្រមស៊ើបសួរវិញ[60]។

## ផ្នែកទី៣៖ អង្គការអយ្យការ(ព្រះរាជអាជ្ញា)

អង្គការអយ្យការ គឺជាអ្នកតំណាងអោយផលប្រយោជន៍ទូទៅ ជាម្ចាស់បណ្តឹងអាជ្ញា និងជាភាគីនូវក្នុងរឿងព្រហ្មទណ្ឌ។ តាមអត្ថន័យមាត្រា ២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាអង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងធ្វើការសន្និដ្ឋានអោយតុលាការអនុវត្តច្បាប់។ អង្គការអយ្យការធ្វើការធានារ៉ាប់រងចំពោះការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ហើយព្រមទាំងធានាដោយយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់អោយចាប់ខ្លួនផងដែរ។ ក្នុងការបំពេញភារៈកិច្ចរបស់ខ្លួន ចៅក្រមឈរឬអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយរបស់ខ្លួនក្នុងការបំពេញមុខងាររបស់ខ្លួន ក៏ដូចជានីតិវិធីតុលាការ ចំពោះចំណាត់ការក្នុងរឿងក្តីព្រហ្មទណ្ឌ។ ជាមួយគ្នានេះដែលចៅក្រមឈរឬអយ្យការ ត្រូវតែមានវត្តមានក្នុងពេលសវនាការ សម្រាប់រឿងក្តីព្រហ្មទណ្ឌនានា ដោយឡែកចំពោះក្នុងរឿងក្តីរដ្ឋប្បវេណីចៅក្រមអយ្យការមិនមានវត្តមានទេ លើកលែងតែរឿងក្តីរដ្ឋប្បវេណីណាមួយ ដែលប៉ះពាល់ដល់ប្រយោជន៍របស់សង្គមទើបមានវត្តមានរបស់ចៅក្រមអយ្យការ។

### ៣.១. សមាសភាពនៃចៅក្រមអយ្យការ

ចៅក្រមអយ្យការ គឺជាសមាសភាពបុគ្គលដែលបម្រើការងារនៅក្នុងអង្គការអយ្យការដែលហៅថា "ព្រះរាជអាជ្ញា"។ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចៅក្រមអយ្យការរួមមាន៖

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល។
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។
- ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង អមសាលាដំបូង[61]។

ចំពោះក្នុងការអនុវត្តតួនាទីរបស់ខ្លួននោះ អង្គការអយ្យការជាស្ថាប័នមួយដែលមានឋានានុក្រម ហើយឋានានុក្រមនេះស្តែងចេញតាមរយៈការប្រើអំណាចអធិបញ្ញា។ ក្នុងអត្ថន័យថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានសិទ្ធិ

[60] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក អៀង សំណាងឆ្នាំ២០១៩

[61] មាត្រា ២៨នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងនានា ក្នុងព្រះរាជាណាចក្រកម្ពុជាពីបទល្មើសដែលខ្លួនបានដឹង ហើយអាចធ្វើអធិបញ្ញាទៅតាមការណែនាំជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងនានាអោយធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការយល់ឃើញជាការគួរ។ ទោះបីជាយ៉ាងនេះក្តីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចមានសិទ្ធិចេញអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងនានា អោយធ្វើការតម្កល់រឿងទុកឥតចាត់ការចំពោះរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។ អំណាចអធិបញ្ញានេះក៏ត្រូវបានទទួលស្គាល់ផងដែរ ចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍លើចៅក្រមអយ្យការទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនបានផងដែរ។ ប៉ុន្តែអធិបញ្ញានេះ ត្រូវបានកម្រិតពេល គឺនូវពេលសវនាការចៅក្រមអយ្យការធ្វើកំណត់សម្គាល់ផ្ទាល់មាត់ និងដោយសេរីតាមអ្វីដែលខ្លួនបានយល់ឃើញថាមានភាពត្រឹមត្រូវ និងស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ដោយគ្មានការចោទប្រកាន់ពីបទវិន័យណាមួយបានឡើយ។

### ៣.១.១. មុខងាររបស់ចៅក្រមអយ្យការអមតុលាការកំពូល

តុលាការកំពូល គឺមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះអគ្គរាជអាជ្ញាអមតុលាការកំពូលជាតំណាងអង្គការអយ្យការ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចូលរួមនៅក្នុងការស្នើសុំអោយមានការគោរពច្បាប់ក្នុងពេលដែលមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ ព្រមទាំងបណ្តឹងតវ៉ាផ្សេងៗទៀតដាក់ជូនទៅតុលាការកំពូលដើម្បីដោះស្រាយ។

### ៣.១.២. មុខងាររបស់ចៅក្រមអយ្យការអមសាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ គឺមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាតំណាងអង្គការអយ្យការ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើការឃ្លាំងមើលអំពីការអនុវត្តច្បាប់ និងអាចធ្វើអធិការកិច្ចគ្រប់អង្គការអយ្យការទាំងឡាយដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់សាលាឧទ្ធរណ៍។ ក្នុងករណីដែលមានបទល្មើសធ្ងន់ធ្ងរកើតឡើងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវរាយការណ៍ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អោយបានជ្រាប។ តាមគោលការណ៍ច្បាប់ អគ្គព្រះរាជអាជ្ញាមិនត្រឹមតែឃ្លាំមើលនិងត្រួតពិនិត្យការងារនគរបាលយុត្តិធម៌ប៉ុណ្ណឹងនោះទេ ក៏មានសិទ្ធិកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ដើម្បីពិភាក្សាពីបញ្ហាដែលទាក់ទង និងការប្រព្រឹត្តទៅរបស់អង្គភាពនគរបាលយុត្តិធម៌នេះផងដែរ ហើយក៏អាចប្រគល់ភារៈកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់អោយបំពេញនូវភារៈកិច្ចទាំងឡាយណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការល្អនៃនគរបាលយុត្តិធម៌។ បន្ថែមលើសពីនេះទៅទៀត អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចមានសិទ្ធិចូលស្តាប់ចម្លើយ អាចត្រួតពិនិត្យរាល់ការអនុវត្ត

វិធាននៃការឃាត់ខ្លួន ជាពិសេសការគោរពទម្រង់ច្បាប់ ការកាន់កាប់ គ្រប់គ្រងកន្លែងឃាត់ខ្លួន។ ម៉្យាងវិញទៀត ប្រធានអង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌គ្រប់រូប ត្រូវតែគោរព អធិបញ្ញារបស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

### ៣.១.៣. មុខងាររបស់ចៅក្រមអយ្យការអមសាលាដំបូង

សាលាដំបូង គឺមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ជាតំណាងអង្គការអយ្យការ។ ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែនៅពេលណាដែលត្រូវអនុវត្តដីកាចាត់អោយស៊ើបសួរជំនួសនោះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនូវក្រោមអំណាចរបស់ចៅក្រមស៊ើបសួរដែលជាអ្នកចេញដីកា។ ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងស៊ើបអង្កេត ព្រមទាំងធ្វើការណែនាំណាមួយដែលមានប្រយោជន៍អោយដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌។ ក្នុងករណីពិសេសមានការចាំបាច់ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌មកវិញបាន។ ព្រះរាជអាជ្ញា ក៏អាចធ្វើអធិការកិច្ចបាននូវគ្រប់ពេលវេលានៅក្នុងអង្គភាពយុត្តិធម៌ហើយក៏អាចចូលស្តាប់ចម្លើយ ការត្រួតពិនិត្យការអនុវត្តវិធាននៃការឃាត់ខ្លួនជាពិសេសការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងនៃការឃាត់ខ្លួនបាន។ ព្រះរាជអាជ្ញាអាចប្រើប្រាស់អំណាចទាំងអស់ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមានន័យថា ក្រមនីតិវិធីព្រហ្មទណ្ឌបានទទួលស្គាល់អោយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសនីមួយៗ ដែលបានកើតឡើងជាក់ស្តែង។ ចំណែកឯព្រះរាជអាជ្ញារងវិញ គឺស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ពោលគឺអាចប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ ព្រមទាំងធ្វើការចោទប្រកាន់ ចំពោះបទល្មើសកើតឡើងនៅក្នុងគោលដៅផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់[62]។

## ៣.២. សមត្ថកិច្ចរបស់អយ្យការ

ព្រះរាជអាជ្ញា គឺមានតួនាទីធ្វើការចោទប្រកាន់តាមរយៈបណ្តឹងអាជ្ញា។ ក្នុងរដ្ឋធម្មនុញ្ញបានចែងថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[63]។ ដូច្នេះព្រះរាជអាជ្ញាពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យបណ្តឹងអាជ្ញាអោយមានចលនា គឺមានន័យថាការចោទប្រកាន់អំពីបទល្មើសណាមួយ។

### ៣.២.១. សមត្ថកិច្ចដែនដីរបស់អយ្យការ

ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាព្រះរាជអាជ្ញាមានសមត្ថកិច្ចដែនដីដែលបានកំណត់ដូចខាង:

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស

---

[62] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក អៀង សំណាងឆ្នាំ២០១៩

[63] មាត្រា ១៣១ថ្មីនៃរដ្ឋធម្មនុញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ព្រះរាជអាជ្ញានៅទីកន្លែងនីមួយៗសុទ្ធតែមានសមត្ថកិច្ចចំណាត់ការរឿងក្តីទាំងអស់។ ក្នុងករណីដែលវិវាទសមត្ថកិច្ចដែនដីនោះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាអ្នកមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចថា ព្រះរាជអាជ្ញារូបណាមួយដែលមានសមត្ថកិច្ចដែនដី ក្នុងចំណាត់ការនៃសំណុំរឿងក្តីព្រហ្មទណ្ឌនោះដោយមានម្ចាស់បណ្តឹងតែមួយ ប្តឹងមកព្រះរាជអាជ្ញាមានសមត្ថកិច្ចដែនដីរៀងៗខ្លួន។

**៣.២.២. សមត្ថកិច្ចក្នុងការធ្វើចំណាត់ការលើសំណុំរឿង**

ស្ថាប័នអយ្យការ គឺជាស្ថាប័នកណ្តាលមួយដែលត្រូវទទួលគ្រប់នូវព័ត៌មានដែលទាក់ទង និងបទល្មើសព្រហ្មទណ្ឌ។ មានន័យថាព្រះរាជអាជ្ញាទទួលនូវពាក្យបណ្តឹង និងបណ្តឹងបរិហារផ្សេងៗដែលទាក់ទងទៅនឹងរឿងបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើង ហើយត្រូវបានទទួលដោយផ្ទាល់ពីសំណាក់ជនរងគ្រោះ ព្រមទាំងបុគ្គលដទៃផ្សេងទៀត ក្រៅពីជនដែលរងគ្រោះ(តតិយជន) ឬដោយមន្ត្រីនគរបាលយុត្តិធម៌។ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានចែងជាកាតព្វកិច្ចសម្រាប់អាជ្ញាធរសាធារណៈ និងមន្ត្រីគ្រប់រូបនូវក្នុងពេលដែលបំពេញមុខងាររបស់ខ្លួនខណៈខ្លួនបានដឹងពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ បានកើតឡើងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតកន្លែងកើតហេតុ[64]។ ជាគោលការណ៍ក្រោយពេលទទួលបាននូវព័ត៌មានទាក់ទងទៅនិងបទល្មើសព្រហ្មទណ្ឌណាមួយនោះនូវមុនពេលធ្វើចំណាត់ការទៅលើសំណុំរឿងដែលទទួលបាននោះ ព្រះរាជអាជ្ញាបើកនូវការស៊ើបអង្កេតបឋម ឬបង្គាប់អោយមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្រាវជ្រាវបន្ថែមសំដៅដល់ការប្រមូលនូវព័ត៌មានបំភ្លឺបន្ថែមទៀត ដើម្បីអាចធ្វើជាមូលដ្ឋានដ៏សំខាន់មួយសម្រាប់ធ្វើការវាយតម្លៃព្រមទាំងថ្លឹងថ្លែងដោយកំណត់ចំណាំនៅលើសំណុំរឿងនោះអោយបានត្រឹមត្រូវនិងច្បាស់មុន និងព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬក៏សម្រេចតម្កល់រឿងទុកឥតចាត់ការ។ ស្របតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ ឬក៏សម្រេចតម្កល់រឿងទុកឥតចាត់ការបាន។

**៣.២.២.១. ការធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ**

កាលណាបណ្តឹងណាមួយត្រូវតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវអោយដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល២(ពីរ)ខែដោយគិតពីថ្ងៃចុះពាក្យនូវបណ្តឹងក្នុងបញ្ជីបណ្តឹងដែលបញ្ជីបណ្តឹងនេះ គឺមាននូវតាមតុលាការជាន់ដំបូងនីមួយៗត្រូវបានបង្កើតអោយ

[64] មាត្រា ៤២នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

មានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្តឹងដែលបណ្តឹងដែលប្តឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬបញ្ជូនមកតាមរយៈមន្ត្រីនគរបាលយុត្តិធម៌[65]។ ចំពោះគ្រប់បណ្តឹងត្រូវតែចុះក្នុងបញ្ជីដោយមានខ្លឹមសារកំណត់ដូចខាងក្រោម៖

- អត្តសញ្ញាណរបស់អ្នកបណ្តឹង
- កាលបរិច្ឆេទដែលអយ្យការបានទទួលពាក្យបណ្តឹង
- ប្រភពនៃបណ្តឹង ដែលប្តឹងផ្ញើមកដោយផ្ទាល់ចំពោះព្រះរាជអាជ្ញា ឬក៏បញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌
- ប្រភេទនៃរឿងហេតុដែលអ្នកប្តឹងបានរាយការណ៍
- ចំណាត់ការលើបណ្តឹងកាលណាសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមួយ។

បញ្ជីនៃការប្តឹងត្រូវកាន់កាប់ដោយលេខាធិការរបស់អយ្យការក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។ បញ្ជីនេះអាចត្រូវបានបើកមើលដោយអាជ្ញាធរតុលាការទាំងអស់។ បើយោងតាមគោលការណ៍កាលានុវត្តភាពនៃបណ្តឹងអាជ្ញានេះបានអនុញ្ញាតអោយព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការបាន ទោះបីអំពើដែលបានប្តឹងឬបរិហារមកនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាអំពើនោះគឺមិនមានភាពរឹករវដល់សង្គមឬប៉ះពាល់សណ្តាប់ធ្នាប់ធ្ងន់ធ្ងរ ឬមួយជាការប្រព្រឹត្តក្នុងកាលៈទេសៈពិសេសណាមួយដែលអាចអនុគ្រោះបាន។ ការសម្រេចសេចក្តីជាជម្រើសមិនចោទប្រកាន់នេះបានស្តែងចេញតាមរយៈសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់។ ម៉្យាងទៀត ទោះបីជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចមានសិទ្ធិធ្វើអធិបញ្ញាអោយព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ដែលខ្លួនបានដឹងក៏ដោយ ប៉ុន្តែមិនអាចធ្វើអធិបញ្ញាអោយតម្កល់រឿងទុកឥតចាត់ការនោះទេ។

### ក. មូលហេតុនៃការធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការមិនមានការកំណត់ដោយច្បាប់ជាក់លាក់ និងច្បាស់លាស់នោះទេ។ ប៉ុន្តែអាចកំណត់ដោយផ្អែកទៅលើស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌបាន។ មូលហេតុនៃការធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាមានដូចជា៖

- មូលហេតុដែលមិនអាចកំណត់អត្តសញ្ញាណរបស់ចារី ឬក៏ពុំមានបន្ទុកគ្រប់គ្រាន់ដើម្បីបង្ហាញអំពីពិរុទ្ធភាពរបស់ចារីហើយការស្រាវជ្រាវបន្ថែមដោយនគរបាលយុត្តិធម៌ ហាក់ដូចជាមិនទទួលបានលទ្ធផល ឬគ្មានប្រយោជន៍ដើម្បីទទួលបានធាតុផ្សំផ្សេងៗទៀតដែលធ្វើជាមូលហេតុចម្បងនៃការចោទប្រកាន់។

---

[65] មាត្រា ៤១នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

- មូលហេតុអំពើដែលបង្ហាញនោះមិនបង្កើតអោយមានជាបទល្មើសព្រហ្មទណ្ឌណាមួយឡើយ។
- មូលហេតុនៃបទល្មើសព្រហ្មទណ្ឌមិនមានលក្ខណៈគ្រប់គ្រាន់ដូចជា ធាតុផ្សំសំណុំរឿងមិនអនុញ្ញាត អោយកំណត់ពីធាតុផ្សំនៃបទល្មើស ឬក៏មានមូលហេតុមកពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌ(អនីតិជនអាយុក្រោម ១៤(ដប់បួន)ឆ្នាំ ការបញ្ជារបស់ច្បាប់ឬអាជ្ញាធរធម្មានុរូបភាព ការពារស្របច្បាប់ និង ស្ថានភាពចាំបាច់ដែលជាអំពើយុត្តិកម្មនោះ)។
- មូលហេតុនៃការរលត់បណ្តឹងអាជ្ញាជាដើម។

សរុបមកគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ បានផ្តល់លទ្ធភាពអោយចៅក្រមអយ្យការអាចធ្វើសេចក្តីសម្រេចតម្កល់រឿងក្តីព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានដែរ ទោះបីជាបទល្មើសនោះ អ្នកដែលបានប្រព្រឹត្តល្មើសត្រូវបានគេស្គាល់មុខក៏ដោយ ប៉ុន្តែព្រះរាជអាជ្ញាយល់ឃើញថាការតម្កល់រឿងទុកឥតចាត់ការនេះ គឺមានលក្ខណៈត្រឹមត្រូវតាមកាលៈទេសៈដើម្បីផលប្រយោជន៍ទូទៅ។ ពីព្រោះវិព្យសនកម្មដែលបានកើតឡើងដោយសារបទល្មើសនោះ មានតម្លៃតិចតួចពេកឬហេតុផលម្យ៉ាងទៀតដូចជា ភាពរំភើបដល់សណ្តាប់ធ្នាប់សាធារណៈ គឺមានលក្ខណៈមិនធ្ងន់ធ្ងរ ឬជនល្មើសបានប្រព្រឹត្តបទល្មើសជាលើកដំបូងដែលទំហំនៃវិព្យសនកម្មមានទ្រង់ទ្រាយតិចតួច ឬជនល្មើសបានជួសជុលការខូចខាតអោយដល់ជនរងគ្រោះបានរួចរាល់ហើយជាដើម។

### ខ. នីតិវិធីនៃការធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ

ការធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ត្រូវធ្វើការជូនដំណឹងដល់អ្នកប្តឹងដឹងពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលខ្លីបំផុត ហើយយ៉ាងយូរផុតរយៈពេល ២(ពីរ)ខែដោយគិតពីថ្ងៃដែលចុះពាក្យបណ្តឹងក្នុងបញ្ជី។ ចំពោះការធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ហើយត្រូវតែមានមូលហេតុសំអាងច្បាប់ព្រមទាំងមានសំអាងហេតុជាក់លាក់ច្បាស់លាស់ ហើយការធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ គ្មានអាជ្ញាអស់ជំនុំនោះទេ។ ព្រះរាជអាជ្ញាអាចធ្វើការសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញក្នុងខណៈពេលដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់ ហើយមានភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើនូវការចោទប្រកាន់។ ប្រសិនបើអ្នកប្តឹងមិនសុខចិត្ត និងការធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការនោះទេ សាមីខ្លួនមានសិទ្ធិធ្វើការប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។ ការតវ៉ានេះត្រូវធ្វើឡើងតាមរយៈបណ្តឹងដែលដាក់ជូនទៅអយ្យការដែលពាក់ព័ន្ធបន្ទាប់មកសំណុំរឿង និងត្រូវបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយតំណាងអយ្យការអមសាលាដំបូងដើម្បីអគ្គព្រះរាជអាជ្ញាពិនិត្យ និងសម្រេច។

នីតិវិធីបន្ទាប់មុននិងធ្វើការសម្រេចសេចក្តី អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើការស៊ើបអង្កេតបន្ថែមទៀតបានផងដែរ។ ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូងអោយធ្វើការចោទប្រកាន់តាមការសន្និដ្ឋាន

របស់ខ្លួន។ អធិបញ្ញានិងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ហើយផ្ទុយទៅវិញបើយល់ឃើញថាការតវ៉ានេះ គឺមិនមានមូលហេតុត្រឹមត្រូវនោះទេ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើការតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការដដែល ហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវជូនដំណឹងអំពីការតម្កល់សេចក្តីសម្រេចនេះ ទៅអោយអ្នកប្តឹងតវ៉ានោះបានដឹងពីការសម្រេចនេះ[66]។

### ៣.២.២.២. ការធ្វើសេចក្តីសម្រេចការចោទប្រកាន់

គោលការណ៍កាលានុវត្តនៃការចោទប្រកាន់ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងពីចំណាត់ការនូវលើពាក្យបណ្តឹងផ្សេងៗដែលខ្លួនបានទទួលដោយផ្ទាល់ ឬទទួលបានតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបញ្ជូនមក។ ព្រះរាជអាជ្ញាអាចធ្វើការសម្រេចចិត្តដោយត្រូវតម្កល់រឿងទុកឥតចាត់ការ ប្រសិនបើខ្លួនយល់ឃើញថាករណីនោះមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ ឬអាចធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ[67]។ ករណីខ្លួនបានយល់ឃើញថាបទល្មើសនោះ មានធាតុផ្សំគ្រប់គ្រាន់អាចធ្វើការចោទប្រកាន់ទៅជនដែលប្រព្រឹត្តល្មើសនោះបាន មានន័យថាគោលការណ៍បានបង្ហាញពីការកំណត់នូវកាលានុវត្តភាពនៃការចោទប្រកាន់។ តាមរយៈគោលការណ៍នេះ ផ្តល់សិទ្ធិអោយព្រះរាជអាជ្ញានូវសេរីភាព និងឆន្ទានុសិទ្ធិ ក្នុងការវាយតម្លៃថាគួរធ្វើការចោទប្រកាន់ ឬមិនធ្វើការចោទប្រកាន់ដោយផ្អែកលើស្ថានទម្ងន់ទោស និងមូលហេតុផ្សេងៗអាចធ្វើជាធាតុផ្សំសំខាន់ៗសម្រាប់ក្នុងធ្វើការចោទប្រកាន់ ព្រមទាំងធាតុផ្សំដទៃទៀត ដូចជាកាលៈទេសៈនៃការប្រព្រឹត្ត នឹងភាពរីករាលដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនូវក្នុងសង្គមព្រមទាំងធាតុផ្សំមួយចំនួនទៀត ដែលអាចប្រមូលបានពីការស៊ើបអង្កេតនោះ។ ម៉្យាងវិញទៀត គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់នេះ ក៏បានផ្តល់សិទ្ធិដោយអនុញ្ញាតអោយព្រះរាជអាជ្ញា តម្កល់រឿងទុកឥតចាត់ការក៏បានដែរ ទោះបីជាអំពើដែលបរិហារនោះជាបទល្មើសក៏ដោយ ព្រោះគ្មានមូលហេតុគ្រប់គ្រាន់អាចទុកជាធាតុផ្សំបទល្មើស។ ចំពោះការធ្វើសេចក្តីសម្រេចចោទប្រកាន់អាចធ្វើបានតាមរយៈដីកាសន្និដ្ឋានអោយស៊ើបសួរ កំណត់ហេតុបង្ហាញខ្លួនភ្លាម និងការបញ្ជូនរឿងជំនុំជម្រះដោយផ្ទាល់។

### ក. ការបើកការស៊ើបសួរ(តាមរយៈដីកាសន្និដ្ឋានអោយស៊ើបសួរ)

ក្នុងករណីបទឧក្រិដ្ឋព្រះរាជអាជ្ញា ត្រូវតែបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរដែលត្រូវប្តឹងទៅដល់ចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលបង្ហាញប្រាប់ឈ្មោះ ឬប្រឆាំងលើអញ្ញាតជន(ជនដែលគេមិនស្គាល់អត្តសញ្ញាណ)។ ជាទូទៅដីកាបញ្ជូនរឿងអោយស៊ើបសួរចុះនិទ្ទេសរួមដូចជា៖

[66] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក អៀង សំណាងឆ្នាំ២០១៩

[67] មាត្រា ៤២នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

- សេចក្តីសង្ខេបអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលរងការស៊ើបសួរ ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញាទទួលបន្ទុករឿងក្តី។ ចំពោះទម្រង់ការបែបនេះមានលក្ខណៈដាច់ខាតត្រូវតែអនុវត្តបើពុំដូច្នេះទេ ដីកាបញ្ជូនរឿងអោយស៊ើបសួរត្រូវចាត់ទុកជាមោឃៈ មានន័យថាក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញា ដាច់ខាតត្រូវតែបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទៅចៅក្រមស៊ើបសួរតាមរយៈដីកានេះ បានបើកសិទ្ធិអោយដល់ចៅក្រមស៊ើបសួរមានសិទ្ធិបើកការស៊ើបសួរ ចំពោះរឿងក្តីដែលមានចង្អុលបង្ហាញក្នុងដីការបស់ព្រះរាជអាជ្ញានោះ។ ចំណែកចំពោះបទមជ្ឈឹមវិញ ព្រះរាជអាជ្ញាក៏អាចបើកការស៊ើបសួរបានដែរ ប្រសិនបើមូលហេតុមួយចំនួនដូចខាងក្រោមត្រូវបានបំពេញមានដូចជា៖

- អត្តសញ្ញាណរបស់ចារីមិនត្រូវបានគេស្គាល់
- សំណុំរឿងនេះ មិនទាន់មូលសព្វគ្រប់ដោយភស្តុតាងដែលប្រមូលបានពុំទាន់មានលក្ខណៈគ្រប់គ្រាន់នូវឡើយ។
- បទមជ្ឈឹមដែលត្រូវបានអ្វើការចោទប្រកាន់នោះ គឺមានលក្ខណៈស្មុគស្មាញពិបាកនិងដោះស្រាយឬជនល្មើសមានគ្នាច្រើនដែលបានប្រព្រឹត្តបទល្មើស។

ការបើកការស៊ើបសួរនេះ ត្រូវបានធ្វើឡើងទៅតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ដីកានេះជានីតិវិធីដែលមានសារៈសំខាន់ ដែលផ្តល់អោយចៅក្រមស៊ើបសួរអាចប្រើប្រាស់អំណាចរបស់ខ្លួនដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរមាន៖

- សេចក្តីសង្ខេបអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះ ឬអត្តសញ្ញាណរបស់បុគ្គលដែលរងការស៊ើបសួរ
- កាលបរិច្ឆេទ និងចុះហត្ថលេខាដោយតំណាងអយ្យការ

ក្រោយពីបានទទួលពាក្យបណ្តឹងហើយករណីព្រះរាជអាជ្ញាយល់ឃើញថា អំពើដែលគេប្តឹងមកនោះមាននូវមូលដ្ឋានគ្រប់គ្រាន់អាចចោទប្រកាន់បានព្រះរាជអាជ្ញា នឹងធ្វើការចោទប្រកាន់ដើម្បីបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។ ការបើកការស៊ើបសួរ គឺជាការប្តឹងទៅចៅក្រមស៊ើបសួរអោយធ្វើការ

ស៊ើបសួរលើអង្គហេតុណាមួយប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលបង្ហាញប្រាប់ពីឈ្មោះ ឬប្រឆាំងទៅលើជនដែលគេមិនស្គាល់ពីអត្តសញ្ញាណដែលគេហៅថា អញ្ញាតជនបានដែរ។ អត្ថន័យនៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ គឺជាការបញ្ជាក់ពីការផ្តល់នូវសមត្ថកិច្ចការងារជូនដល់ចៅក្រមស៊ើបសួរក្នុងខណៈនេះចៅក្រមស៊ើបសួរមានសិទ្ធិអំណាចយ៉ាងធំនូវក្នុងចំណាត់ការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ដោយធ្វើការស៊ើបសួរស្វែងរកទាំងភស្តុតាងដាក់បន្ទុកទាំងភស្តុតាងដោះបន្ទុកលើជនល្មើស ក្នុងគោលដៅស្វែងរកអោយឃើញការពិតដែលបានកើតឡើង។

**ខ ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់**

ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីនៃការសម្រេចធ្វើការចោទប្រកាន់ដោយព្រះរាជាអាជ្ញា។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ជានីតិវិធីមួយដែលអាចយកអនុវត្តបាន ចំពោះបទមជ្ឈឹមតូចតាចនិងគ្រប់បទលហុហើយសំណុំរឿងនេះមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជំម្រះបានទោះបីជនជាប់ចោទជានីតិជន ឬអនីតិជនក៏ដោយក៏នីតិវិធីនេះអាចប្រព្រឹត្តទៅបានដែរ។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ត្រូវធ្វើតាមរយៈដីកាកោះហៅទៅជំនុំជម្រះផ្ទាល់ដែលតាមរយៈដីកានេះ ជាបញ្ជាអោយជនជាប់ចោទចូលបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង។ ដីកានេះចុះនិទ្ទេសរួមមាន៖

- អត្តសញ្ញាណជនជាប់ចោទ
- សេចក្តីសង្ខេបអង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

ក្នុងដីកានេះត្រូវតែចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែងកាលបរិច្ឆេទ ពេលសវនាការ។ ជាចុងក្រោយដីកានេះត្រូវបញ្ជាក់ថាជនជាប់ចោទអាចពឹងមេធាវីអោយអមខ្លួនបាន។

**គ. ការធ្វើនីតិវិធីបង្ហាញខ្លួនភ្លាម**

ព្រះរាជអាជ្ញាអាចបង្គាប់អោយនាំខ្លួន ជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូងកាលបើមានគ្រប់លក្ខខណ្ឌដូចខាងក្រោម៖ បទល្មើសជាបទល្មើសជាក់ស្តែង និងករណីបទឧក្រិដ្ឋ ឬនិងបទមជ្ឈឹមជាក់ស្តែង ហើយបទល្មើសដែលត្រូវចោទប្រកាន់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១(មួយ)ឆ្នាំ និងយ៉ាងច្រើន ៥(ប្រាំ)ឆ្នាំ ជនជាប់ចោទជានីតិជននិងរឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបាន។ ព្រះរាជអាជ្ញាអាចបង្គាប់អោយមានការនាំខ្លួនជនជាប់ចោទ អោយចូលមកបង្ហាញខ្លួនភ្លាមនូវចំពោះតុលាការជាន់ដំបូង (តុលាការរាជធានី-ខេត្ត) ប្រសិនលក្ខខណ្ឌមួយចំនួនដូចបញ្ជាក់ខាងលើត្រូវបានបំពេញនោះ។ កាលណាសម្រេចថាត្រូវប្រើនីតិវិធីបង្គាប់អោយចូលបង្ហាញខ្លួនភ្លាមព្រះរាជអាជ្ញាត្រូវពិនិត្យអត្តសញ្ញាណបុគ្គលដែលគេ

បញ្ជូនមកអោយខ្លួននោះនិងអោយដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើសនិងទទួលចម្លើយរបស់បុគ្គលដែលគេបញ្ជូនមកអោយខ្លួននិងអោយដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលបានចោទប្រកាន់និងឈ្មោះបទល្មើស និងទទួលចម្លើយរបស់បុគ្គលនោះផងដែរ។ ប្រសិនបើសាមីខ្លួនចង់និយាយព្រមទាំងធ្វើនូវកំណត់ហេតុស្ដីអំពីការបង្គាប់អោយចូលខ្លួនភ្លាម។ ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទ ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងដោយអនុលោមទៅតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ មេធាវីដែលជ្រើសរើស ឬចាត់តាំងត្រូវបានទទួលដំណឹងភ្លាម ហើយមេធាវីនិងពិនិត្យសំណុំរឿងនិងធ្វើការទាក់ទងជាមួយជនជាប់ចោទ។ និទ្ទេសនៃទម្រង់ការនេះត្រូវចុះក្នុងកំណត់ហេតុ បើពុំដូច្នោះទេនីតិវិធីត្រូវចាត់ទុកជាមោឃៈ។ នៅក្នុងនីតិវិធីនេះតុលាការសាលាដំបូង ត្រូវបានទទួលបណ្ដឹងតាមកំណត់ហេតុស្ដីពីការបង្គាប់អោយចូលបង្ហាញខ្លួនភ្លាម។ ជាមួយគ្នានេះ ជនជាប់ចោទត្រូវបង្ខាំងទុកដោយកងកំលាំងការពារហូតដល់សាមីខ្លួនចូលបង្ហាញខ្លួន នៅចំពោះមុខតុលាការដែលត្រូវបានបើកសវនាការនៅថ្ងៃនោះតែម្ដង។ ខណៈដែលបង្ហាញខ្លួននេះតុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទបានត្រឹមត្រូវ និងច្បាស់លាស់និងធ្វើរបាយការណ៍ដោយសង្ខេបអំពីរឿងរ៉ាវដែលបានធ្វើការចោទប្រកាន់និងប្រាប់អោយជនជាប់ចោទដឹងថាសាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួនបាន។ ក្នុងករណីដែលជនជាប់ចោទសុំរយៈពេលឬប្រសិនបើតុលាការយល់ឃើញថា រឿងក្ដីនោះមិនអាចធ្វើការជំនុំជម្រះភ្លាមៗបានទេ សំណុំរឿងនេះនឹងត្រូវលើកពេលសវនាការទៅក្រោយទៀតដើម្បីជំនុំជម្រះបាន។ ក្នុងករណីនេះតុលាការមានសិទ្ធិបង្គាប់ អោយឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្នបានដោយអានុភាពនៃសាលក្រមដែលមានសំអាងហេតុហើយដែលបានបញ្ញត្តិពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន[68]។ ម៉្យាងទៀត ចំពោះសាលក្រមលើអង្គសេចក្ដីនៃនីតិវិធីបង្គាប់អោយចូលបង្ហាញខ្លួនភ្លាមនេះ ត្រូវតែប្រកាសនៅក្នុងរយៈពេលមិនអាចលើសពី ២(ពីរ)សប្ដាហ៍ដោយគិតពីថ្ងៃចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ផ្ទុយទៅវិញប្រសិនបើតុលាការបានទទួលពាក្យបណ្ដឹងតាមនីតិវិធីបង្គាប់អោយបង្ហាញខ្លួនភ្លាមនេះ យល់ឃើញថាលក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមមានក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមិនត្រូវបានបំពេញនោះទេ ឬក៏ដោយសារមានភាពសាំញ៉ាំនៃសំណុំរឿងដែលតម្រូវអោយធ្វើការស្រាវជ្រាវបន្ថែមនោះតុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីអោយបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទៅចៅក្រមស៊ើបសួរ។ ខណៈនោះជនជាប់ចោទត្រូវនាំទៅបង្ហាញខ្លួន នៅថ្ងៃនោះតែម្ដងនូវចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេជនជាប់ចោទត្រូវតែដោះលែងអោយមានសេរីភាពវិញដោយឯកឯង[69]។

[68] មាត្រា ៤២នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[69] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក អៀង សំណាងឆ្នាំ២០១៩

## ផ្នែកទី៤៖ យុត្តាធិការស៊ើបសួរ(ចៅក្រមស៊ើបសួរ)

ក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌព្រះរាជាណាក្រកម្ពុជា ចៅក្រមស៊ើបសួរដើរតួយ៉ាងសំខាន់ក្នុងការស្វែងរកការពិត។ តួនាទីយ៉ាងមានសំខាន់របស់ចៅក្រមស៊ើបសួរ គឺការសម្រេចឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នដែលជាសេចក្តីសម្រេចមានលក្ខណៈប៉ះពាល់ខ្លាំងទៅនិងសិទ្ធិសេរីភាពរបស់បុគ្គល។ ហើយនៅក្នុងក្រមនីតិវីធីព្រហ្មទណ្ឌក៏បានបង្កើតអោយមានយុត្តាធិការស៊ើបសួរមានចំនួនពីរគឺ សភាស៊ើបសួរនៅសាលាដំបូងរាជធានី-ខេត្តដែលជាយុត្តាធិការស៊ើបសួរនៃតុលាការជាន់ដំបូង និងសភាស៊ើបសួរសាលាឧទ្ធរណ៏ដែលជាយុត្តាធិការស៊ើបសួររបស់សាលាឧទ្ធរណ៏។ ជាគោលការណ៏នៃការស៊ើបសួរត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបសួររបស់សភាស៊ើបសួរនៃតុលាការជាន់ដំបូង។ ចំណែកឯសភាស៊ើបសួរមានសមត្ថកិច្ចចម្បងធ្វើការជំនុំជម្រះលើពាក្យបណ្តឹងដែលប្រឆាំងនិងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ។ ប៉ុន្តែក្នុងលក្ខខណ្ឌណាមួយចំនួនចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិអោយសភាស៊ើបសួរក៏អាចធ្វើការស៊ើបសួរបានផងដែរ។

មន្ទីរស៊ើបសួរជាយុត្តាធិការនៃសាលាដំបូង មានសិទ្ធិអំណាចស៊ើបសួរនូវគ្រប់រឿងក្តីទាំងឡាយ ដែលបានធ្វើការប្តឹងចោទបើកអោយមានការស៊ើបសួរ ដែលធ្វើតាមរយះដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។ ហើយមន្ទីរស៊ើបសួរនេះ ត្រូវបានបំពេញកិច្ចដោយចៅក្រមស៊ើបសួរមួយរូបដែលត្រូវបានចាត់តាំងឡើងដោយប្រធានតុលាការសាលាដំបូង ដែលជ្រើសរើសចៅក្រមម្នាក់ក្នុងចំណោមចៅក្រមនៃសាលាដំបូងនោះ។ ប្រសិនបើករណីពុំមានចៅក្រមស៊ើបសួរទេ ចៅក្រមផ្សេងទៀតនៃតុលាការដដែលអាចត្រូវបានចាត់តាំងជាបណ្តោះអាសន្នដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ។ មានន័យថាក្នុងករណីដែលចៅក្រមស៊ើបសួរណាម្នាក់ពុំអាចមកបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាកឬដោយសារមានជម្ងឺឬមួយដោយសារមានមូលហេតុដទៃផ្សេងទៀតចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការដដែលត្រូវបានចាត់តាំងជាបណ្តោះអាសន្ន ដោយប្រធានតុលាការ ដើម្បីបំពេញនូវមុខងារស៊ើបសួរ[70]។

កាលណាប្រធានតុលាការ ធ្វើការសម្រេចដោយជ្រើសតាំងចៅក្រមមួយរូបណាមួយអោយបំពេញកិច្ចស៊ើបសួរនោះសេចក្តីសម្រេចនេះគឺបិទផ្លូវតវ៉ា មានន័យថាមិនអាចប្តឹងជំទាស់បានឡើយ។ ជាមួយគ្នានេះចៅក្រមណាមួយទទួលបន្ទុកធ្វើការស៊ើបសួររឿងក្តីណាមួយនោះ ចៅក្រមស៊ើបសួរនោះមិនអាចធ្វើជាចៅក្រមជំនុំជម្រះនូវរឿងក្តីដែលខ្លួនបានស៊ើបសួរនោះទេ។ ហើយចំពោះចៅក្រមស៊ើបសួរ គឺជាចៅក្រមអសនៈដែលមាន

[70] មាត្រា ៤២នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

នាទីបំពេញមុខងារជាចៅក្រមស៊ើបសួរនៅសាលាដំបូងរាជធានី-ខេត្ត។ តាមទ្រឹស្តីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមអសនៈត្រូវបានបែងចែកជាពីរ គឺចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។

### ៤.១. សមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចដែនដីគឺ៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬក៏ទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួន បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។ ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរសាលាឧទ្ធរណ៍ ជាអ្នកមានសិទ្ធិសម្រេចថាចៅក្រមស៊ើបសួររូបណាទទួលភារៈកិច្ចស៊ើបសួរ[71]។

#### ៤.១.១. សមត្ថកិច្ចក្នុងការបើកការស៊ើបសួរ

ការបើកការស៊ើបសួរជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ក្នុងការស្រាវជ្រាវចំពោះអង្គហេតុបទល្មើសព្រហ្មទណ្ឌ។ ចំពោះកិច្ចស៊ើបសួរទាំងអស់ត្រូវបានអនុវត្ត និងដឹកនាំផ្ទាល់ដោយចៅក្រមស៊ើបសួរដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ និងបញ្ជាក់ពីការពិតនៃអង្គហេតុព្រហ្មទណ្ឌចាប់តាំងពីការចាប់ផ្ដើមស្រាវជ្រាវរហូតដល់បិទបញ្ចប់ការស៊ើបសួរ។ ការស៊ើបសួរត្រូវធ្វើឡើងដោយការខានមិនបានចំពោះបទឧក្រិដ្ឋ រីឯបទមជ្ឈឹមការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។

តាមស្មារតីនៃក្រមនីតិវីធីព្រហ្មទណ្ឌការបើកការស៊ើបសួរត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយពីរយ៉ាងគឺ៖ តាមរយៈការស្នើសុំអោយបំពេញកិច្ចស៊ើបសួររបស់តំណាងអយ្យការ និងតាមរយៈការស្នើសុំអោយបំពេញកិច្ចស៊ើបសួររបស់ភាគីរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី។

##### ៤.១.១.១. ការបើកការស៊ើបសួរដោយតំណាងអយ្យការ

ការបើកការស៊ើបសួរដោយតំណាងអយ្យការ គឺចៅក្រមស៊ើបសួរបានទទួលបណ្ដឹងពីអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរដោយព្រះរាជអាជ្ញា។ មានន័យថាចៅក្រមស៊ើបសួរមានសមត្ថកិច្ចធ្វើការស៊ើបសួរតែពីអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរប៉ុណ្ណោះ។ ករណីដែលចៅក្រមស៊ើបសួរបានស៊ើបសួរហើយមានលេចអង្គហេតុថ្មីដែលជាធាតុផ្សំសំខាន់ក្នុងរឿងព្រហ្មទណ្ឌថ្មីមួយទៀត ករណីនេះចៅក្រមស៊ើបសួរត្រូវជូនពត៌មានពីអង្គហេតុថ្មីនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចបើកការស៊ើបសួរពីអង្គហេតុថ្មីនោះ តាមរយៈដីកាបញ្ជូនរឿងអោយស៊ើបសួរបន្ថែមទៅចៅក្រមស៊ើបសួរ។ ពោលគឺចៅក្រមស៊ើបសួរមិនអាចធ្វើការស៊ើបសួរលើអង្គហេតុថ្មី ដោយគ្មានដីកាបញ្ជូនរឿងអោយស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាបានឡើយ។

[71] មាត្រា ១២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ប៉ុន្តែក្នុងករណីចៅក្រមស៊ើបសួរពុំចាំបាច់ស្នើសុំដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទេ បើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសលើអង្គហេតុមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរដំបូង ដែលចៅក្រមស៊ើបសួរកំពុងធ្វើការស៊ើបសួរនោះ។

### ៤.១.១.២. ការបើកការស៊ើបសួរដោយភាគីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី

ការបើកការស៊ើបសួរដោយភាគីជនរងគ្រោះ គឺអាចបើកការស៊ើបសួរបានដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនោះបានផ្តល់សិទ្ធិអោយជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈឹមអាចដាក់ពាក្យប្តឹងជូនចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[72]។ ហើយចំពោះចំណាត់ការទៅលើពាក្យបណ្តឹងដែលប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ កាលណាបានទទួលនូវពាក្យបណ្តឹងនេះហើយចៅក្រមស៊ើបសួរ ធ្វើការកត់សំគាល់ការដាក់ពាក្យបណ្តឹងនោះដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈដីកា[73]។ បន្ទាប់ពីការពិនិត្យឃើញថាមានលក្ខណះត្រឹមត្រូវហើយ ចៅក្រមស៊ើបសួរនិងបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ចំពោះនីតិវីធីបន្តបន្ទាប់ពី ព្រះរាជអាជ្ញាបានពិនិត្យពាក្យបណ្តឹងរួចរាល់ហើយព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរអោយបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរដែលតាមរយៈអំណាចនៃដីកានេះ បានផ្តល់អោយចៅក្រមស៊ើបសួរ មានសមត្ថកិច្ចបើកការស៊ើបសួរបាន។ នៅក្នុងការចេញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរនេះអាចប្រឆាំងទៅនិងអញ្ញាត្តជនទោះបីការធ្វើបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទលើបុគ្គលម្នាក់ឬច្រើននាក់ក៏ដោយ។ ផ្ទុយទៅវិញ ករណីពាក្យបណ្តឹង ប្តឹងក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនេះ នៅពេលព្រះរាជអាជ្ញា បានត្រួតពិនិត្យរួចហើយឃើញថាបណ្តឹងអាជ្ញាបានរលត់ហើយ ឬពាក្យបណ្តឹងនោះមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ដែលជាធាតុផ្សំសំខាន់ៗសម្រាប់ធ្វើការចោទប្រកាន់ទេនោះ ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំអោយចៅក្រមស៊ើបសួរកុំអោយធ្វើការស៊ើបសួរបាន។ ករណីនេះប្រសិនបើចៅក្រមស៊ើបសួរយល់ព្រមថាសម្រេចមិនការស៊ើបសួរទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមានសំអាងហេតុហើយជូនដំណឹងជាបន្ទាន់ទៅដើមបណ្តឹងរដ្ឋប្បវេណី។ កាលណាបើចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរដដែលនោះ ចៅក្រមស៊ើបសួរត្រូវបញ្ជូនដីកាសម្រេចមានសំអាងហេតុនឹងត្រូវជូនដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញា។ ករណីនេះម្ចាស់បណ្តឹងត្រូវបង់ប្រាក់តម្កល់ទុកដោយផ្អែកទៅលើធនធានរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនិងការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមរយៈដីកាសម្រេចនូវចំនួនទឹកប្រាក់ ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាច

[72] មាត្រា ១៣៨នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[73] មាត្រា ១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

លើកលែងមិនអោយបង់ប្រាក់នោះបាន ហើយដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀត ក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីមានលទ្ធភាពបង់ប្រាក់តម្កល់នោះ ខណៈពេលបានបង់ប្រាក់តម្កល់ហើយដើមបណ្តឹងរដ្ឋប្បវេណី នឹងទទួលបានបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រលាបញ្ជី។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង់ប្រាក់តម្កល់ទេ ក្នុងរយៈពេលកំណត់ដោយចៅក្រមស៊ើបសួរទេ(ករណីតម្រូវអោយបង់)ពាក្យបណ្តឹងដែលប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ។ រួចហើយចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចតាមដីការបស់ខ្លួន និងត្រូវបញ្ជូនដំណឹងនេះជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ក្រោយនីតិវិធីត្រូវបានបញ្ចប់ប្រាក់តម្កល់ និងត្រូវបង្វិលទៅអោយសាមីខ្លួនវិញ។ លើកលែងតែមានការប្តឹងដោយបំពាន ឬក៏បណ្តឹងដោយអូសបន្លាយពេលវេលាដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនោះ។ ករណីការស៊ើបសួរត្រូវបានបើកបន្ទាប់ពីមានពាក្យប្តឹងដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបិទតាមរយៈដីកាលើកលែងការចោទប្រកាន់ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីគឺធ្វើឡើងដោយមានរំលោភឬដោយអូសបន្លាយពេលវេលានោះចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចអោយដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណីបាន ប៉ុន្តែចំនួនប្រាក់ដែលត្រូវពិន័យនេះមិនអាចមានចំនួនលើសចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានដាក់តម្កល់នោះឡើយ។ ចំពោះករណីនេះ ដីកាសម្រេចដែលអោយបង់ប្រាក់ពិន័យត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ទន្ទឹមនឹងច្បាប់បានចែងអំពីសិទ្ធិរបស់ជនរងគ្រោះដែលអាចបើកការស៊ើបសួរដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ។ បុគ្គលដែលមានឈ្មោះក្នុងពាក្យបណ្តឹង(បុគ្គលដែលគេប្តឹង)អាចមានសិទ្ធិប្តឹងជួសជុលវិព្យសនកម្មពីអ្នកដែលបានប្តឹងពីខ្លួនវិញបានដែរ។ ក្នុងករណីដីកាសម្រេចលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពរនោះដោយការចេញដីកាសម្រេចនេះ គឺមានមូលហេតុដោយសំអាងលើនីតិវិធីធ្វើឡើយដោយរំលោភឬបានអូសបន្លាយពេលវេលាជាដើមនោះ។ ទន្ទឹមនឹងនេះ ចំពោះនីតិវិធីនៃការដាក់ពាក្យបណ្តឹងវិញ បុគ្គលនោះអាចមានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការជាន់ដំបូងដែលបានបើកការស៊ើបសួរនូវពាក្យបណ្តឹងដែលដើមបណ្តឹងបានធ្វើសកម្មភាពប្តឹងមកខ្លួននោះ[74]។

### ៤.១.២. សមត្ថកិច្ចក្នុងការបិទកិច្ចនៃការស៊ើបសួរ

យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ការបិទការស៊ើបសួរអាចត្រូវបានបិទតាមរយៈមធ្យោបាយពីរយ៉ាងគឺ៖ ការបិទការស៊ើបសួរតាមរយៈដីកាសន្និដ្ឋាន និងការបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ។

[74] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក អៀង សំណាងឆ្នាំ២០១៩

#### ៤.១.២.១. ការបិទការស៊ើបសួរតាមរយៈដីកាសន្និដ្ឋាន

ការបិទការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានក្នុងករណីចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនពត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី។ មាននន័យថា នីតិវិធីនៃការស៊ើបសួរ កាលណាចៅក្រមយល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់ចៅក្រមស៊ើបសួរជូនដំណឹងនេះទៅព្រះរាជអាជ្ញាអោយបានជ្រាប ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី។ ក្នុងករណីនេះ ពីរថ្ងៃក្រោយមកចៅក្រមស៊ើបសួរ និងត្រូវបញ្ជូនសំណុំរឿងទៅអោយព្រះរាជអាជ្ញាដើម្បីពិនិត្យ បើព្រះរាជអាជ្ញាយល់ឃើញថាមានកត្តាចាំបាច់ត្រូវធ្វើការស៊ើបសួរជាថ្មីទៀតនោះ ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំអោយចៅក្រមស៊ើបសួរ ធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាវាមានប្រយោជន៏នូវគ្រប់ពេលវេលានៃកិច្ចស៊ើបសួរ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួររូបនេះត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដោយមានសំអាងហេតុហើយត្រូវជូនដំណឹងទៅដល់ព្រះរាជអាជ្ញាក្នុងយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ឬក្នុងករណីចៅក្រមមិនបានសម្រេចនៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៏។ មិនត្រឹមតែប៉ុណ្ណោះនៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទក៏អាចមានសិទ្ធិស្នើសុំអោយចៅក្រមស៊ើបសួរសួរចម្លើយ ស្តាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សីសួរតទល់គ្នាស្របទៅតាមគោលការណ៏ចំពោះមុខដូចដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬអាចចុះទៅដល់ទីកន្លែងកើតហេតុដើម្បីពិនិត្យ។ ពាក្យស្នើសុំនេះត្រូវធ្វើលាយលក្ខណ៏អក្សរព្រមទាំងមានសំអាងហេតុច្បាស់លាស់។ ប៉ុន្តែករណីចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យស្នើសុំនេះទេចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងចិរវេលា១(មួយ)ខែបន្ទាប់ពីខ្លួនបានទទួលពាក្យស្នើសុំដីកានេះចៅក្រមស៊ើបសួរសម្រេចត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញានិងដល់ជនដែលត្រូវចោទ។ ករណីចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ១(មួយ)ខែជនត្រូវចោទមានសិទ្ធិធ្វើការប្ដឹងដោយផ្ទាល់តាមរយៈពាក្យស្នើសុំទៅសភាស៊ើបសួរសាលាឧទ្ធរណ៏។ ជាមួយគ្នានេះ គ្រប់ពេលវេលានៃការស៊ើបសួរដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិស្នើសុំដល់ចៅក្រមស៊ើបសួរអោយស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សីសួរចម្លើយជនត្រូវចោទតទល់គ្នា ឬក៏ចុះទៅដល់ទីកន្លែងបានដោយដាក់ពាក្យសុំនោះត្រូវធ្វើជាលាយលក្ខណ៏អក្សរហើយមានសំអាងហេតុនៅក្នុងចំណាត់ការលើបណ្ដឹងនោះ ករណីចៅក្រមស៊ើបសួរមិនព្រមធ្វើតាមនូវពាក្យស្នើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធក្នុងរយៈពេល១(មួយ)ខែក្រោយពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុហើយត្រូវជូនដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី[75]។

[75] មាត្រា ២៤៦នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

### ៤.១.២.២. ការបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ

ការបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ គឺនៅពេលចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរនោះត្រូវបានបញ្ចប់នោះ ចៅក្រមស៊ើបសួរនិងចេញដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះឬដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះឬដីកាលើកលែងការចោទប្រកាន់ក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុចៅក្រមស៊ើបសួរនិងសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ចំណែកឯដីកាសម្រេចនេះនិងរៀបរាប់រាល់អំពើដែលត្រូវបានចោទប្រកាន់ព្រមទាំងឈ្មោះបទល្មើសតាមច្បាប់ដែលបានកំណត់។ ផ្ទុយទៅវិញក្នុងករណីដូចខាងក្រោមនេះចៅក្រមស៊ើបសួរអាចសម្រេចចេញដីកាលើកលែងការចោទប្រកាន់បាន កាលណាអំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈឹម ឬបទលហុឬកាលណាជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។ ដីកាដំណោះស្រាយជានិច្ចជាកាលត្រូវតែមានសំអាងហេតុចៅក្រមស៊ើបសួរមិនត្រូវជាកាតព្វកិច្ចត្រូវគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ មានន័យថាអំណាចនៃដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា មិនមានសិទ្ធិចាប់បង្ខំអោយចៅក្រមស៊ើបសួរត្រូវតែធ្វើតាមនោះទេ។ ម៉្យាងទៀតដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ អាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះបទល្មើសមួយចំនួន កាលណាបទល្មើសមានធាតុផ្សំគ្រប់គ្រាន់អាចធ្វើការជំនុំជម្រះបាន។ ករណីនេះក្រោយពីដីកាលើកលែងការចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរបើមានលេចឡើងនូវបន្ទុកថ្មី ការស៊ើបសួរអាចត្រូវបានបើកធ្វើឡើងវិញតាមរយៈការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា។ នៅពេលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយត្រូវជូនដំណឹងនូវក្នុងរយៈពេលយ៉ាងខ្លីបំផុត ជូនដល់ព្រះរាជអាជ្ញាជនត្រូវចោទព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ម៉្យាងវិញទៀតនៅក្នុងដីកាដំណោះស្រាយចៅក្រមស៊ើបសួរ សម្រេចពីការប្រគល់សងទៅអោយម្ចាស់ដើមវិញនូវវត្ថុដែលបានចាប់យក។ ករណីនេះ ព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់អោយប្រគល់វត្ថុទាំងនោះ ពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ។ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះ គ្មានការជំទាស់អ្វីពិតប្រាកដប្រជាទេ។ ផ្ទុយទៅវិញ ចំពោះវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិដូចជា អាវុធឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់មិនអាចប្រគល់អោយវិញបាន។ ពោលគឺវត្ថុទាំងនោះត្រូវអូសរឹបទុកជាសម្បត្តិរបស់រដ្ឋឬត្រូវបំផ្លាញចោល។ ករណីមិនព្រមប្រគល់អោយវិញទេ អ្នកប្តឹងមានប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន។ ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាគ្មានសមត្ថកិច្ចក្នុងការប្រគល់ទេ កាលណាមានការចោទប្រកាន់ធ្វើឡើងនៅចំពោះយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ។

ករណីជនត្រូវចោទកំពុងស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ឬដាក់អោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ កាលណាចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយមានសេចក្តីសម្រេចដោះលែងជនត្រូវ

ចោទ ជនដែលជាប់ឃុំបណ្ដោះអាសន្នជននោះត្រូវបានរក្សាទុកក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់ធ្វើបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា។ លើកលែងតែព្រះរាជអាជ្ញាយល់ព្រមដោះលែងជនត្រូវចោទនោះភ្លាម ដោយសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញាត្រូវធ្វើជាលាយលក្ខណ៍អក្សរត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។ ដូច្នេះសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចំពោះដីកាដំណោះស្រាយដោយលើកលែងការចោទប្រកាន់ដល់ជនត្រូវចោទកំពុងឃុំខ្លួន ហើយអានុភាពនៃដីកានេះនាំអោយដោះលែងជនត្រូវចោទដែលជាប់ឃុំខ្លួននោះ។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាសម្រេចប្ដឹងឧទ្ធរណ៍ទៅនិងដីកាដោះស្រាយរបស់ចៅក្រមស៊ើបសួរដែលសម្រេចលើកលែងនូវការចោទប្រកាន់ចំពោះជនត្រូវចោទនោះ ករណីនេះជនត្រូវចោទ និងត្រូវបានរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់សភាស៊ើបសួរសាលាឧទ្ធរណ៍សម្រេច[76]។

## ៤.២. វិធានការនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

វិធានការនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ គឺជាឧបករណ៍ជំនួយដល់ចៅក្រមស៊ើបសួរក្នុងការស្វែងរកស្រាវជ្រាវនូវការពិតដែលជាប្រយោជន៍ដល់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរដែលក្នុងនោះមានវិធានការណ៍ជាច្រើនដូចជា៖ ការជូនដំណឹងពីការដាក់អោយស្ថិតក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ការស្ដាប់ចម្លើយសាក្សី ការឆែកឆេរនិងការចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ ការស្ដាប់ទូរស័ព្ទ ការធ្វើដីកាចាត់អោយស៊ើបសួរជំនួស។

### ៤.២.១. ការជូនដំណឹងពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ

ចៅក្រមស៊ើបសួរត្រូវតែដាក់អោយស្ថិតក្រោមការពិនិត្យនូវបុគ្គលដែលមានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។ ប៉ុន្តែចៅក្រមស៊ើបសួរមានអំណាចដាក់អោយស្ថិតក្រោមការពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាខ្លាំងថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរក៏ដោយ។ ហើយម្យ៉ាងវិញទៀតចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈ ជាចារី ជាអ្នកផ្ដើមគំនិត ឬជាអ្នកផ្សំគំនិត[77]។ ការជូនដំណឹងអំពីការដាក់អោយស្ថិតនៅក្រោមការពិនិត្យ នូវពេលចូលបង្ហាញខ្លួនលើកដំបូងចៅក្រមស៊ើបសួរ ពិនិត្យអត្តសញ្ញាណរបស់ជនជាប់ចោទ ប្រាប់ជនជាប់ចោទពីរឿងរ៉ាវដែលចោទប្រកាន់និងប្រាប់ពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ បន្ទាប់មកចៅក្រមស៊ើបសួរនិងប្រាប់ជនត្រូវចោទថាខ្លួនអាចមានសិទ្ធិឆ្លើយ ឬសិទ្ធិមិនឆ្លើយបានដោយសេរីចំណែកឯនិទ្ទេសស្ដីពីការប្រាប់នេះ គឺត្រូវចុះក្នុងកំណត់ហេតុពេលដែលជនត្រូវចោទចូលបង្ហាញលើកដំបូង។ ករណីប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះចៅក្រមស៊ើបសួរត្រូវ

[76] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក អៀង សំណាងឆ្នាំ២០១៩

[77] មាត្រា ២៦នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ទទួលចម្លើយនោះភ្លាម។ ម្យ៉ាងវិញទៀតចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទអោយបានដឹងពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬការស្នើសុំអោយចាត់តាំងមេធាវីអោយខ្លួនដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ដោយឡែកចំពោះជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ ក្នុងករណីមិនមានការជ្រើសរើសដោយជនត្រូវចោទជាអនីតិជនទេ មេធាវីនិងត្រូវធ្វើការចាត់តាំងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយជនត្រូវចោទដែលនៅក្រៅឃុំត្រូវបានប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរបានដឹងអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថាៈ

- ខ្លួនត្រូវតែជូនពត៌មានដល់ចៅក្រមស៊ើបសួរនៅពេលដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន
- គ្រប់ការអោយដំណឹងបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយដែលប្រកាសឡើងដោយជនត្រូវចោទនោះត្រូវចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់។

ម៉្យាងវិញទៀត ចំពោះការអោយដំណឹងព្រមទាំងការប្រកាសស្តីអំពីការផ្លាល់ប្តូរអាសយដ្ឋាននោះត្រូវចុះក្នុងកំណត់ហេតុនៅពេលបង្ហាញខ្លួនជាលើកដំបូងផងដែរ[78]។

### ៤.២.២. ការសួរចម្លើយជនត្រូវចោទ

ចៅក្រមស៊ើបសួរមានសិទ្ធិសួរចម្លើយជនត្រូវចោទដែលអាចធ្វើនៅចំពោះមុខមេធាវីរបស់ជនត្រូវចោទ។ ដូច្នេះកាលណាជនត្រូវចោទមានមេធាវីអម ហើយចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុតចំនួន៥ (ប្រាំ)ថ្ងៃមុនការសួរចម្លើយ។ ការសួរចម្លើយជនត្រូវចោទដោយស្ថិតក្នុងចិរវេលានេះអាចអោយមេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី។ ប៉ុន្តែបើចៅក្រមស៊ើបសួរបានកោះហៅមេធាវីបានត្រឹមត្រូវរួចហើយ ហើយមេធាវីមិនបានចូលបង្ហាញខ្លួនក្នុងថ្ងៃ និងម៉ោងបានកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទបានដោយគ្មានវត្តមានមេធាវីបានគ្រាន់តែចុះនិទ្ទេសស្តីពីអវត្តមានមេធាវីក្នុងកំណត់ហេតុសួរចម្លើយ។ ក្នុងករណីពិសេសចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបង្ហាញឆន្ទៈបោះបង់នេះត្រូវចុះនៅក្នុងកំណត់ហេតុមួយផ្សេងទៀតពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ។ ក្នុងករណីបន្ទាន់មួយទៀត ការសួរចម្លើយជនត្រូវចោទអាចធ្វើឡើងដោយមិនបាច់កោះហៅមេធាវីក៏បានដែរដូចជា ករណីមានភាពបន្ទាន់ដែលមានគ្រោះថ្នាក់ហួតបណ្តាលអោយស្លាប់ ឬបណ្តាលមកពីមានការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង[79] ហើយប្រភេទនៃភាពបន្ទាន់នេះត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ទន្ទឹមនឹងនេះ នៅពេលដែលចៅក្រមស៊ើបសួរកំពុងសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏មានវត្តមានដែរហើយអាចលើកសំណួរទៅជនត្រូវចោទបានបន្ទាប់ពីមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងក្រមនីតិវិធី

[78] មាត្រា ១៤៣នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[79] មាត្រា ១៤៥នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ព្រហ្មទណ្ឌក៏បានផ្តល់សិទ្ធិអោយជនត្រូវចោទស្នើសុំចៅក្រមស៊ើបសួរសួរចម្លើយខ្លួន ឬតទល់គ្នាបានហើយ សម្រាប់រយៈពេលអប្បបរមានៃការសួរចម្លើយជនត្រូវចោទវិញ កាលណាចិរវេលា ៤(បួន)ខែបានកន្លងផុតទៅ ដោយគិតចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូងដោយជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ហើយប្រសិនបើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងចិរវេលា ១(មួយ)ខែគិតចាប់ពីថ្ងៃបន្ទាប់ពីការស្នើសុំទេ ជនត្រូវចោទអាចធ្វើការប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរសាលាឧទ្ធរណ៍ដែលទទួលចម្លើយនេះដោយខ្លួនឯង។ ក្នុងករណីនេះ កំណត់ហេតុសួរចម្លើយនេះត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ[80]។

### ៤.២.៣. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ចៅក្រមស៊ើបសួរ មានសិទ្ធិសួរចម្លើយជនត្រូវចោទក្នុងពេលបំពេញកិច្ចស៊ើបសួររបស់ខ្លួន ហើយក៏តម្រូវអោយចៅក្រមស៊ើបសួរស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ហើយតម្រូវអោយធ្វើឡើងនូវចំពោះមុខមេធាវីដោយមានការចូលរួមពីព្រះរាជអាជ្ញា។ ចំពោះមេធាវីនិងព្រះរាជអាជ្ញាក៏អាចធ្វើការលើកសំណួរបានផងដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរចេញដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី។ សម្រាប់មេធាវីវិញនូវក្នុងការអនុវត្តចៅក្រមស៊ើបសួរធ្វើលិខិតអញ្ជើញមេធាវី ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត៥(ប្រាំ)ថ្ងៃមុនការស្តាប់ចម្លើយ។ នៅក្នុងចិរវេលានេះ មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនចូលមកបង្ហាញខ្លួននៅថ្ងៃនិងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានរបស់មេធាវីបានហើយត្រូវតែចុះនិទ្ទេសស្តីពីអវត្តមានរបស់មេធាវីនេះ ត្រូវចុះនូវក្នុងកំណត់ហេតុស្តាប់ចម្លើយ។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានដោយមិនបាច់កោះហៅមេធាវី ប្រសិនបើបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន។ ការបោះបង់ចោលនេះ ត្រូវចុះនិទ្ទេសនូវក្នុងកំណត់ហេតុមួយដោយឡែកពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីបន្ទាន់នោះ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយមិនចាំបាច់កោះហៅមេធាវីក៏បានដែរដូចជា ក្នុងករណីមានភាពបន្ទាន់ដែលមានគ្រោះថ្នាក់ហួតដែលបណ្តាលអោយស្លាប់ ឬបណ្តាលមកពីមានការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់នេះត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។

[80] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក អៀង សំណាងឆ្នាំ២០១៩

### ៤.២.៤. ការស្តាប់ចម្លើយសាក្សី

ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលចម្លើយទាំងនោះអាចមានប្រយោជន៍នូវក្នុងការសំដែងអោយឃើញការពិត។ ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីដាច់ពីគ្នាដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរក៏អាចតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផងបានដែរ។ បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សីត្រូវតែមកបង្ហាញខ្លួន។ ក្នុងករណីបុគ្គលនោះរឹងទទឹង មិនព្រមចូលមកបង្ហាញខ្លួននោះចៅក្រមស៊ើបសួរអាចសុំអោយកងកម្លាំងសាធារណៈបង្ខំសាក្សីនេះអោយចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាអោយចូលបង្ហាញខ្លួន បញ្ជានេះត្រូវតែមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានការបោះត្រាផង។ សាក្សីមុននិងឆ្លើយសំណួរ សាក្សីម្នាក់ៗត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិតដែលខ្លួនបានដឹង។ ទម្រង់នៃសម្បថត្រូវធ្វើដូចមានកំណត់នូវក្នុងឧបសម្ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជាមួយគ្នានេះករណីចាំបាច់ ចៅក្រមស៊ើបសួរត្រូវហៅអ្នកបកប្រែដើម្បីស្តាប់ចម្លើយសាក្សី។ មុននិងបំពេញការងារជាអ្នកបកប្រែត្រូវស្បថតាមសាសនាឬជំនឿរបស់ខ្លួន ហើយអ្នកបកប្រែនេះមិនត្រូវបានជ្រើសរើសក្នុងចំណោម ចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬសាក្សីទោះបីក្នុងករណីណាក៏ដោយ។ ជាគោលការណ៏សាក្សីទាំងអស់ មុននិងផ្តល់ចម្លើយនោះត្រូវធ្វើសម្បថជាមុន មុននិងផ្តល់ចម្លើយ។ លើកលែងតែសាក្សីមួយចំនួនដែលត្រូវបានស្តាប់ចម្លើយដោយមិនចាំបាច់ធ្វើសម្បថទេ[81]។

### ៤.២.៥. ការឆែកឆេរ និងការចាប់យកវត្ថុតាង

ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការឆែកឆេរ និងការចាប់យកវត្ថុតាងបាន។ ការឆែកឆេរ និងការចាប់យកវត្ថុតាងនោះចៅក្រមស៊ើបសួរត្រូវធ្វើនូវចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែងទេត្រូវធ្វើនូវចំពោះមុខសាក្សី ២(ពីរ)នាក់ដែលចៅក្រមស៊ើបសួរបានចាត់តាំង។ សាក្សីនោះមិនអាចជានគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រត្តិបត្តិក្នុងការឆែកឆេរនោះឡើយ។ ការឆែកឆេរមិនអាចចាប់ផ្តើមមុខម៉ោង ៦(ប្រាំមួយ)ព្រឹកនិងក្រោយម៉ោង ១៨(ដប់ប្រាំបី)បានទេលើកលែងតែះ

- ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណៈជន
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។

ប្រសិនបើជាការឆែកឆេរក្នុងការិយាល័យមេធាវី តម្រូវអោយធ្វើនៅចំពោះមុខគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជីរួមជាមួយគ្នាអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២(ពីរ)នាក់។ កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្ត

[81] មាត្រា ១៥៣,១៥៤,១៥៥,១៥៦នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

សញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែងឬសាក្សីនីមួយៗ កាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូនៃប្រធានគណៈមេធាវី[82]។

ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាងបានតែត្រូវបិទស្លាកបោះត្រាលើវត្ថុតាងនោះ បន្ទាប់ពីបានបង្ហាញវត្ថុដែលចាប់យកនោះដល់អ្នកកាន់កាប់ទីកន្លែង ឬក៏សាក្សីទាំងពីរនាក់រួចមក ចៅក្រមស៊ើបសួរនិងធ្វើការកំណត់ហេតុស្តីពីការចាប់យកវត្ថុនោះ ដែលរួមមានបញ្ជីសារពើភណ្ឌនៃការចាប់យក។ កំណត់ហេតុស្តីពីការចាប់នេះ ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ ក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២(ពីរ) នាក់ ហើយកំណត់ហេតុនេះត្រូវមានចុះនិទ្ទេសពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗនោះផងដែរ។ ម៉្យាងវិញទៀត ចៅក្រមស៊ើបសួរក៏ធ្វើការប្រគល់វត្ថុដែលចាប់យកទៅម្ចាស់ដើមវិញផងដែរ។ នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចសងទៅអោយម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុក្រោយពីទទួលបានមតិអំពីព្រះរាជអាជ្ញា។ ម៉្យាងទៀតដីកាសម្រេចត្រូវអោយដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន។ ករណីវត្ថុដែលបានចាប់យកនោះជាវត្ថុដែលមិនគួរប្រគល់សងទៅអោយអ្នកប្តឹងសុំវិញទេ អាចជាវត្ថុមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជា អាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវបានប្រគល់សងទៅអោយសាមីខ្លួនបានទេ ដោយវត្ថុទាំងឡាយនោះត្រូវបានរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ ឬត្រូវបំផ្លាញចោល។

### ៤.២.៦. ការធ្វើកោសលវិច័យ

ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការស្នើសុំអោយធ្វើកោសលវិច័យក្នុងករណីដែលកោសលវិច័យមានបញ្ហាបច្ចេកទេសកើតឡើងចៅក្រមស៊ើបសួរអាចបង្គាប់អោយធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យរបស់សុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដោយមានសំអាងហេតុ ហើយដីកានោះត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា។ ប្រសិនបើពាក្យនោះចេញមកពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដីកាសម្រេចនេះត្រូវជូនដំណឹងអោយដល់អ្នកប្តឹងសុំជាបន្ទាន់ ហើយនូវពេលចេញដីកាចាត់តាំងអ្នកជំនាញត្រូវបញ្ជាក់បេសកកម្ម និងរយៈពេលដែលត្រូវបំពេញបេសកកម្ម ប៉ុន្តែអ្នកជំនាញអាចអនុញ្ញាតអោយពន្យារពេលបាន។ ក្នុងករណីត្រូវប្រគល់វត្ថុចាប់យកជូនអ្នកជំនាញ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុចាប់យក[83]។ ចៅក្រមស៊ើបសួរចាត់តាំងអ្នកជំនាញដែលមានក្នុងបញ្ជីថ្នាក់

[82] មាត្រា ១៥៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[83] មាត្រា ១៦៥នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ជាតិនៃអ្នកជំនាញដែលរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ អ្នកជំនាញត្រូវតែស្បថនូវចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញដើម្បីជំនួយដល់ភាពស្មោះត្រង់ និងស្វែងរកយុត្តិធម៌។

### ៤.២.៧. ការស្តាប់ទូរស័ព្ទ

ចៅក្រមស៊ើបសួរ គឺអាចធ្វើការស្តាប់ទូរស័ព្ទបានក្នុងករណីចាំបាច់ដោយមានគោលបំណងស្វែងរកអោយឃើញការពិតចៅក្រមស៊ើបសួរអាចបង្គាប់អោយស្តាប់ ឬថតចម្លងការសន្ទនាតាមទូរស័ព្ទបាន។ ម៉្យាងទៀតវិញចៅក្រមស៊ើបសួរអាចមានសិទ្ធិស្នើសុំទៅអង្គភាពសាធារណៈមានជំនាញវិជ្ជាជីវៈ ឬគ្រប់មន្ត្រីរាជការជំនាញទាំងឧបករណ៍បច្ចេកទេស និងធ្វើការថតដែលចៅក្រមស៊ើបសួរ និងធ្វើការបញ្ជាក់ក្នុងដីកាសម្រេចរបស់ខ្លួនពីប្រភេទនៃទំនាក់ទំនងត្រូវចាប់រយៈពេលត្រូវអនុវត្តបេសកកម្ម។ ករណីនេះអង្គភាពសាធារណៈ មន្ត្រីរាជការដែលត្រូវបានចាត់តាំង ត្រូវបំពេញតាមពាក្យស្នើសុំរបស់ចៅក្រមស៊ើបសួរ។ ការអនុវត្តបេសកម្មវិញអង្គភាពសាធារណៈគ្រប់មន្ត្រីរាជការដែលបានចាត់តាំងត្រូវជូនពត៌មានពីការប្រព្រឹត្តការងារ និងការលំបាករបស់ខ្លួនជូនទៅចៅក្រមស៊ើបសួរ។ បន្ទាប់ពីបានបំពេញបេសកកម្មរួចរាល់ហើយ អង្គភាពសាធារណៈឬមន្ត្រីរាជការថតចម្លងជាលាយលក្ខណ៍អក្សរត្រូវផ្ទះបញ្ជាំងយ៉ាងត្រឹមត្រូវ អំពីខ្លឹមសារនៃសម្លេងដែលថតនោះប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាកផងដែរ។ ហើយគ្រប់ពេលវេលាចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតនោះបាន។ ការចូលទៅក្នុងកន្លែងទាំងនេះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេ ទោះបីជាកន្លែងយោធាក៏ដោយ។ ចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមរយៈដីកាចាត់អោយស៊ើបសួរជំនួសបានផងដែរ[84]។

### ៤.២.៨. ការចាត់ឲ្យស៊ើបសួរជំនួស

នៅក្នុងការបំពេញភារៈកិច្ចរបស់ខ្លួនចៅក្រមស៊ើបសួរអាចជួបប្រទះ និងឧបសគ្គផ្សេងៗដែលនាំអោយចៅក្រមស៊ើបសួរពុំអាចបំពេញភារៈកិច្ចដោយខ្លួនឯងបានដែលជាហេតុនាំអោយចៅក្រមស៊ើបសួរ ប្រគល់សិទ្ធិអោយទៅអ្នកផ្សេងបំពេញភារៈកិច្ចជំនួសខ្លួន។ តាមរយៈដីកាចាត់អោយស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិអោយចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀតមន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរចេញដីកាចាត់អោយស៊ើបសួរជំនួស ដូច្នេះដីកាចាត់អោយស៊ើបសួរជំនួសត្រូវបញ្ជាក់ពីកិច្ចដែលត្រូវធ្វើដែលទាក់ទងដោយផ្ទាល់ជាមួយនឹងបទល្មើសដែលត្រូវចោទប្រកាន់ និងត្រូវណែនាំអោយបានច្បាស់លាស់ពោល គឺមិនត្រូវការប្រគល់សិទ្ធិជាលក្ខណៈទូទៅទេ ហើយថែមទាំងកំណត់ថិរវេលាដែលត្រូវអនុវត្តដីកាអោយស៊ើបសួរជំនួសទៀតផង។ ចៅក្រមស៊ើប

[84] មាត្រា ១៧២នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

សួរអាចដកហូតដីកានេះបានគ្រប់ពេលវេលា[85]។ ជាទូទៅរាល់កិច្ចការស៊ើបសួរទាំងអាចជាកម្មវត្ថុនៃដីកាចាត់អោយស៊ើបសួរជំនួស។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានដាក់កំរិតខ្លះ សម្រាប់ការប្រគល់សិទ្ធិមន្ត្រីនគរបាលយុត្តិធម៌។ ចៅក្រមស៊ើបសួរមិនអាចប្រគល់សិទ្ធិអោយមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបសួរជំនួសខ្លួនទាក់ទិនជាមួយការសួរចម្លើយជនត្រូវចោទ និងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងការបំពេញកិច្ចស៊ើបសួរជំនួសចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ដែលស្តាប់ចម្លើយស៊ើបសួរសាក្សីត្រូវអោយសាក្សីនោះស្បថជាមុនសិន មុននឹងស្តាប់ចម្លើយ។ ប្រសិនបើមានការឃាត់ខ្លួនក្នុងក្របខ័ណ្ឌនៃការអនុវត្តដីការចាត់អោយស៊ើបសួរជំនួស អំណាចដែលប្រគល់អោយព្រះរាជអាជ្ញាត្រូវប្រើប្រាស់ដោយចៅក្រមស៊ើបសួរ។

### ៤.៣. វិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ

វិធានការនិរន្តរាយចៅក្រមស៊ើបសួរ គឺជាឧបករណ៏គត្តិយុត្តិជំនួសដល់ដំណើរការក្នុងរឿងក្តីព្រហ្មទណ្ឌដល់ចៅក្រមស៊ើបសួរនៅក្នុងពេលបំពេញកិច្ចស៊ើបសួររបស់ខ្លួន ដើម្បីស្វែងរកការពិតនោះចៅក្រមស៊ើបសួរមានសិទ្ធិកោះហៅអញ្ជើញបុគ្គលណាមួយដែលមិនព្រមឆ្លើយតបតាមការកោះរបស់ខ្លួន ដោយការប្រើប្រាស់សិទ្ធិនូវក្នុងដីកាដែលជាវិធានការនិរន្តរាយ។ វិធាននិរន្តរាយដូចជា៖ ដីកាបង្គាប់អោយចូលខ្លួន ដីកាបង្គាប់អោយនាំខ្លួន ដីកាបង្គាប់អោយចាប់ខ្លួន ការស្នើសុំអោយបំពេញកិច្ចស៊ើបសួរ។

#### ៤.៣.១. ដីកាបង្គាប់ឲ្យចូលខ្លួន

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចចេញដីកាបង្គាប់អោយចូលខ្លួន គឺមានន័យថាជាការបញ្ជាបុគ្គលម្នាក់អោយចូលទៅបង្ហាញខ្លួននៅមុខរបស់ខ្លួនបាន។ ដីកានោះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ។ ចំពោះនិទ្ទេសដែលត្រូវចុះលើដីកាបង្គាប់អោយចូលខ្លួនមាននិទ្ទេសដូចជា៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្រ្កាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននូវមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមស៊ើបសួរដែលចេញដីកា។

មិនត្រឹមតែប៉ុណ្ណោះដីកាបង្គាប់អោយចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរមានបោះត្រាផង។ ហើយចំពោះដីកាបង្គាប់អោយចូលខ្លួនត្រូវអោយដំណឹងដល់បុគ្គលដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា[86]។ ពោលគឺមន្ត្រីនគរបាលយុត្តិធម៌

[85] មាត្រា ១៧៣នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[86] មាត្រា ១៨៨នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាជាអ្នកមានភារៈកិច្ចអនុវត្តដីកាបង្គាប់អោយចូលខ្លួននោះ។ នៅពេលអនុវត្តបុគ្គលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ចំពោះដើមដីកានេះត្រូវបញ្ជូនទៅអោយចៅក្រមស៊ើបសួរវិញ។

### ៤.៣.២. ដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់អោយនាំខ្លួន គឺជាការបញ្ជាដល់កម្លាំងសាធារណៈអោយចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចត្រូវចេញលើតែជនត្រូវចោទ ឬលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព និទ្ទេសដែលចុះក្នុងដីកាបង្គាប់អោយនាំខ្លួននេះមានដូចជា អត្តសញ្ញាណនៃបុគ្គលពាក់ព័ន្ធ បទល្មើសចោទប្រកាន់ អត្ថបទច្បាប់កំណត់ និងបង្ក្រាបបទល្មើសនេះ ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។ មិនត្រឹមតែប៉ុណ្ណោះដីកានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខា ដោយចៅក្រមស៊ើបសួរព្រមទាំងមានបោះត្រា ។

### ៤.៣.៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន

ដីកាបង្គាប់អោយចាប់ខ្លួន គឺជាការបញ្ជាដល់កងកម្លាំងសាធារណៈស្រាវជ្រាវរកអោយចាប់ខ្លួន និងអោយនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនអោយទទួល និងឃុំខ្លួនបុគ្គលនោះផងដែរ[87]។ ដីកាបង្គាប់អោយចាប់ខ្លួនអាចចេញលើជនត្រូវចោទ ឬបុគ្គលណាដែលមានតម្រុយមានពិរុទ្ធភាព។

ចៅក្រមស៊ើបសួរ គឺអាចចេញដីកាបង្គាប់អោយចាប់ខ្លួនបុគ្គលណាម្នាក់បាន លុះត្រាតែបាននូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬមជ្ឈឹមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។
- បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

មុននិងចេញដីកាបង្គាប់អោយចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញាមុនសិន។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានមូលហេតុច្បាស់លាស់។ ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញាហើយ។ ព្រះរាជអាជ្ញា ធានារ៉ាប់រងការផ្សព្វផ្សាយដីកាបង្គាប់អោយចាប់ខ្លួននេះ រីឯនិទ្ទេសដែលមានចុះក្នុងដីកាបង្គាប់អោយចាប់ខ្លួន ត្រូវចុះនូវពត៌មានដូចខាងក្រោម៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមស៊ើបសួរដែលចេញដីកា។

[87] មាត្រា ១៩៦នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ដីកាបង្គាប់អោយចាប់ខ្លួន គឺត្រូវមានចុះកាលបរិច្ឆេទនិងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង។

### ៤.៣.៤. ការបង្គាប់ឲ្យឃុំខ្លួន

ដីកាបង្គាប់អោយឃុំខ្លួនជាបញ្ជារបស់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនអោយទទួលនិងឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរអាចចេញដីកាឃុំខ្លួននេះ លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃការសម្រេចអោយឃុំខ្លួនបណ្តោះអាសន្ននេះ។ ខ្លឹមសារនេះហាក់ដូចជា ហាមឃាត់មិនអោយជនត្រូវចោទមានសេរីភាពក្នុងការដើរហើរ ព្រោះជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព។ ប៉ុន្តែនៅក្នុងករណីពិសេសជនត្រូវចោទអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ននេះ ជាបញ្ញត្តិដែលចែងអំពីអំណាចរបស់ចៅក្រមស៊ើបសួរ។ ទន្ទឹមនិងនេះមិនមែនមានន័យថាគ្រប់ជនត្រូវចោទសុទ្ធតែត្រូវបានឃុំខ្លួនបណ្តោះអាសន្នបានឡើយ។ មានន័យថាការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែនៅក្នុងករណីចោទប្រកាន់អំពីបទឧក្រិដ្ឋ ឬមជ្ឈិមដែលបានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើឬលើសមួយឆ្នាំប៉ុណ្ណោះ[៨៨]។

#### ៤.៣.៤.១. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់ដូចជា៖

- ដើម្បីបញ្ចប់បទល្មើសឬបង្ការបទល្មើសកុំអោយកើតសារជាថ្មី។
- ដើម្បីរារាំងកុំអោយមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំអោយមានការត្រូវរ៉ូវគ្នារវាងជនដែលត្រូវចោទនិងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាងឬតម្រុយជាសម្ភារៈ។
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ដើម្បីការពារសន្តិសុខអោយជនត្រូវចោទ។

ដើម្បីធានានិងរក្សានូវសណ្តាប់ធ្នាប់សាធារណៈ កុំអោយមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

#### ៤.៣.៤.២. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នបែងចែកជាពីរ គឺការឃុំខ្លួនលើអនីតិជន និងលើនីតិជន។

[៨៨] មាត្រា ២០៨នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

**ក. ការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជន**

ជាគោលការណ៍ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមានភាពខុសគ្នារវាងអនីតិជននិងនីតិជន។ ចំពោះលើអនីតិជនមានអាយុតិចជាង ១៤(ដប់បួន)ឆ្នាំមិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ ដោយចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះទៅអោយឪពុកម្តាយ ឬអាណាព្យាបាលហើយកាលណាបើគ្មានអាណាព្យាបាលទេត្រូវប្រគល់អោយមជ្ឈមណ្ឌលអប់រំជាបណ្តោះអាសន្នរងចាំសេចក្តីសម្រេចរបស់តុលាការ។

ដោយឡែកចំពោះអនីតិជនមានអាយុ ១៤(ដប់បួន)ឆ្នាំដល់ក្រោម ១៦(ដប់ប្រាំមួយ)ឆ្នាំអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នប្រសិនបើអនីតិជនបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយ។ ការកំណត់រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នត្រូវបានកំណត់ដូចតទៅ៖

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤(បួន)ខែបានទេ កាលណាអនីតិជនមានអាយុតិចជាង១៦(ដប់ប្រាំមួយ)ឆ្នាំ។
- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦(ប្រាំមួយ)ខែបានទេ កាលណាអនីតិជនមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំដល់ ១៨(ដប់ប្រាំបី)ឆ្នាំ។

ចំពោះអនីតិជនដែលមានអាយុ ១៤(ដប់បួន)ឆ្នាំដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំអាចត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន ប្រសិនបើអនីតិជននោះបានប្រព្រឹត្តបទមជ្ឈិមណាមួយនោះ។ ការឃុំខ្លួនបណ្តោះអាសន្ននោះត្រូវបានកំណត់ដូចតទៅៈ

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២(ពីរ)ខែបានទេ កាលណាអនីតិជនមានអាយុតិចជាង ១៦(ដប់ប្រាំមួយ)ឆ្នាំ។
- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤(បួន)ខែបានទេ កាលណាអនីតិជនមានអាយុចាប់ពី១៦(ដប់ប្រាំមួយ)ឆ្នាំដល់ ១៨(ដប់ប្រាំបី)ឆ្នាំ។

ចំពោះបទមជ្ឈិមចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ចំពោះអនីតិជនឡើយ។

**ខ. ការឃុំខ្លួនបណ្តោះអាសន្នលើនីតិជន**

ជាគោលការណ៍នីតិជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៦(ប្រាំមួយ)ខែបានទេ។ ប៉ុន្តែនូវពេលដែលផុតកំណត់ចិរវេលានេះចៅក្រមស៊ើបសួរអាចពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ៦(ប្រាំមួយ)ខែដោយមានដីកាសំអាងហេតុត្រឹមត្រូវនឹងច្បាស់លាស់ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានតែពីរដងគត់[៨១]។

[៨១] មាត្រា ២០៨នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ចំពោះនីតិជនដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤(បួន) ខែបានទេ។ ប៉ុន្តែនូវពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចធ្វើការពន្យារការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ២ (ពីរ)ខែដោយមានដីកាសំអាងហេតុត្រឹមត្រូវ[90]។

សូមបញ្ជាក់ថា ចំពោះបទមជ្ឈឹមចិរវេលានៃការឃុំព្រោះបណ្តោះអាសន្នមិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមាទោសដែលច្បាប់បានកំណត់ឡើយ។ ប្រសិនបើមានការចោទប្រកាន់ ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬក៏បទឧក្រិដ្ឋកម្មសង្គ្រាមការឃុំខ្លួនបណ្តោះអាសន្ន គឺមិនអាចលើសពី ១(មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែកាលណាបើផុតចិរវេលានេះចៅក្រមស៊ើបសួរ អាចនឹងពន្យារការឃុំខ្លួនបណ្តោះអាសន្ន ម្តងបាន ១(មួយ)ឆ្នាំដោយដីកាមានសំអាងហេតុត្រឹមត្រូវ នឹងច្បាស់លាស់ ចៅក្រមស៊ើបសួរអាចបង្គាប់អោយពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះបានតែពីរដងគត់[91]។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរគឺត្រូវអោយដំណឹងដល់ជនត្រូវចោទនិងទទួលនូវការកត់សំគាល់ពីជននេះ។ កាលណាជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញនូវមធ្យោបាយការពារខ្លួនអោយកូនក្តីខ្លួនស្របតាមនីតិវិធីច្បាប់ជាធរមាន។

#### ៤.៣.៥. ការសម្រេចមិនឃុំខ្លួន

កាលណាចៅក្រមស៊ើបសួរបានទទួលបាននូវពាក្យបណ្តឹងទៅតាមសេចក្តីទិន្នដ្ឋានរបស់ព្រះរាជអាជ្ញា ដែលមានខ្លឹមសារស្នើសុំអោយឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នតែចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមការស្នើសុំអោយឃុំខ្លួននោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ ដោយមិនចាំបាច់មានសំអាងហេតុទេ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្តឹងស្នើសុំករណីចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេព្រះរាជអាជ្ញាមានសិទ្ធិប្តឹងសុំទៅសភាស៊ើបសួរសាលាឧទ្ធរណ៍បាន។

#### ៤.៣.៦. ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ

ការដោះលែងជនត្រូវចោទអោយនូវក្រៅឃុំអាចធ្វើឡើងតាមរយៈ ការសម្រេចរបស់ចៅក្រមស៊ើបសួរតាមបណ្តឹងព្រះរាជអាជ្ញា បណ្តឹងជនត្រូវចោទ និងការត្រួតពិនិត្យតាមផ្លូវតុលាការ។

##### ៤.៣.៦.១. តាមរយៈការសម្រេចចៅក្រមស៊ើបសួរ

ក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថា ធាតុផ្សំបទល្មើសមិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់នោះទេ ចៅក្រមស៊ើបសួរអាចបង្គាប់អោយដោះលែងជនត្រូវចោទនោះអោយស្ថិតនូវក្រៅឃុំបាន

[90] មាត្រា ២០៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[91] មាត្រា ២១០នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

គ្រប់ពេល។ ប៉ុន្តែមុននឹងចេញដីកាដោះលែងជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវជូនពត៌មាននេះទៅព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសុំណុំរឿងទៅអោយព្រះរាជអាជ្ញាពិនិត្យដោយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយះពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយះពេល ៥(ប្រាំ)ថ្ងៃបន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ករណីបន្ទាន់ចៅក្រមស៊ើបសួរអាចបង្គាប់អោយដោះលែងជនត្រូវចោទភ្លាមដោយមិនរង់ចាំយោបល់ពីព្រះរាជអាជ្ញាតែត្រូវចង្អុលប្រាប់ពីមូលហេតុនៃការបន្ទាន់ក្នុងដីកាសម្រេចរបស់ខ្លួន។

**៤.៣.៦.២. តាមរយះពាក្យបណ្តឹងព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាអាចស្នើសុំអោយដោះលែងជនត្រូវចោទបានគ្រប់ពេលវេលាដូចជាចៅក្រមស៊ើបសួរដែរ។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចក្នុងរយះពេល ៥(ប្រាំ)ថ្ងៃ។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយះពេល ៥(ប្រាំ)ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរដែលអាចសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ ផ្ទុយទៅវិញ ករណីមិនព្រមដោះលែងត្រូវមានសំអាងហេតុដែលមានបង្ហាញនៅក្នុងដីកាសម្រេចនោះ។

**៤.៣.៦.៣. តាមរយះបណ្តឹងជនត្រូវចោទ**

ករណីដែលជនត្រូវចោទត្រូវបានឃុំខ្លួននោះ ខ្លួនមានសិទ្ធិដាក់ពាក្យស្នើសុំអោយដោះលែងនូវក្រៅឃុំបានគ្រប់ពេលវេលា។ កាលណាពាក្យបណ្តឹងត្រូវបានដាក់ទៅចៅក្រមស៊ើបសួរ ចៅក្រមរូបនេះត្រូវបញ្ជូនពាក្យនោះទៅព្រះរាជអាជ្ញាភ្លាម ដើម្បីសុំផ្តល់យោបល់និងបញ្ជូនសំណុំរឿងពិនិត្យ។ ក្រោយពីទទួលបាននូវពាក្យបណ្តឹងហើយព្រះរាជអាជ្ញានិងផ្តល់យោបល់ក្នុងរយះពេលខ្លីបំផុត ហើយចៅក្រមស៊ើបសួរអាចសម្រេចយ៉ាងយូរបំផុតរយះពេល ៥(ប្រាំ)ថ្ងៃបន្ទាប់ពីបានបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញា។ កាលណាជនត្រូវចោទត្រូវបានបដិសេធមិនអោយនូវក្រៅឃុំ ជនត្រូវចោទមានសិទ្ធិដាក់ពាក្យស្នើសុំនូវក្រៅឃុំសារជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរឬទៅសភាស៊ើបសួរនៅក្នុងរយះពេល ១(មួយ)ខែបន្ទាប់ពីមានសេចក្តីបដិសេធពាក្យស្នើសុំលើកមុន ករណីនេះចៅក្រមស៊ើបបសួរ និងសភាស៊ើបសួរត្រូវសម្រេចពាក្យសុំនេះ ក្នុងយះពេល ៥(ប្រាំ)ថ្ងៃក្រោយពីបានទទួលពាក្យស្នើសុំ។

**៤.៣.៦.៤. ការត្រួតពិនិត្យតាមផ្លូវតុលាការ**

កាលបើជនត្រូវចោទ ត្រូវបានចោទប្រកាន់ពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទនោះអោយស្ថិតនៅក្រោមការត្រួតពិនិត្យបានតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ការត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពបង្គាប់ជនត្រូវចោទនូវក្រៅឃុំអោយគោរពកាតព្វកិច្ចមួយឬច្រើន។ ចំពោះអនីតិជនដែលមានអាយុតិចជាង ១៤(ដប់បួន)ឆ្នាំមិនត្រូវបានដាក់អោយស្ថិតនូវក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការឡើយ។ កាលណាចៅក្រមស៊ើបសួរបានសម្រេចដោយត្រូវដាក់ជនត្រូវចោទអោយនៅក្រោមការត្រួត

ពិនិត្យតាមផ្លូវតុលាការនោះ ហើយការសម្រេចនេះអាចជាគំនិតផ្តួចផ្តើមរបស់ខ្លួនឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ ក្នុងករណីចៅក្រមស៊ើបសួរ ត្រូវមានបញ្ជាក់ពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។ ដីកាសម្រេចដាក់ជនត្រូវចោទអោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ គឺចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និងជនត្រូវចោទអោយបានដឹងនូវការសម្រេចនេះ។ ជាមួយគ្នានេះ ករណីចៅក្រមស៊ើបសួរទទួលពាក្យបណ្តឹងពីសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយសុំអោយដាក់ជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ប៉ុន្តែចៅក្រមស៊ើបសួរមិនព្រមតាមការសុំនោះចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ ហើយដីកាសម្រេចបដិសេធនេះត្រូវតែជូនដំណឹងជាបន្ទាន់ជូនដល់ព្រះរាជអាជ្ញា។ ផ្ទុយទៅវិញក្នុងករណីចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរដែលមានសិទ្ធិសម្រេចជំនួសចៅក្រមស៊ើបសួរបាន។

### ៤.៣.៧. មោឃៈភាពនៃការស៊ើបសួរ

ជាទូទៅគ្រប់ដែលពេលបំពេញកិច្ចរបស់ខ្លួន ចៅក្រមស៊ើបសួរត្រូវគោរពតាមវិធានទូទៅនៃនីតិវិធីស៊ើបសួរដែលជាបទបញ្ញតិដាច់ខាតត្រូវតែគោរពតាមកិច្ចទាំងនោះមានដូចជា ការបើកស៊ើបសួរសមត្ថកិច្ចដែនដីជំនួយរបស់ក្រឡាបញ្ជីជាដើម។ ប្រសិនបើពុំដូច្នោះនោះទេ និងត្រូវមោឃៈនីតិវិធីដែលត្រូវបានអនុវត្តហើយនោះ។ ក្នុងករណីខ្លះទៀតក៏អាចនាំអោយមោឃៈភាពដែរ កាលណាបំពានវិធានឬទម្រង់សំខាន់ណាមួយដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌធ្វើអោយប៉ះពាល់ប្រយោជន៍របស់ភាគី។ ចំពោះនីតិវិធីនៃការប្តឹងសុំមោឃៈភាពក្នុងករណីព្រះរាជអាជ្ញាយល់ឃើញថាលិខិតណាមួយធ្វើឡើងក្នុងនីតិវិធីមានមោឃៈភាពនោះ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំដោយមានសំអាងហេតុ រួចដាក់ទៅសភាស៊ើបសួរនិងជូនពត៌មាននេះដល់ចៅក្រមស៊ើបសួរ។ ក្នុងករណីដែរជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាលិខិតណាមួយដែលធ្វើឡើងក្នុងនីតិវិធីមានមោឃៈភាពនោះសាមីខ្លួនអាចធ្វើពាក្យសុំដោយមានសំអាងហេតុរួចដាក់ទៅសភាស៊ើបសួរព្រមទាំងជូនពត៌មាននេះដល់ចៅក្រមស៊ើបសួរអោយបានជ្រាប។ ជាមួយគ្នានេះចៅក្រមស៊ើបសួរយល់ឃើញថាលិខិតណាមួយនៃនីតិវិធីមានមោឃៈភាពនោះចៅក្រមស៊ើបសួររូបនេះ ប្តឹងទៅសភាស៊ើបសួរដោយមានដីកាសំអាងហេតុព្រមទាំងជូនពត៌មាននេះដល់ព្រះរាជអាជ្ញាជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី[៩២]។

[៩២] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក អៀង សំណាងឆ្នាំ២០១៩

# ជំពូកទី៣
# ការជំនុំជម្រះ

ការជំនុំជម្រះ គឺជាសវនការដែលសម្រេចសេចក្តីដោយចៅក្រមជំនុំជម្រះជាអ្នកដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះសម្រេចសេចក្តីលើសំណុំរឿងព្រហ្មទណ្ឌនេះ។ ប៉ុន្តែមុនការបើកសវនាការជំនុំជម្រះសម្រេចសេចក្តីគឺត្រូវឆ្លងកាត់នៅដំណាក់កាលជាច្រើនដូចជា ដំណាក់កាលនីតិវិធីមុនពេលជំនុំជម្រះ(មុនសវនាការ) ដំណាក់កាលនីតិវិធីជំនុំជម្រះ(សវនការ) និងដំណាក់កាលនីតិវិធីក្រោយពេលជំនុំជម្រះ(ក្រោយពេលសវនាការ)។

## ផ្នែកទី១៖ នីតិវិធីមុនពេលជំនុំជម្រះ( មុនសវនាការ )

មុនពេលធ្វើការជំនុំជម្រះសម្រេចសេចក្តី គឺចៅក្រមជំនុំជម្រះទទួលពាក្យបណ្តឹងដែលបញ្ជូនមកដោយចៅក្រមស៊ើបសួរនៃសាលាដំបូង ឬតំណាងអមអយ្យការសាលាដំបូងដើម្បីចាប់នីតិវិធីនៃការជំនុំជម្រះ។ នីតិវិធីលម្អិតនៃការទទួលបណ្តឹងមានខ្លឹមសារដូចខាងក្រោម៖

### ១.១. ការទទួលពាក្យបណ្តឹង

ក្នុងនីតិវិធីមុនពេលជំនុំជម្រះ គឺចៅក្រមជំនុំជម្រះបានទទួលពាក្យបណ្តឹងតាមរយៈចៅក្រមស៊ើបសួរដោយដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ និងតាមរយៈព្រះរាជអាជ្ញាដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា ឬមួយការធ្វើកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា។

#### ១.១.១. តាមរយៈដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូននូវដីកាដំណោះស្រាយជូនទៅតុលាការសាលាដំបូងអមអយ្យការ។ បន្ទាប់ពីចៅក្រមស៊ើបសួរធ្វើការបើកការស៊ើបអង្កេតនិងស៊ើបសួរត្រូវបានបិទបញ្ចប់ដោយចៅក្រមស៊ើបសួរ ហើយបានកំណត់ពីបទល្មើស អត្តសញ្ញាណជនជាប់ចោទ និងប្រមូលបានភស្តុតាងគ្រប់គ្រាន់ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការចាត់ការតាមនីតិវិធីបន្ត។ ការបញ្ជូនដីកាទៅរបស់ចៅក្រមស៊ើបសួរទៅជំនុំជម្រះនោះភ្ជាប់ជាមួយនូវឯកសារសំខាន់ៗមួយចំនួនដូចជា៖

- ពាក្យបណ្តឹង
- លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងអាណត្តិ
- ដីកាបញ្ជូនរឿងអោយស៊ើបសួរ
- ដីកាបញ្ជូនសំណុំរឿងអោយពិនិត្យ
- ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ
- ដីកាសន្និដ្ឋានស្ថាពរ
- ដីកាកោះហៅជនជាប់ចោទ

- លិខិតជូនដំណឹងដល់មេធាវីតំណាងដោយអាណត្តិ
- ដីកាបង្គាប់អោយចូលខ្លួន
- ដីកាបង្គាប់អោយនាំខ្លួន
- ដីកាបង្គាប់អោយឃុំខ្លួន
- កំណត់ហេតុសួរចម្លើយជនជាប់ចោទ
- កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី
- ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។

### ១.១.២. តាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា

ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា គឺជាដីកាដែលព្រះរាជអាជ្ញាចោទប្រកាន់បញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់ចំពោះបទល្មើសជាក់ស្តែងដែលទណ្ឌកម្មកំណត់ក្នុងច្បាប់មិនលើសពី ១(មួយ)ឆ្នាំ ឬមិនលើសពី ៥(ប្រាំ)ឆ្នាំ ហើយមានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាវិធីមួយដែលតុលាការទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាអាចយកមកអនុវត្តបានចំពោះបទមជ្ឈិមតូចតាច និងបទលហុហើយសំណុំរឿងវាមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបានទោះបីជាជនជាប់ចោទជានីតិជន ឬអនីតិជនក៏អាចអនុវត្តតាមនីតិវិធីមួយនេះបានផងដែរ។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានឯកសារភ្ជាប់ដូចជាៈ

- លេខសំណុំរឿង និងកាលបរិច្ឆេទ
- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- បទល្មើសដែលត្រូវបានចោទប្រកាន់
- អត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស
- តុលាការដែលមានសមត្ថកិច្ចជំនុំជម្រះ
- ហត្ថលេខារបស់ព្រះរាជអាជ្ញា
- ការបញ្ជាក់សិទ្ធិរបស់ជនជាប់ចោទអាចពឹងពាក់មេធាវីអោយអមខ្លួនបាន។

### ១.១.៣. តាមរយៈការកំណត់ហេតុចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា

កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា គឺព្រះរាជអាជ្ញាអាចបង្គាប់អោយជនជាប់ចោទចូលមកបង្ហាញខ្លួនភ្លាមនូវចំពោះមុខតុលាការសាលាដំបូងអមអយ្យការ។ ប្រសិនបើបទល្មើសជា

បទល្មើសដាក់ស្តែងដែលការផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១(មួយ)ឆ្នាំនិងយ៉ាងច្រើន ៥(ប្រាំ)ឆ្នាំដែលជនជាប់ចោទជានីតិជននិងរឿងក្តីមានលក្ខណះគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបាន។ ឯកសារនៃទម្រង់ការនេះ ត្រូវចុះកំណត់ហេតុបើពុំដូច្នោះទេ នីតិវិធីត្រូវចាត់ទុកថាជាមោឃៈ។ នីតិវិធីនេះត្រូវបានព្រះរាជអាជ្ញាជ្រើសរើសក្នុងគោលបំណងពន្លឿនដំណើរការរឿងក្តីអោយមានភាពឆាប់រហ័សនិងសម្រួលដល់ការកកស្ទះរឿងក្តី។ នីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះ ជនជាប់ចោទស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នដែលមានអមដោយកងកម្លាំងការពាររហូតដល់ជនជាប់ចោទចូលបង្ហាញខ្លួននៅចំពោះមុខតុលាការពេលបើកសវនាការនាថ្ងៃនោះតែម្តង។ ក្នុងកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមមានឯកសារដូចជាៈ

- លេខសំណុំរឿង និងកាលបរិច្ឆេទ
- អត្តសញ្ញាណនៃជនជាប់ចោទ
- កាលបរិច្ឆេទ និងទីកន្លែងកំណើតរបស់ជនជាប់ចោទ
- លំនៅឋានរបស់ជនជាប់ចោទ
- បទល្មើសដែលត្រូវបានចោទប្រកាន់
- កាលបរិច្ឆេទ ម៉ោងដែលត្រូវបង្ហាញខ្លួន
- ទីកន្លែងដែលត្រូវបានបង្ហាញខ្លួន
- ស្នាមមេដៃរបស់ជនជាប់ចោទ
- ហត្ថលេខារបស់ព្រះរាជអាជ្ញា

ក្នុងកំណត់ហេតុនេះមានបញ្ជាក់ថា ជនជាប់ចោទមានសិទ្ធិសុំពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ជនជាប់ចោទ ឬស្នើសុំអោយមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់។

## ផ្នែកទី២ៈ នីតិវិធីពេលជំនុំជម្រះ(សវនការ)

ពេលធ្វើនីតិវិធីជំនុំជម្រះឬសវនាការ គឺចៅក្រមត្រូវបានបែងចែកជាពីរចៅក្រមអាសន និងចៅក្រមឈរដែលត្រូវកំណត់ឡើងដោយប្រធានតុលាការលើកលែងតែនីតិវិធីចូលបង្ហាញខ្លួនភ្លាម។ ករណីដែលតុលាការបានទទួលពាក្យបណ្តឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវតែគិតគូរតាមរយៈពេលដែលត្រូវប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់អោយចូលបង្ហាញខ្លួន។

### ២.១. ដំណើរការពិភាក្សាដេញដោលក្នុងសវនាការជំនុំជម្រះ

ការពិភាក្សាដេញដោលត្រូវបានប្រព្រឹត្តទៅក្នុងសវនាការជាសាធារណៈនូវក្នុងការជំនុំជម្រះក្តី។ ករណីលើកលែងតែក្នុងកាលៈទេសៈពិសេស ការពិភាក្សាដេញដោលអាចត្រូវបានធ្វើឡើងទាំងស្រុង ឬមួយផ្នែកដោយ

សម្ងាត់។ ប្រសិនបើតុលាការយល់ឃើញថាសវនាការជាសាធារណៈអាចបង្កអោយមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈឬប៉ះពាល់ដល់ទំនៀមទម្លាប់ដល់សង្គម។ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតអោយមានការជំនុំជម្រះក្តីដោយកំបាំងមុខដែលមានន័យថាតុលាការនឹងបើកសវនាការ ទោះបីពុំមានវត្តមានជនជាប់ចោទក៏ដោយតុលាការត្រូវតែស្វែងរកអោយឃើញការពិតស្តាប់ចម្លើយភាគីដទៃទៀតសាក្សី និងពិនិត្យវត្ថុតាង[93]។ ចំពោះបទឧក្រិដ្ឋ នឹងបទលហុមានជាប់ទាក់ទងនឹងបទចោទពីបទឧក្រិដ្ឋ ក្រុមប្រឹក្សាជំនុំជម្រះត្រូវតែមានចៅក្រម ៣(បី)រូប។ ចំពោះបទមជ្ឈឹម នឹងបទលហុចៅក្រមតែម្នាក់ដឹកនាំសវនាការ។ ចៅក្រមជំនុំជម្រះមិនអាចជាចៅក្រមដែលបានបំពេញកិច្ចស៊ើបសួរនៅក្នុងករណីតែមួយនោះទេ។

## ២.២. សក្ខីកម្ម និងវត្ថុតាង

ក្រោយពីការប្រាប់អោយដឹងពីបទចោទប្រកាន់ទៅដល់ជនជាប់ចោទ ហើយប្រធានសវនាការអាចសួរសំណួរទៅជនជាប់ចោទដោយប្រធានសវនាការអាចសួរសំណួរទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ក្នុងការអោយឃើញការពិត(សំណួរទាំងនេះត្រូវបានសួរទាំងខាងផ្នែកដាក់បន្ទុក និងផ្នែកដោះបន្ទុក)។ ព្រះរាជអាជ្ញា មេធាវីនិងភាគីដទៃដូចជា ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចសួរជនជាប់ចោទបាន។ គ្រប់សំណួរទាំងអស់នេះត្រូវសួរដោយមានការអនុញ្ញាតពីប្រធានសវនាការ។ ប្រធានសវនាការស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សីនិងអ្នកជំនាញតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារយុត្តិធម៌ដែលបានចូលរួមក្នុងការស៊ើបអង្កេតក៏អាចត្រូវបានផ្តល់ចម្លើយក្នុងឋានៈជាសាក្សីបានដែរ ហើយព្រះរាជអាជ្ញា មេធាវីនិងភាគីអាចត្រូវបានអនុញ្ញាតអោយសួរសំណួរ។ ហើយតុលាការអាចកោះហៅសាក្សីត្រូវតែចូលមកបង្ហាញខ្លួននូវចំពោះមុខតុលាការ ប្រសិនបើកាលណាសាក្សីបដិសេធន៏មិនចូលខ្លួនតុលាការអាចប្រើកម្លាំងសាធារណៈដើម្បីបង្ខំសាក្សីអោយចូលខ្លួនបាន។ ហើយប្រធានតុលាការក៏អាចបង្គាប់ជនណាម្នាក់អោយបង្ហាញវត្ថុតាងបានដែរ។

## ២.៣. សេចក្តីសន្និដ្ឋានចុងក្រោយ

បន្ទាប់ពីកិច្ចពិភាក្សាដេញដោលភាគីទាំងអស់ បានផ្តល់ឱកាសក្នុងការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន។ ចំពោះសេចក្តីសន្និដ្ឋានចុងក្រោយទាំងនេះត្រូវធ្វើតាមលំដាប់លំដោយដូចតទៅ៖

- ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានការកត់សម្គាល់ខ្លីៗ

[93] មាត្រា ៣៣៣នៃក្រមព្រហ្មនីតិវិធីទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ
- ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ
- មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ
- មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ។

ខណៈពេលដែលដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញាអាចធ្វើការឆ្លើយតបទៅបាននោះ ជនជាប់ចោទ និងមេធាវីរបស់ខ្លួនត្រូវតែនិយាយក្រោយគេបង្អស់ជានិច្ច។

### ២.៤. ការពិភាក្សាសម្រេច និងសាលក្រម

ចៅក្រមជំនុំជម្រះត្រូវថយទៅលើការពិភាក្សាសម្រេច ហើយគ្មានទទ្បីករណ៍ណាមួយច្បាស់លាស់អាច និងត្រូវលើកយកមកសំអាងទៀតបានឡើយនូវពេលដែលចៅក្រមថយទៅពិភាក្សាសម្រេច។ សេចក្តីសម្រេច អាចនិងត្រូវប្រកាសនៅក្នុងថ្ងៃដដែលឬតុលាការអាចលើកទៅប្រកាសសេចក្តីសម្រេចរបស់ខ្លួននៅកាលបរិច្ឆេទ ក្រោយទៀតក៏បាន។ ក្នុងករណីណាក៏ដោយសេចក្តីសម្រេចប្រកាសត្រូវតែធ្វើការប្រកាសក្នុងសវនាការជាសាធារណៈ។ ចំពោះសាលក្រមវិញត្រូវមានពីរផ្នែកៈ

- ***ផ្នែកសម្អាងហេតុៈ*** ដែលជាផ្នែកតុលាការពិនិត្យមើលទទ្បីករណ៍នៃអង្គហេតុនីមួយៗ នឹងអង្គច្បាប់ដែលត្រូវបានលើកឡើងនៅក្នុងសវនាការ។
- ***ផ្នែកសេចក្តីសម្រេចៈ*** ដែលជាផ្នែកតុលាការចុះនិទ្ទេសអំពីបទល្មើសដែលជាប់ជនចោទបានប្រព្រឹត្ត អត្ថបទច្បាប់ដែលអនុវត្ត និងទោសដែលតុលាការបានសម្រេចហើយទោសនេះអាចមានទាំងទណ្ឌកម្មរដ្ឋប្បវេណីប្រសិនបើមាន។

ប្រសិនបើជនជាប់ចោទត្រូវបានលើកលែងការចោទប្រកាន់ និងពុំមានវិធានការណ៍ថែមទៀតទេ។ ហើយប្រសិនបើតុលាការរកឃើញវិញថា ជនជាប់ចោទមានពិរុទ្ធភាពហួសពីមតិសង្ស័យតុលាការអាចប្រកាសពីពិរុទ្ធភាពរបស់ជនជាប់ចោទ នឹងសម្រេចផ្តន្ទាទោសជនជាប់ចោទ។ ចំពោះករណីបើជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ សាលក្រមត្រូវបានគេហៅថា "សាលក្រមចំពោះមុខ" ប្រសិនបើជនជាប់ចោទអវត្តមានសាលក្រមនេះហៅថា "សាលក្រមកំបាំងមុខ"។

## ផ្នែកទី៣ៈ នីតិវិធីក្រោយពេលជំនុំជម្រះ(ក្រោយសវនាការ)

ក្រោយពីពេលដែលជំនុំជម្រះរួចហើយ ចៅក្រមជំនុំជម្រះបានប្រកាសសេចក្តីសម្រេចមួយដែលផ្តន្ទាទោសជនជាប់ចោទនោះដែលហៅថា "សាលក្រម" ឬ"សាលដីកា" ហើយការប្រកាសសាលក្រម ឬសាលដីកានេះទៀបសោតអាចត្រូវចៅក្រមប្រកាសថាជាប្រភេទសាលក្រមកំបាំងមុខជនជាប់ចោទ សាលក្រមចំពោះមុខជនជាប់ចោទ ឬសាលក្រមចាត់ទុកថាចំពោះមុខជនជាប់ចោទ។ ហើយជនចាប់ចោទក៏មានសិទ្ធិប្តឹងបើកផ្លូវតវ៉ា

ទៅតាមប្រភេទន័យសាលក្រម ឬសាលដីកានីមួយៗនោះផងដែរ។ កាលណាបើចៅក្រមប្រកាសប្រភេទសាលក្រមកំបាំងមុខជនជាប់ចោទមានសិទ្ធិបើកផ្លូវប្ដឹងតវ៉ាតាមរយះបណ្ដឹងទាស់ ហើយប្រសិនចៅក្រមប្រកាសនូវសាលក្រមចំពោះមុខជនចាប់ចោទ ឬសាលក្រមចាត់ទុកថាចំពោះមុខជនជាប់ចោទនោះ មានសិទ្ធិអាចធ្វើការប្ដឹងតវ៉ាបានតាមរយះបណ្ដឹងឧទ្ធរណ៍ រួចក៏បន្តធ្វើបណ្ដឹងសាទុក្ខបានផងដែរ។ ទោះបីជាអស់សិទ្ធិប្ដឹងតវ៉ាតាមរយះបណ្ដឹងទាស់ បណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសាទុក្ខក៏ពិតមែន ក៏ប៉ុន្តែនូវមានសិទ្ធិធ្វើការបើកផ្លូវតវ៉ាមួយទៀត គឺតាមរយះបណ្ដឹងសើរើ។ ដូច្នេះនិងការរៀបរាប់ប្រភេទបណ្ដឹងនីមួយៗអោយបានក្បោះក្បាយដូចខាងក្រោមៈ

### ៣.១. ការធ្វើបណ្ដឹងបើកផ្លូវតវ៉ា(បណ្ដឹងទាស់)

ក្រោយពីសាលក្រមត្រូវបានប្រកាសរួចហើយភាគីនៅក្នុងរឿងព្រហ្មទណ្ឌអាចប្ដឹងទាស់បាន នៅក្នុងករណីដែលសាលក្រមនោះត្រូវបានសម្រេចដោយកំបាំងមុខខ្លួន និងជនដែលមានសិទ្ធិអាចធ្វើបណ្ដឹងទាស់បាន គឺៈ

#### ៣.១.១. ពិរុទ្ធជន

ក្នុងករណីដែលសាលក្រមត្រូវបានប្រកាសកំបាំងមុខ ពិរុទ្ធជនអាចប្ដឹងទាស់នឹងសាលក្រមដែលប្រកាសដោយកំបាំងមុខខ្លួនបាន[94]។ សាលក្រមមួយ គឺជាសាលក្រមកំបាំងមុខក្នុងករណីដែលជនជាប់ចោទមិនចូលបង្ហាញខ្លួននៅក្នុងពេលសវនាការ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញអោយឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវបានប្រកាសកំបាំងមុខជនជាប់ចោទ[95]។ តាមអត្ថន័យនេះ ប្រសិនបើជនជាប់ចោទអវត្តមាននាពេលសវនាការដែលធ្វើការពិភាក្សាដេញដោល ហើយតុលាការពុំមានភស្តុតាងណាបញ្ជាក់ថា ជនជាប់ចោទបានទទួលដំណឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅទេ សាលក្រមដែលបានប្រកាសដោយតុលាការគឺជាសាលក្រមកំបាំងមុខ ទោះបីជានៅពេលសវនាការប្រកាសសាលក្រមជនជាប់ចោទមានវត្តមានក៏ដោយ។ ផ្ទុយទៅវិញប្រសិនបើជនជាប់ចោទមានវត្តមាននាពេលសវនាការដែលធ្វើការពិភាក្សាដេញដោល សាលក្រមគឺជាសាលក្រមចំពោះមុខ ទោះបីជានូវពេលប្រកាសសាលក្រមជនជាប់ចោទអវត្តមានក៏ដោយ។ ក្នុងករណីមួយវិញទៀត សាលក្រមត្រូវចាត់ទុកជាចំពោះមុខ ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះសាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមដែលចាត់ទុកថាចំពោះមុខនេះត្រូវអោយដំណឹងដល់ជនជាប់ចោទ។ សាលក្រមនេះអាចត្រូវប្ដឹងឧទ្ធរណ៍បាន ក្នុងករណីដែលជនជាប់ចោទអវត្តមានបានបង្ហាញមូលហេតុអំពីការអវត្តមានរបស់ខ្លួន

---

[94] មាត្រា ៣៦៥នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[95] មាត្រា ៣៦២នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ហើយតុលាការក៏បានទទួលថាត្រឹមត្រូវ នោះតុលាការអាចលើករឿងទៅជំនុំជម្រះនៅសវនាការមួយក្រោយទៀត[96]។ ដោយហេតុថាទោះបីជាសាលក្រមត្រូវបានប្រកាសដោយកំបាំងមុខជនជាប់ចោទក៏ដោយតែជនជាប់ចោទប្រាកដជាបានដឹងពីថ្ងៃដែលត្រូវបានប្រកាសសាលក្រម ព្រោះថានៅពេលសវនាការដែលធ្វើការពិភាក្សាដេញដោល ប្រធានសវនាការបានជូនដំណឹងទៅដល់ភាគីដែលមានវត្តមានពីថ្ងៃដែលត្រូវប្រកាសសាលក្រមរួចហើយ។ កាលណាបណ្ដឹងទាស់ធ្វើប្រឆាំងសាលក្រមទាំងមូលសាលក្រមនេះត្រូវទុកជាអាសារបង់ ហើយការអនុវត្តសាលក្រមត្រូវព្យួរ ប៉ុន្តែដីកាបង្គាប់អោយចាប់ខ្លួននូវតែមានអានុភាព។

### ៣.១.២. ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណី នឹងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចធ្វើបណ្ដឹងទាស់នឹងសាលក្រមដែលសម្រេចកំបាំងមុខខ្លួនបាន។ ចំពោះបណ្ដឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ។ បណ្ដឹងទាស់ត្រូវធ្វើក្នុងរយះពេល ១៥(ដប់ប្រាំ)ថ្ងៃគិតពី

- ថ្ងៃអោយដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់អោយដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្ដឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់អោយដល់ដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។

បណ្ដឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិអោយប្ដឹងទាស់[97]។ ប៉ុន្តែពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុកម្ដាយ ឬអ្នកអាណាព្យាបាលដោយពុំចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។ ពិរុទ្ធជនត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការអោយដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។ ការអោយដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការត្រូវអនុលោមក្រមនីតិវិធីព្រហ្មទណ្ឌ ដោយដីកាជូនដំណឹង គឺជាលិខិតដែលអោយដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការដែលបញ្ញត្តិច្បាប់តម្រូវអោយជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដើម្បីអោយភាគីពាក់ព័ន្ធទទួលបានដំណឹងអំពីសេចក្ដីសម្រេចនោះ។ ដីកាអោយដំណឹងត្រូវធ្វើតាមគំនិតផ្ដើមរបស់ព្រះរាជអាជ្ញា របស់អគ្គព្រះរាជអាជ្ញា របស់ភាគី[98]។ ដីកាអោយដំណឹងត្រូវចុះនិទ្ទេសដូចតទៅះ

---

[96] មាត្រា ៣៦១នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[97] មាត្រា ៣៧២នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[98] មាត្រា ៤៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

- ប្រភេទ នឹងការយោងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹង
- អត្តសញ្ញាណ នឹងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច
- កាលបរិច្ឆេទ នឹងហត្ថលេខារបស់អ្នកដែលធ្វើការជូនដំណឹង។
- ដីកាអោយដំណឹងបញ្ជាក់ប្រាប់អំពីផ្លូវតវ៉ាដែលអាចធ្វើបាន ប្រឆាំងទៅនឹងសេចក្តីសម្រេចលិខិតចម្លងនៃសេចក្តីសម្រេចដែលត្រូវភ្ជាប់ទៅនឹងដីកាអោយដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ[99]។

ចំពោះការជូនដំណឹងអាចធ្វើបានដូចជា៖ ព្រះរាជអាជ្ញា អាជ្ញាសាលា ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬអាវុធហត្ថ។ ការប្រគល់ការជូនដំណឹងធ្វើតាមមធ្យោបាយដូចតទៅ៖

- ប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចអោយដល់ភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ។ អ្នកប្រគល់និទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង។ ភាគីពាក់ព័ន្ធត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចដើម។ ក្នុងករណីដែលអ្នកប្រគល់ការជូនដំណឹងមិនមែនជាព្រះរាជអាជ្ញា សេចក្តីសម្រេចដើមនេះត្រូវបង្វិលទៅ ព្រះរាជអាជ្ញាវិញជាបន្ទាន់។
- ប្រសិនបើភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន និងចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះកាលបរិច្ឆេទនៃការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច។ បុគ្គលដែលទទួលលិខិតត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមដែលត្រូវបង្វិលទៅព្រះរាជអាជ្ញាភ្លាម។ បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថា នឹងប្រគល់អោយភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុត។

ក្នុងករណីនេះ លិខិតចម្លងនៃសេចក្តីសម្រេចត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយមានចុះនិទ្ទេសដូចជា ឈ្មោះ និងអាសយដ្ឋានរបស់សាមីខ្លួនដែលត្រូវទទួលដីកានៅក្នុងផ្នែកខាងមុខស្រោមសំបុត្រត្រាប្រគល់ដីកានៅផ្នែកខាងក្រោយស្រោមសំបុត្រ។ ចំពោះក្នុងករណីដែលភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្តីសម្រេច ឬគ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ ឬគ្មានបុគ្គលណាម្នាក់ដែលមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធយល់ព្រមទទួលសេចក្តីសម្រេចនោះទេ អ្នកប្រគល់ការអោយដំណឹងត្រូវប្រគល់លិខិតនៃសេចក្តីសម្រេចទៅមេឃុំឬចៅសង្កាត់ ឬចៅសង្កាត់រងណាមួយ។ អ្នកប្រគល់ការអោយដំណឹងត្រូវ ចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើមអំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលលិខិតចម្លងនៃសេចក្តីសម្រេចព្រមទាំងកាលបរិច្ឆេទនៃការប្រគល់។ បុគ្គលដែលទទួលលិខិតចម្លង ត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចដើម ដែលត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតសន្យាថានឹងប្រគល់អោយភាគីពាក់ព័ន្ធក្នុងរយៈពេលខ្លីបំផុត។ ប្រសិនបើភាគីពាក់ព័ន្ធគ្មានលំនៅឋាន ឬទីសំណាក់ទេ ឬប្រសិនបើភាគីពាក់

[99] មាត្រា ៤៨៣នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ព័ន្ធនេះរស់នៅក្រៅដែនដីជាតិ សេចក្ដីសម្រេចរបស់តុលាការក៏អាចជូនដំណឹងដល់សាមីខ្លួនបានដែរ។ ក្នុងករណីនេះ កាលបរិច្ឆេទនៃសេចក្ដីសម្រេចតុលាការត្រូវចាត់ទុកថាកាលបរិច្ឆេទនៃការជូនដំណឹង។ ចំពោះក្នុងករណីដែលការប្រគល់ការជូនដំណឹងត្រូវបានធ្វើតាមវិធីដូចដែលរៀបរាប់ខាងលើ គឺមានន័យថាការជូនដំណឹងត្រូវបានធ្វើត្រឹមត្រូវតាមនីតិវិធីរួចហើយ។ នៅពេលដែលមានពាក្យបណ្ដឹងទាស់ត្រឹមត្រូវ សំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះដោយតុលាការដដែលដោយភាគីទាំងអស់នឹងត្រូវបានកោះហៅ។ ចំពោះសេចក្ដីសម្រេចរបស់តុលាការអាចជា ៖

- ✓ សាលក្រមលើកចោលបណ្ដឹងទាស់ ដោយសារតែបណ្ដឹងទាស់មិនអាចទទួលបាន។ បណ្ដឹងទាស់មិនអាចទទួលបាន ដោយសារតែអ្នកដាក់ពាក្យបណ្ដឹងទាស់ជាជនដែលពុំមានសិទ្ធិប្ដឹងទាស់ ឬដោយសារតែការដាក់ពាក្យបណ្ដឹងទាស់ធ្វើឡើងផុតរយៈពេលដែលច្បាប់កំណត់ដូចជា សហព័ទ្ធរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ពាក្យបណ្ដឹងទាស់ជំនួសអោយសហព័ទ្ធរបស់ខ្លួនដោយពុំមានលិខិតប្រគល់សិទ្ធិ។
- ✓ សាលក្រមប្រកាសថាបណ្ដឹងទាស់ទុកជាឥតបានការ ហើយតម្កល់សាលក្រមដែលគេប្ដឹងទាស់ទុកជាបានការដដែល ដោយមូលហេតុថាអ្នកប្ដឹងទាស់មិនចូលបង្ហាញខ្លួននៅពេលសវនាការ ក្រោយពីបានទទួលការកោះហៅដោយត្រឹមត្រូវ។
- ✓ សាលក្រមលើអង្គសេចក្ដី ក្នុងករណីដែលអ្នកប្ដឹងទាស់បង្ហាញខ្លួននៅពេលសវនាការ។ ក្នុងករណីនេះតុលាការអាចសម្រេចតម្កល់សេចក្ដីសម្រេចមុន ឬកែប្រែ ឬបដិសេធសេចក្ដីសម្រេច ហើយសម្រេចសេចក្ដីសាជាថ្មីម្ដងទៀតបាន ទៅតាមស្ថានភាពនៃរឿងនីមួយៗ។

សាលក្រមដែលសម្រេចលើបណ្ដឹងទាស់អាចប្ដឹងឧទ្ធរណ៍បាន ដែលរយៈពេលប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជនដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល ១(មួយ)ខែ។ កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលប្រកាសសាលក្រម។ កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលទទួលដំណឹងនេះធ្វើតាមវិធីណាក៏ដោយ[100]។

## ៣.២. ការធ្វើបណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ គឺជាបណ្ដឹងមួយប្រភេទដែលនាំអោយសំណុំរឿងនោះត្រូវផ្ទេរទៅសាលាឧទ្ធរណ៍ នៅក្នុងព្រំដែនដែលកំណត់ដោយលិខិតបណ្ដឹងឧទ្ធរណ៍ នឹងតាមឋានៈរបស់អ្នកប្ដឹងឧទ្ធរណ៍។ សាលាឧទ្ធរណ៍សម្រេចសេចក្ដីដោយត្រួតពិនិត្យទៅលើអង្គហេតុ នឹងអង្គច្បាប់ដែលសាលាជម្រះក្ដីថ្នាក់ក្រោមបានស្រាវជ្រាវរកឃើញនឹងបានអនុវត្ត។

[100] មាត្រា ៤៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

### ៣.២.១. លក្ខខណ្ឌទម្រង់នៃការធ្វើបណ្តឹងឧទ្ធរណ៍

ក្រមនីតិវិធីព្រហ្មទណ្ឌ បានបង្ហាញបុគ្គលដែលអាចការប្តឹងឧទ្ធរណ៍បានមាន៖

- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ពិរុទ្ធជន
- ដើមបណ្តឹងរដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី[101]។

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី នឹងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវីតែត្រូវមានលិខិតប្រគល់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍។ ប៉ុន្តែក្នុងករណីដែលពិរុទ្ធជនជាអនីតិជន ឪពុកម្តាយ ឬអ្នកអាណាព្យាបាល អាចតំណាងក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍បាន ដោយពុំចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។ ប្រសិនបើពិរុទ្ធជនជាប់ឃុំ មានបំណងប្តឹងឧទ្ធរណ៍ហើយការប្តឹងឧទ្ធរណ៍អាចធ្វើបាននៅមុខប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏អាចត្រូវបានតំណាងដោយមេធាវីសហព័ទ្ធ ឬញាតិលោហិតផ្ទាល់បានដែរ ប៉ុន្តែត្រូវមានលិខិតប្រគល់សិទ្ធិផងទើបបាន។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍នឹងសាលក្រមរបស់តុលាការជាន់ដំបូងនូវការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។ ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១(មួយ)ខែគិតពីពេលប្រកាសសាលក្រម។ ពិរុទ្ធជនដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១(មួយ)ខែគិតពីពេលប្រកាសសាលក្រម កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ ឬគិតពីពេលទទួលដំណឹងសាលក្រមទោះបីជាការអោយដំណឹងនេះធ្វើតាមវិធីណាក៏ដោយ កាលបើសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ។

**កំណត់សម្គាល់**៖ ប្រសិនបើជាករណីនៃសាលក្រមកំបាំងមុខ រយះពេលប្តឹងឧទ្ធរណ៍ត្រូវផ្តើមគិតពីពេលផុតកំណត់ប្តឹងទាស់។

### ៣.២.២. នីតិវិធីចំពោះមុខសាលាឧទ្ធរណ៍

ដោយហេតុថាបណ្តឹងឧទ្ធរណ៍ត្រូវដាក់នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រមហេតុនេះ ក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រមមានភារៈកិច្ចត្រូវបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍។ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានកំណត់អំពីរយៈពេលនៃការបញ្ជូនសំណុំរឿងពីសាលាជម្រះក្តីជាន់

[101] មាត្រា ៣៧៥នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ទាបទៅសាលាឧទ្ធរណ៍ទេ ប៉ុន្តែតម្រូវអោយមានការបញ្ជូននេះត្រូវធ្វើក្នុងរយៈពេលដ៏ខ្លីបំផុតទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។ ប៉ុន្តែក្នុងករណីជាបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការអំពីការឃុំខ្លួនជនជាប់ចោទ តាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់រយៈពេលត្រឹមតែ ១០(ដប់)ថ្ងៃយ៉ាងយូរសម្រាប់ការបញ្ជូនសំណុំរឿងទៅអោយសាលាឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជំនះបានដែលត្រូវតែបញ្ជាក់នៅក្នុងលិខិតបញ្ជូន[102]។ ក្រោយពីបានទទួលសំណុំរឿងរួចហើយ នីតិវិធីនៅចំពោះមុខសាលាឧទ្ធរណ៍ត្រូវចាប់ផ្តើមពីការកំណត់កាលបរិច្ឆេទសវនាការរហូតដល់ការប្រកាសសាលដីកា។ គួរបញ្ជាក់ផងដែរថាការសម្រេចសេចក្តីអំពីបណ្តឹងឧទ្ធរណ៍ទៅ និងសាលក្រមដែលជាសមត្ថកិច្ចរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍មិនមែនជាសមត្ថកិច្ចរបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ទេ។

#### ៣.២.២.១. ការកំណត់កាលបរិច្ឆេទសវនាការ

ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់រយៈពេលជាក់លាក់ណាមួយ ដែលតម្រូវអោយសភាព្រហ្មទណ្ឌត្រូវបើកសវនាការសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍។ ក្រមនីតិវិធីព្រហ្មទណ្ឌ គ្រាន់តែតម្រូវអោយសភាព្រហ្មទណ្ឌសម្រេចនៅក្នុងរយៈពេលសមស្របតែប៉ុណ្ណោះ លើកលែងតែករណីបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងស្តីពីការឃុំខ្លួនជនជាប់ចោទ ដែលសាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃគិតពីថ្ងៃទទួលសំណុំរឿង[103]។ ក្រោយពីបានកំណត់កាលបរិច្ឆេទនៃសវនាការរួចហើយ ប្រធានសភាព្រហ្មទណ្ឌជូនដំណឹងអំពីកាលបរិច្ឆេទនេះ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នកមានសមត្ថកិច្ចក្នុងការកោះហៅជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី នឹងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

#### ៣.២.២.២. ការធ្វើរបាយការណ៍

ការធ្វើរបាយការណ៍ខុសប្លែកពីនីតិវិធីនៅតុលាការជាន់ខ្ពស់ នីតិវិធីនៅសាលាឧទ្ធរណ៍ត្រូវឆ្លងកាត់ធ្វើរបាយការណ៍មួយ។ ប្រធានសភាព្រហ្មទណ្ឌចាត់តាំងចៅក្រមធ្វើរបាយការណ៍ម្នាក់ដែលអាចជាប្រធានសភាព្រហ្មទណ្ឌខ្លួនឯងឬចៅក្រមអមរបាយការណ៍នេះរៀបរាប់អំពីដំណើររឿង និងធ្វើអោយដឹងអំពីសាលក្រមដែលជូនមកសាលាឧទ្ធរណ៍។

#### ៣.២.២.៣. ដំណាក់កាលសវនាការ

ពេលសវនាការ ការពិភាក្សាដេញដោលត្រូវប្រព្រឹត្តទៅជាសាធារណៈលើកលែងតែករណីដែលសភាព្រហ្មទណ្ឌយល់ឃើញថា ភាពជាសាធារណៈនាំអោយមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈសង្គមឬដល់

[102] មាត្រា ៣៨៦នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[103] មាត្រា ៣៨៧កថាខណ្ឌទី ២នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ប្រពៃណីទំនៀមទម្លាប់។ ក្នុងករណីនេះ សភាព្រហ្មទណ្ឌបង្គាប់អោយធ្វើការពិភាក្សាដេញដោលជាសម្ងាត់ទាំងស្រុង ឬមួយផ្នែកតាមសាលដីកាដោយមានសំអាងហេតុដែលអាចជាសាលដីកាដាច់ដោយឡែកពីសាលដីកាលើអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលដីកាលើអង្គសេចក្តីក៏បាន។ បើយោងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ សភានីមួយៗនៃសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយមានចៅក្រម ៣(បី)រូបដែល ១(មួយ)រូបជាប្រធាន។ រឿងក្តីណាមួយដែលតុលាការកំពូលបានបង្វិលវិញ នោះសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយដែលមានចៅក្រម ៥(ប្រាំ)រូបហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមក្នុងការជំនុំជម្រះលើកមុន[104]។ សមាសភាពនេះត្រូវបំពេញដោយអគ្គព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាម្នាក់នៃមហាអយ្យការអមសាលាឧទ្ធរណ៍ និងក្រឡាបញ្ជីម្នាក់។ ជាដំបូងចៅក្រមរបាយការណ៍ត្រូវអានរបាយការណ៍ហើយបន្ទាប់មកប្រធានក្រុមប្រឹក្សាជំនុំជម្រះចាប់ផ្តើមសួរចម្លើយជនជាប់ចោទ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី អ្នកជំនាញ តាមលំដាប់លំដោយក៏ដូចជានៅសាលជម្រះក្តីជាន់ទាបដែរ អគ្គព្រះរាជអាជ្ញា មេធាវី ភាគីទាំងឡាយអាចអនុញ្ញាតអោយលើកជាសំណួរចោទសួរបាន។ ក្រោយពីការដេញដោលបានចប់សព្វគ្រប់អគ្គព្រះរាជអាជ្ញា និងមេធាវីឡើងនិយាយតាមលំដាប់លំដោយនៃការហៅឈ្មោះ។ នៅគ្រប់ករណីទាំងអស់ជនជាប់ចោទនិយាយក្រោយបំផុត។ មេធាវីរបស់ជនជាប់ចោទត្រូវបានអនុញ្ញាតអោយធ្វើការកត់សម្គាល់ជាបន្ថែមដោយសង្ខេប។

### ៣.២.២.៤. ការប្រកាសសាលដីកា

សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ប្រកាសសាលដីកា។ សាលដីកានេះអាចជាសាលដីកាចំពោះមុខសាលដីកាដែលចាត់ទុកថាចំពោះមុខ ឬជាសាលដីកាកំបាំងមុខ។ ការកំណត់អំពីប្រភេទនៃសាលដីកាខាងលើនេះត្រូវអនុលោមទៅតាមវិធានដែលអនុវត្តចំពោះសាលក្រមនៃសាលាជម្រះក្តីជាន់ទាបដែរ។ ចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍អាចជា៖

- សាលដីកាចាត់របៀប(បង្គាប់អោយស៊ើបសួរបន្ថែមទៀត)។
- សាលដីកាដែលប្រកាសថាបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន កាលបើពិនិត្យទៅឃើញថាមានបណ្តឹងឧទ្ធរណ៍ហួសពេលកំណត់ការធ្វើក្នុងលក្ខខណ្ឌមិនត្រឹមត្រូវ។
- សាលដីកាប្រកាស បដិសេធន៍សាលក្រមហើយអោយជនជាប់ចោទរួចខ្លួន កាលបើសាលាឧទ្ធរណ៍យល់ឃើញថា គ្មានពិរុទ្ធភាពលើជនជាប់ចោទ ឬក៏អំពើនោះមិនមែនជាបទល្មើសទេ។

[104] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤

- សាលដីកាដែលប្រកាសដាក់ទម្ងន់ទោសឬបន្ថយកម្រិតទោស ដែលប្រកាសដោយសាលក្រមនៃតុលាការជាន់ដំបូង ឬក៏ប្រកាសផ្តន្ទាទោសជនជាប់ចោទដែលតុលាការជាន់ដំបូងសម្រេចអោយរួចខ្លួនពីបទចោទ
- សាលដីកាដែលសម្រេចលើអង្គសេចក្តីឡើងវិញ (ដូចជាករណីនៃការសម្រេចសេចក្តីរបស់តុលាការជាន់ដំបូងអោយរួចខ្លួនពីការចោទប្រកាន់ ឬផ្តន្ទាទោសជាដើម) កាលណាសាលាឧទ្ធរណ៍ពិនិត្យឃើញថាសាលក្រមរបស់តុលាការជាន់ដំបូងមានមោឃៈភាព។
- សាលដីកាដែលសម្រេចបន្ថែមនូវចំនួនទឹកប្រាក់សម្រាប់ជួសជុលការខូចខាតអោយទៅដើមបណ្តឹងរដ្ឋប្បវេណី ឬបន្ថយចំនួនទឹកប្រាក់នេះ។ បន្ថែមពីលើសាលដីកាសម្រេចផ្តន្ទាទោស សាលាឧទ្ធរណ៍ក៏អាចចេញដីកាបង្គាប់អោយចាប់ខ្លួនជនជាប់ចោទដែលអវត្តមាន កាលបើសាលាឧទ្ធរណ៍សម្រេចទោសដាក់ពន្ធនាគារតិចជាង ១(មួយ)ឆ្នាំដោយគ្មានការព្យួរទេ ហើយប្រសិនបើវិធានការសន្តិសុខតម្រូវនោះ។ ក្នុងការប្រកាសអំពីសេចក្តីសម្រេចខាងលើនេះ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់នូវគោលការណ៍មួយចំនួនសម្រាប់សាលាឧទ្ធរណ៍ដូចជា៖
- សាលាឧទ្ធរណ៍មិនអាចបន្ថែមធាតុថ្មីណាមួយដែលមិនបានដាក់ជូនតុលាការជាន់ដំបូងសម្រេចនោះទេ មានន័យថា សាលាឧទ្ធរណ៍សម្រេចសេចក្តីតែនៅលើអង្គហេតុដែលបានដាក់ជូនតុលាការជាន់ដំបូងសម្រេចហើយដែលត្រូវបានប្តឹងឧទ្ធរណ៍ប៉ុណ្ណោះ ចំពោះការឡើងអំពីអង្គហេតុថ្មីមិនអាចធ្វើបានឡើយ។ ទោះបីជាយ៉ាងនេះក្តី សាលាឧទ្ធរណ៍អាចកែប្រែប្រភេទគតិយុត្តិនៃអង្គហេតុដែលសាលាដំបូងបានកំណត់ដូចជា ការកែប្រែពីបទរំលោភលើទំនុកចិត្តទៅជាបទឆបោកជាដើម ដោយសារតែការវាយតម្លៃកំណត់បទល្មើសដោយតុលាការជាន់ដំបូងមិនត្រឹមត្រូវតាមអំពើដែលចោទប្រកាន់។
- ប្រសិនបើសាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ សាលាឧទ្ធរណ៍មិនអាចដាក់ទម្ងន់ទោសលើជនជាប់ចោទ ឬបន្ថែមចំនួនទឹកប្រាក់សំណងអោយដើមបណ្តឹងទេ ទោះបីជាការសម្រេចសេចក្តីតុលាការជាន់ដំបូងមានការខុសឆ្គងយ៉ាងណាក៏ដោយ។ ប៉ុន្តែប្រសិនបើតុលាការជាន់ដំបូងភ្លេចប្រកាសទោសបន្ថែមណាមួយដែលដាច់ខាតត្រូវតែប្រកាសនោះដូចជា ក្នុងករណីការប្រកាសអំពីការរឹបអូសគ្រឿងញៀនដើម្បីបំផ្លាញចោលជាដើម សាលាឧទ្ធរណ៍អាចបដិសេធសាលក្រមហើយសម្រេចអំពីទោសជាថ្មីម្តងទៀត។
- ប្រសិនបើសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ សាលាឧទ្ធរណ៍ត្រូវសម្រេចឡើងវិញនូវសេចក្តីសម្រេចខាងព្រហ្មទណ្ឌនៃតុលាការ

ជាន់ដំបូងពោល គឺសាលាឧទ្ធរណ៍អាចសម្រេចអោយជនជាប់ចោទរួចខ្លួនឬផ្តន្ទាទោសឬបន្ថែមទម្ងន់ទោសជាដើម។

- ប្រសិនបើសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយមានបណ្តឹងឧទ្ធរណ៍តែពីដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាលាឧទ្ធរណ៍សម្រេចសេចក្តីតែអំពីផលប្រយោជន៍រដ្ឋប្បវេណីប៉ុណ្ណោះ។ នៅមុខសាលាឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើពាក្យប្តឹងសុំថ្មីដែលមិនបានដាក់ជូនតុលាការពិនិត្យនោះទេ។

សាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍អាចត្រូវប្តឹងទាស់បាន ដោយត្រូវគោរពតាមលក្ខខណ្ឌដែលបានចែងក្រមនីតិវិធីព្រហ្មទណ្ឌ[105]។ ការប្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃដោយគិតពីៈ

- ថ្ងៃអោយដំណឹងអំពីសាលដីកាកំបាំងមុខ កាលណាសាលដីកានេះត្រូវបានប្រគល់អោយដល់ពិរុទ្ធជនដោយផ្ទាល់ដៃ។
- ថ្ងៃដែលពិរុទ្ធជនបានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា កាលណាសាលដីកានេះមិនបានប្រគល់ទៅអោយពិរុទ្ធជនដោយផ្ទាល់ដៃទេ[106]។

ក្រៅពីការប្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏អាចប្តឹងទាស់នឹងសាលដីកាកំបាំងមុខខ្លួនបានផងដែរ។ បណ្តឹងទាស់នេះ កំណត់ទៅលើតែសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលដីកាប៉ុណ្ណោះ។ ការប្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃដោយគិតពីៈ

- ថ្ងៃអោយដំណឹងអំពីសាលដីកាកំបាំងមុខ កាលណាសាលដីកានេះត្រូវបានប្រគល់អោយទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ។
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា កាលណាសាលដីកានេះមិនបានប្រគល់អោយដើមបណ្តឹងដោយផ្ទាល់ដៃទេ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធឬដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរដែលអនុញ្ញាតិអោយប្តឹងទាស់[107]។

[105] មាត្រា ៤០៩នៃនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[106] មាត្រា ៤១២នៃនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[107] មាត្រា ៤១៦នៃនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

### ៣.៣. ការធ្វើបណ្តឹងសាទុក្ខ

ជាគោលការណ៏តុលាការកំពូលសម្រេចសេចក្តីតែលើអង្គច្បាប់ប៉ុណ្ណោះ មិនសម្រេចសេចក្តីលើអង្គហេតុទេ ត្រង់ចំណុចនេះមានន័យថាតុលាការកំពូលមិនពិនិត្យ ឬស៊ើរើអង្គហេតុដែលកំណត់ដោយសាលាឧទ្ធរណ៏រួចហើយនោះទេ ប៉ុន្តែតុលាការពិនិត្យមើលថាសាលាឧទ្ធរណ៏បានអនុវត្តច្បាប់ត្រឹមត្រូវដែរឬទេ ទៅតាមអង្គហេតុដែលបានរកឃើញនោះ។

#### ៣.៣.១. ទម្រង់នៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខត្រូវធ្វើតាមពាក្យបណ្តឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៏ដែលបានចេញសាលដីកា។ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៏រៀបចំសំណុំរឿងនេះទៅក្រឡាបញ្ជីតុលាការកំពូលក្នុងរយះពេលដ៏ខ្លីបំផុត។ តាមក្រមនីតិវិធីព្រហ្មទណ្ឌបុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខបានមានដូចជា៖

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៏
- ជនជាប់ចោទ ឬពិរុទ្ធជន
- បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិវិធីបត្យាប័ន
- ដើមបណ្តឹងរដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

បណ្តឹងសាទុក្ខ ត្រូវពិនិត្យដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល[108]។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌក្នុងការធ្វើបណ្តឹងសាទុក្ខត្រូវធ្វើក្នុងរយះពេលដូចតទៅ៖

- ១(មួយ)ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៏
- ១៥(ដប់ប្រាំ)ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៏
- ៥(ប្រាំ)ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន។

កាលណាសាលដីកាបណ្តឹងសាទុក្ខនេះ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខរយះពេលត្រូវផ្តើមគិតពីការអោយដំណឹង។

កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយះពេលត្រូវផ្តើមគិតពីការផុតរយះពេលប្តឹងទាស់ កាលបើជាសាលដីកាកំបាំងមុខ។

[108] មាត្រា ៤១៨នៃក្រមនីតិវីធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

### ៣.៣.២. មូលហេតុនៃបណ្តឹងសាទុក្ខ

ខុសប្លែកពីការប្តឹងទាស់ នឹងការប្តឹងឧទ្ធរណ៍ដែលបានរៀបរាប់ខាងលើនេះ ការធ្វើបណ្តឹងសាទុក្ខត្រូវមានមូលហេតុដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ និយាយម្យ៉ាងវិញទៀតថា តុលាការកំពូលអាចបដិសេធសេចក្តីសម្រេចដែលត្រូវគេប្តឹងសាទុក្ខដោយមូលហេតុដូចខាងក្រោមតែប៉ុណ្ណោះ៖

- សមាសភាពមិនស្របច្បាប់នៃតុលាការ
- អសមត្ថភាពនៃតុលាការ
- ការរំលោភអំណាច
- ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់
- ការបំពាន ឬភ្លេចទម្រង់ការដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ
- ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការឬភាគី កាលណាពាក្យប្តឹងសុំនោះត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ នឹងមានន័យយ៉ាងច្បាស់លាស់
- ការបំភ្លៃអង្គហេតុ
- គ្មានសំអាងហេតុ
- ការផ្ទុយគ្នារវាងសំអាងហេតុ នឹងសេចក្តីសម្រេច[109]។

ការកំណត់អំពីមូលហេតុជាក់លាក់នៃបណ្តឹងសាទុក្ខ គឺដោយសារតែតុលាការកំពូលជាចៅក្រមអង្គច្បាប់ មិនមែនជាចៅក្រមអង្គហេតុឡើយ។ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងជាក់ច្បាស់ថាតុលាការកំពូលត្រូវសម្រេចលើបញ្ហាច្បាប់ដែលលើកឡើងដោយអ្នកប្តឹងសាទុក្ខ នឹងដែលមានរៀបរាប់នៅក្នុងសារណា[110]។

### ៣.៣.៣. នីតិវិធីនៅចំពោះមុខតុលាការកំពូល

#### ៣.៣.៣.១. នីតិវិធីមុនពេលសវនាការ

នៅពេលដែលសំណុំរឿងបានទៅដល់តុលាការកំពូល ក្រឡាបញ្ជីតុលាការកំពូលត្រូវចុះបញ្ជី។ ហើយក្រឡាបញ្ជីតុលាការកំពូលអោយដំណឹងដល់គូភាគីអំពីការចុះបញ្ជីនៃសំណុំរឿង។ ក្នុងរយៈពេល ១០(ដប់)ថ្ងៃក្រោយការអោយដំណឹងនេះ ក្រឡាបញ្ជីអោយដំណឹងដល់អ្នកប្តឹងសាទុក្ខថាខ្លួនមានថេរវេលា ២០(ម្ភៃ)ថ្ងៃដើម្បីផ្ញើរជូនសភាព្រហ្មទណ្ឌ(សភានៃតុលាការកំពូល)នូវសារណាមួយ។ អ្នកប្តឹងសាទុក្ខបានជូនសារណានោះមកតុលាការកំពូល។ ក្រឡាបញ្ជីអោយដំណឹងដល់ភាគីដទៃទៀត នឹងមេធាវីដើម្បីឆ្លើយតបនឹងសារណារបស់អ្នកប្តឹងសាទុក្ខក្នុងរយៈពេល ២០(ម្ភៃ)ថ្ងៃភាគីដទៃទៀតអាចដាក់ពាក្យសុំពន្យារពេលនៃការដាក់សារណា។ ការ

[109] មាត្រា ៤១៩នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[110] មាត្រា ៤៣៦នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ពន្យារពេលនេះមិនអាចលើសពី ១០(ដប់)ថ្ងៃទេ។ លុះត្រាតែផុតរយៈពេលកំណត់ដើម្បីជូនសារណាប្រធានតុលាការកំពូលចាត់តាំងចៅក្រមរបាយការណ៍ នឹងបញ្ជូនសំណុំរឿងទៅចៅក្រមនេះ។ ចៅក្រមរបាយការណ៍ត្រូវសរសេររបាយការណ៍ហើយបញ្ជូនទៅក្នុងសំណុំរឿង។ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានកំណត់រយៈពេលជាក់លាក់នៃការធ្វើរបាយការណ៍ទេ។ ក្រោយពីបានសរសេររបាយការណ៍រួចសំណុំរឿងដោយមានសារណានិងរបាយការណ៍ត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីធ្វើសេចក្តីសន្និដ្ឋានជាលាយល័ក្ខណ៍អក្សរ។ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានកំណត់រយៈពេលនៃការធ្វើសេចក្តីសន្និដ្ឋានជាលាយល័ក្ខណ៍អក្សរដោយអគ្គព្រះរាជអាជ្ញាឡើយ។ បន្ទាប់មកសំណុំរឿងនឹងត្រូវបញ្ជូនត្រឡប់មកប្រធានសភាព្រហ្មទណ្ឌវិញ។ ប្រធានសភាព្រហ្មទណ្ឌកំណត់កាលបរិច្ឆេទនៃសវនាការ។ ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់អំពីរយៈពេលគម្លាតរវាងការទទួលសំណុំរឿងត្រឡប់មកពីអគ្គព្រះរាជអាជ្ញាវិញ នឹងការកំណត់កាលបរិច្ឆេទនៃសវនាការឡើយ។ ប្រធានសភាព្រហ្មទណ្ឌជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញា អំពីកាលបរិច្ឆេទនៃសវនាការ។ អគ្គព្រះរាជអាជ្ញា អោយដំណឹងពីកាលបរិច្ឆេទនៃសវនាការដល់ភាគី នឹងមេធាវី (កោះហៅភាគី នឹងមេធាវី)។ គួរសម្គាល់ថាក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អោយតុលាការកំពូលត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៦(ប្រាំមួយ)ខែគិតពីពេលទទួលសំណុំរឿងលើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន។

### ៣.៣.៣.២. នីតិវិធីនាពេលសវនាការ

ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់ពីសមាសភាពជំនុំជម្រះនាពេលសវនាការក្តី នឹងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា សមាសភាពជំនុំជម្រះក្តីរបស់តុលាការកំពូលមានចៅក្រម ៥(ប្រាំ)នាក់ដែលម្នាក់ធ្វើជាប្រធាន។ សមាសភាពនេះ ត្រូវបំពេញដោយអគ្គព្រះរាជអាជ្ញាឬអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលម្នាក់ នឹងក្រឡាបញ្ជីម្នាក់។ ការពិភាក្សាដេញដោលត្រូវប្រព្រឹត្តនៅពេលសវនាការជាសាធារណៈ។ ខុសប្លែកពីនីតិវិធីតុលាការជាន់ដំបូង នឹងនៅសាលាឧទ្ធរណ៍នាពេលសវនាការនៅតុលាការកំពូលភាគីមិនត្រូវបានសភាព្រហ្មទណ្ឌនៃតុលាការកំពូលស្តាប់ចម្លើយទេ លើកលែងក្នុងករណីដែលប្រធានសភាព្រហ្មទណ្ឌបង្គាប់អោយចូលមកបង្ហាញខ្លួន។ ចៅក្រមរបាយការណ៍ធ្វើសេចក្តីរាយការណ៍ អគ្គព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំមេធាវីធ្វើសេចក្តីសន្និដ្ឋានការពារ។

### ៣.៣.៣.៣. ការប្រកាសសាលដីកា

សេចក្តីសម្រេចរបស់សភាព្រហ្មទណ្ឌនៃតុលាការកំពូលអាចជា៖

- សាលដីកាបដិសេធបណ្តឹងសាទុក្ខទាំងស្រុង ឬមួយផ្នែក។ ក្នុងករណីនេះ សាលដីកាដែលតវ៉ាមានអាជ្ញាអស់ជំនុំ។ អ្នកប្តឹងសាទុក្ខមិនអនុញ្ញាតអោយប្តឹងសាទុក្ខជាថ្មីម្តងទៀតអំពីសាលដីកាដដែលនោះទេ។

- សាលដីកាបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ទាំងស្រុង ឬមួយផ្នែក។ ក្នុងករណីនេះ តុលាការកំពូលបញ្ជូនរឿង និងគូភាគីទៅសាលាឧទ្ធរណ៍មួយផ្សេងទៀត ឬសាលាឧទ្ធរណ៍ដដែល ប៉ុន្តែមានសមាសភាពថ្មីផ្សេងពីសមាសភាពមុន។
- សាលដីកាបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ដោយមិនបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍វិញ ប្រសិនបើអំពើដែលចោទប្រកាន់ មិនមែនជាបទល្មើសទេ។

#### ៣.៣.៣.៤. ការជំនុំជម្រះពេញអង្គ

ក្នុងករណីដែលសភាព្រហ្មទណ្ឌនៃតុលាការកំពូលបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ហើយបង្វិលសំណុំរឿងនឹងគូភាគីទៅសាលាឧទ្ធរណ៍វិញនោះ សាលាឧទ្ធរណ៍នឹងសម្រេចទៅតាមខ្លឹមសារនៃសាលដីការបស់តុលាការកំពូល។ សាលាឧទ្ធរណ៍ដែលទទួលជំនុំជម្រះលើសំណុំរឿងតាមការបង្វិលសំណុំរឿងពីតុលាការកំពូល នឹងសម្រេចសេចក្តីដោយចេញសាលដីកាថ្មីមួយទៀត។ សាលដីកាថ្មីនេះអាចជាកម្មវត្ថុនៃបណ្តឹងសាទុក្ខជាថ្មីទៀតបាន។ ក្នុងករណីនេះ តុលាការកំពូលជំនុំជម្រះជាសភាពេញអង្គដោយសម្រេចសេចក្តីលើអង្គហេតុនឹងអង្គច្បាប់ កាលបើអ្នកប្តឹងសាទុក្ខលើកទី២ លើកយកមធ្យោបាយដដែលមកសំអាងដោយសាលាឧទ្ធរណ៍មិនអនុលោមតាមសាលដីកាទី១ របស់តុលាការកំពូល។ ក្រោយពីការជំនុំជម្រះជាសភាពេញអង្គ តុលាការកំពូលចេញសាលដីកាស្ថាពរមួយ។ នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី២នេះ ក៏មិនខុសប្លែកពីនីតិវិធីនៃការជម្រះលើបណ្តឹងសាទុក្ខលើកទី១ប៉ុន្មានដែរ លើកលែងតែសមាសភាពជំនុំជម្រះដែលត្រូវមានចៅក្រមចំនួន ៩(ប្រាំបួន)នាក់។

### ៣.៤. ការធ្វើបណ្តឹងសើរើ

បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម នឹងសាលដីកាដែលស្ថាពរហើយដែលមានអាជ្ញាអស់ជំនុំ។

#### ៣.៤.១. ទម្រង់នៃបណ្តឹងសើរើ

ពាក្យបណ្តឹងសើរើ ត្រូវចុះបញ្ជីដោយក្រឡាបញ្ជីនៃតុលាការកំពូល។ បុគ្គលដែលអាចប្តឹងសើរើរឿងក្តីបានមាន៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ទណ្ឌិត ឬអ្នកតំណាងស្របច្បាប់ ប្រសិនបើទណ្ឌិតនេះជាអសមត្ថជន
- សហព័ទ្ធ ឪពុកម្តាយ កូន នឹងជាទូទៅជនណាដែលមានប្រយោជន៍ខាងសម្ភារៈ ឬខាងផ្លូវចិត្តក្នុងការលុបបំបាត់ទណ្ឌកម្មនេះ ក្នុងករណីដែលទណ្ឌិតបានទទួលមរណភាព ឬបាត់ខ្លួន។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់ពីរយៈពេលនៃការប្តឹងសើរើឡើយ។

### ៣.៤.២. មូលហេតុនៃការធ្វើបណ្តឹងសើរើ

ការប្តឹងសើរើ គឺជាផ្លូវតវ៉ាពិសេសមួយ។ ហេតុនេះបណ្តឹងសើរើអាចអនុញ្ញាតបានតែក្នុងករណីដែលបានចែងដោយច្បាប់ប៉ុណ្ណោះ។ ករណីនៃបណ្តឹងសើរើរឿងក្តីដូចតទៅ៖

- កាលណាក្រោយពីការផ្តន្ទាទោសពីបទមនុស្សឃាត មានលេចជាតម្រុយយ៉ាងគ្រប់គ្រាន់ដែលអនុញ្ញាតអោយគិតថាជនរងគ្រោះនៅរស់រានមានជីវិតនៅឡើយ។
- កាលណាជនជាប់ចោទពីរនាក់ត្រូវផ្តន្ទាទោស ចំពោះបទល្មើសដដែលនេះ ដោយការផ្តន្ទាទោសទាំងពីរនេះមិនចុះសម្រុងគ្នាទេ។
- កាលណាសាក្សីណាមួយត្រូវបានផ្តន្ទាទោសពីបទល្មើស ធ្វើសាក្សីក្លែងក្លាយប្រឆាំងនឹងជនជាប់ចោទ
- កាលណាអង្គហេតុថ្មី ឬលិខិត ឬភស្តុតាងថ្មី ដែលនាំអោយគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត។

### ៣.៤.៣. នីតិវិធីបណ្តឹងសើរើ

ក្រឡាបញ្ជីត្រូវផ្តល់ដំណឹងអោយដល់ដើមបណ្តឹងថាខ្លួនមានរយះពេល ៣០(សាមសិប)ថ្ងៃដើម្បីបំពេញពាក្យបណ្តឹងរបស់ខ្លួន។ ប៉ុន្តែដល់ផុតរយះពេលនេះប្រធានតុលាការកំពូលចាត់តាំងចៅក្រមរបាយការណ៍ម្នាក់បន្ទាប់មកសំណុំរឿងត្រូវបានបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដើម្បីធ្វើដីកាសន្និដ្ឋានជាលាយល័ក្ខណ៍អក្សរក្នុងរយះពេល ៣០(សាមសិប)ថ្ងៃ ហើយសភាព្រហ្មទណ្ឌជាអ្នកសម្រេចថាបណ្តឹងសើរើអាចទទួលយកបានឬអត់។ ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងថាសេចក្តីសម្រេចរបស់សភាព្រហ្មទណ្ឌនេះត្រូវធ្វើតាមទម្រង់យ៉ាងណានោះទេ។ ក្នុងការអនុវត្តជាក់ស្តែងសេចក្តីសម្រេចនេះធ្វើឡើងតាមដីកាសម្រេច។ ទន្ទឹមនឹងនេះដែរសភាព្រហ្មទណ្ឌនៃតុលាការកំពូលអាចសម្រេចព្យួរការអនុវត្តទោសបានប្រសិនបើមានមូលហេតុច្បាស់លាស់។ ប្រសិនបើសភាព្រហ្មទណ្ឌសម្រេចថាបណ្តឹងសើរើអាចទទួលយកបាននោះ សភាព្រហ្មទណ្ឌត្រូវបញ្ជូនសំណុំរឿងនៃបណ្តឹងសើរើទៅតុលាការកំពូលដើម្បីជំនុំជម្រះជាសភាពេញអង្គ នឹងសម្រេចលើអង្គហេតុ និងអង្គច្បាប់ដោយសាលដីកាស្ថាពរ។ តុលាការកំពូលជំនុំជម្រះជាសភាពេញអង្គអាចបង្គាប់អោយផ្អាកការអនុវត្តទណ្ឌកម្មបានគ្រប់ពេលវេលាតាមរយះសាលដីកាដែលមានសំអាងហេតុ។ ប្រធានតុលាការកំពូលកំណត់កាលបរិច្ឆេទនៃសវនាការ នឹងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនេះ។ អគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាដល់អ្នកប្តឹងសើរើ នឹងមេធាវី។ ប្រសិនបើរដ្ឋមន្រ្តីក្រសួងយុត្តិធម៌ជាអ្នកប្តឹងសើរើ អគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការទៅដល់ទណ្ឌិត ឬដល់គ្រួសារ។ ចំពោះក្នុងពេលសវនាការសាធារណៈ តុលាការស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍ មេធាវីរបស់អ្នកប្តឹងសើរើ ស្តាប់ចម្លើយរបស់ទណ្ឌិត បើយល់ឃើញថាមានប្រយោជន៍ នឹងស្តាប់សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញា។ ហើយ

ចំពោះសេចក្តីសម្រេចរបស់តុលាការកំពូលអាចជាសាលដីកាបង្គាប់អោយធ្វើការស្រាវជ្រាវបន្ថែម សាលដីកាសម្រេចអំពីបណ្តឹងសើរើដែលមិនអាចតវ៉ាបានទៀតឡើយ[111]។

[111] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក អៀង សំណាងឆ្នាំ២០១៩

# សេចក្តីសន្និដ្ឋាន

ជាការពិតក្នុងពិភពលោកមួយនេះ រាល់ការចាប់ផ្តើមទាំងឡាយណា តែងតែមាននៅសេចក្តីបញ្ចប់ដែលជាច្បាប់ធម្មជាតិបានតម្រូវ ហើយក៏បានបង្ហាញពីការពិតជាក់ស្តែងមួយផងដែរ ក្នុងការដែលចាប់ផ្តើមសរសេរគាត់តែងសារណា ក៏មាននៅការធ្វើសេចក្តីសន្និដ្ឋានសរុបបញ្ចប់នូវរាល់ខ្លឹមសារនៃប្រធានបទទាំងមូលដូចគ្នាផងដែរ។ សេចក្តីសន្និដ្ឋានបញ្ចប់ខ្លឹមសារមួយនេះ គឺជាការសរុបនូវលទ្ធផលចុងក្រោយនៃការស្រាវជ្រាវមួយនេះ កត្តាជំរុញដែលអាចធ្វើឡើងបានបែបនេះ ក៏អាស្រ័យទៅលើការខិតខំរិះរកស្រាវជ្រាវ តាមមធ្យោបាយវិធីសាស្ត្រជាច្រើន ទើបអាចប្រមូលផ្តុំចងក្រងជាសារណាមួយនេះ លេចជារូបរាងឡើងមកបាន ហើយក៏ជាការសរុបបង្ហាញអោយឃើញនូវលទ្ធផលមួយ ដែលបញ្ជាក់អំពីការខិតខំប្រឹងប្រែងស្រាវជ្រាវ បំពេញនូវការងារមួយនេះ ដែលជាកាតព្វកិច្ចចាំបាច់ ដែលតម្រូវក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះផងដែរ។ ហើយជាការពិតជាក់ស្តែងមួយ ក្រោយពីឆ្លងកាត់នៅការសិក្សាស្រាវជ្រាវរួចមកក៏បានប្រមូលផ្តុំចងក្រងបាននូវប្រធានបទ "ដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌតុលាការកម្ពុជា" មួយនេះបានចំណាយអស់រយៈពេលជាច្រើនទើបអាចបង្កើតសារណាមួយនេះលេចចេញជារូបរាងបាន។ ហើយចំពោះប្រធានបទមួយនេះ ទៀតសោតយើងបានសង្កេតឃើញអំពីគោលការណ៍បែបបទនៃការអនុវត្តចំពោះដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ និងលំហូរនៃនីតិវិធីព្រហ្មទណ្ឌដែលយកមកអនុវត្តក្នុងដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌរបស់តុលាការកម្ពុជាយើងនេះ។

ជាការពិតណាស់ ចំពោះដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌបានបង្ហាញអោយយើងឃើញកាន់តែជាក់ច្បាស់អំពីលំហូរនៃនីតិវិធីព្រហ្មទណ្ឌក្នុងការដោះស្រាយវិវាទរឿងក្តីព្រហ្មទណ្ឌ ដែលបង្ហាញចាប់ផ្តើមតាំងពីដំណាក់កាលដំបូងឡើងមកតែម្តង គឺចាប់តាំងពីពេលដែលជនល្មើសបានប្រព្រឹត្តបទល្មើស រហូតឈានមកដល់ដៃសមត្ថកិច្ចជាអ្នកបន្តនីតិវិធី រហូតដល់ការសម្រេចសេចក្តីបញ្ចប់ប្រកាសនូវការផ្តន្ទាទោសដល់ជនជាប់ចោទនោះ។

ជាក់ស្តែងក្នុងសញ្ញាណនៃទិដ្ឋភាពទូទៅនៃបទល្មើសព្រហ្មទណ្ឌ យើងបានសង្កេតឃើញថាមានគោលការណ៍ជាច្រើនដែលយកអនុវត្តន៍ទៅលើជនល្មើសដូចជា គោលការណ៍នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ គោលការណ៍នៃការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ នឹងគោលការណ៍នៃការអនុវត្តទោសព្រហ្មទណ្ឌជាដើម ដែលគោលការណ៍ទាំងអស់នេះហើយ គឺជាមូលដ្ឋានគ្រឹះក្នុងការសម្រេចវិនិច្ឆ័យផ្តន្ទាទោសទៅលើជនល្មើស ហើយក៏ជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយផងដែរដើម្បីការពារដល់សិទ្ធិសេរីភាព សមភាព សេចក្តីថ្លៃថ្នូររបស់បុគ្គលគ្រប់រូបដែលជាជនល្មើសផងដែរ។ បន្ទាប់មក គឺជាដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកមានសមត្ថកិច្ចបន្តនូវនីតិវិធី ដោយមន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចស៊ើបអង្កេតបឋម និងស៊ើបអង្កេតជាក់ស្តែង។ សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌មានដូចជា ការឃាត់ខ្លួន ការឆែកឆេរ ការចាប់យកវត្ថុតាង ការ

ត្រួតពិនិត្យ ការបញ្ជូនកំណត់ហេតុវត្ថុតាង ការស្តាប់ចម្លើយ និងការសន្ទនាជាដើម។ បន្ទាប់មកទៀត លំហូរនៃនីតិវិធីចូលមកដល់ដំណាក់កាលព្រះរាជអាជ្ញា ដែលជាអ្នកមានសមត្ថកិច្ចសម្របសម្រួលដល់មន្ត្រីនគរបាលយុត្តិធម៌ និងជាអ្នកបន្តនូវនីតិវិធី។ ព្រះរាជអាជ្ញាមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតស្វែងរកនូវបទល្មើស ហើយមានសិទ្ធិសម្រេចធ្វើការចោទប្រកាន់ ឬមិនចោទប្រកាន់តម្កល់រឿងទុក្ខតតចាត់ការទៅលើបុគ្គលណាម្នាក់ដោយផ្អែកលើមូលដ្ឋានច្បាប់ច្បាស់លាស់ ហើយក៏មានសិទ្ធិចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ទៅចៅក្រមស៊ើបសួរ ឬមួយចេញនូវដីកាបញ្ជូនរឿងអោយទៅជំនុំជម្រះដោយផ្ទាល់ ទៅអោយចៅក្រមជំនុំជម្រះ ឬការធ្វើកំណត់នីតិវិធីបង្ហាញខ្លួនភ្លាម ទៅអោយចៅក្រមជំនុំជម្រះធ្វើការជំនុំជម្រះតែម្តងក៏បាន ដោយអាស្រ័យលើមូលដ្ឋានច្បាប់ជាក់លាក់ដែលបានកំណត់។ បន្ទាប់មកនេះ គឺជាដំណាក់កាលចៅក្រមស៊ើបសួរ ឬម្យ៉ាងទៀតហៅថា សភាស៊ើបសួរដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការស្វែងរកនូវភស្តុតាងដាក់បន្ទុក នឹងភស្តុតាងដោះបន្ទុក ដើម្បីធានាដល់សិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូររបស់បុគ្គលគ្រប់រូបដែលបានប្រព្រឹត្តអំពើល្មើស។ ចំពោះចៅក្រមស៊ើបសួរ ក៏មាននូវសិទ្ធិសម្រេចលើកលែងការចោទប្រកាន់របស់ព្រះរាជអាជ្ញាចំពោះជនល្មើសដែរ កាលណាប្រសិនបើចៅក្រមស៊ើបសួរស្វែងរកឃើញមាននូវភស្តុតាងដោះបន្ទុកផ្សេងៗ ដែលជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ក្នុងការធ្វើ ការច្រានចោលនូវការចោទប្រកាន់របស់ព្រះរាជអាជ្ញាចំពោះជនល្មើស។ ចំពោះចៅក្រមស៊ើបសួរក៏មាននូវឆន្ទានុសិទ្ធិសម្រេចមុនអង្គសេចក្តីផងដែរ ដូចជា ការចេញដីកាសម្រេចការឃុំខ្លួនបណ្តោះអាសន្ន ការចេញដីកាសម្រេចធានាអោយនូវក្រៅឃុំបណ្តោះ ជាដើម។ បន្ទាប់មកឈានចូលដល់ ចំណុចមួយទៀតដំណាក់កាលនៃការជំនុំជម្រះ ដែលជាសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ។ ចៅក្រមជំនុំជម្រះមានសមត្ថកិច្ច ធ្វើការជំនុំជម្រះសម្រេចសេចក្តីផ្តន្ទាទោសលើជនជាប់ចោទដែលជាឆន្ទានុសិទ្ធិរបស់ចៅក្រមជំនុំជម្រះ។ ប៉ុន្តែនៅក្នុងពេលសវនាការជំនុំជម្រះ ពិភាក្សាដេញដោលសេចក្តី កាលណាបើចៅក្រមជំនុំជម្រះយល់ឃើញថាមានវិមតិសង្ស័យ នោះនិងបានជាប្រយោជន៍ដល់ជនជាប់ចោទ ដោយសម្រេចលើកលែងបទចោទ ដោយគ្មានទោសដែលជាប្រយោជន៍ក្នុងការពារដល់សិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូររបស់បុគ្គលផងដែរ ដែលជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរក្នុងការសម្រេចសេចក្តី។ ជាចំណុចចុងក្រោយនៃលំហូរនីតិវិធីទោះបីតុលាការបានសេចក្តីសម្រេចប្រកាសផ្តន្ទាទោសដល់ជនជាប់ចោទក៏ដោយ ក៏ជនជាប់ចោទមានសិទ្ធិទាមទារបណ្តឹងតវ៉ា តាមផ្លូវបណ្តឹងបានផងដែរដូចជា ការធ្វើការប្តឹងតវ៉ាតាមរយៈបណ្តឹងទាស់ តាមរយៈបណ្តឹងឧទ្ធរណ៍ តាមរយៈបណ្តឹងសាទុក្ខ តាមរយៈបណ្តឹងសើរើជាដើម។ ដើម្បីជាផលប្រយោជន៍ដល់ជនជាប់ចោទ ក្នុងការទាមទារភាពត្រឹមត្រូវនៃច្បាប់តាមមនីតិវិធីនៃច្បាប់ ព្រោះជាការស្វែងរកភាពយុត្តិធម៌ដែលសាកសម និងចំពោះជនជាប់ចោទផ្ទាល់ខ្លួនតែម្តង។ សរុបជាចុងក្រោយនៃសេចក្តីបញ្ចប់ក្នុងប្រធានបទ "ដំណើរការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌតុលាការកម្ពុជា" យើងបានទទួលជាចំណេះដឹងជាច្រើន អំពីលំហូរនៃនីតិវិធីព្រហ្មទណ្ឌ

របស់តុលាការកម្ពុជាដូចជា គោលការណ៍នៃការអនុវត្តន៏តាមបែបបទនៃនីតិវិធី សិទ្ធិសេរីភាពមួយចំនួនរបស់ជនជាប់ចោទ តួនាទីភារៈកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ តួនាទីភារៈកិច្ចរបស់ព្រះរាជអាជ្ញា តួនាទីភារៈកិច្ចរបស់ចៅក្រមស៊ើបសួរ តួនាទីភារៈកិច្ចរបស់ចៅក្រមជំនុំជម្រះ និងជាពិសេសការទាមទារស្វែងរកភាពយុត្តិធម៌ត្រឹមត្រូវតាមផ្លូវច្បាប់ អោយសាកសមនិងទទួលយកបាននូវការសម្រេចសេចក្តីនោះ។

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវកន្លងមក យើងសង្កេតឃើញថា ក្នុងការអនុវត្តជាក់ស្តែងមានភាពអសកម្មមួយចំនួនដែលធ្វើអោយមានការរាំងស្ទះបង្ករជាភាពយឺតយ៉ាវ ដល់នីតិវិធីដែលបណ្តាលអោយមាន ការកកស្ទះនៃសំណុំរឿងក្តីព្រហ្មទណ្ឌជាច្រើន។ ការកកស្ទះនៃសំណុំរឿងក្តីព្រហ្មទណ្ឌនេះ បានជះឥទ្ធិពលយ៉ាងខ្លាំង ដល់សិទ្ធិសេរីភាពរបស់ជនជាប់ចោទមួយចំនួន ដោយសារតែការឃុំខ្លួនចេះតែបន្តអូសបន្លាយ លើសពីពេលវេលាដែលបានកំណត់ក្នុងនីតិវិធីព្រហ្មទណ្ឌ ហើយការយឺតយ៉ាវដែលបណ្តាលមកពីកត្តាជាច្រើនដូចជាការអូសបន្លាយនៃនីតិវិធីក្នុងពេលអនុវត្តដោយសារតែការខ្វះខាតនូវភស្តុតាង ការអូសបន្លាយនៃនីតិវិធីបណ្តឹងពីសាលាជម្រះក្តីជាន់ទាបសាលាដំបូងរាជធានី-ខេត្ត រហូតដល់សាលាជម្រះក្តីជាន់ខ្ពស់សាលាឧទ្ធរណ៍ តុលាការកំពូលជាដើម ដែលធ្វើអោយសំណុំរឿងមិនងាយចូលជាស្ថាពរ ដែលជាហេតុធ្វើអោយសាលាជម្រះក្តីនីមួយៗមានភាពមមាលញឹកការងារច្រើនមិនងាយបញ្ចប់សំណុំរឿងនីមួយៗនោះ។ ចំពោះចំនួនអគារសម្រាប់ធ្វើការរបស់សាលាជម្រះក្តីនីមួយៗវិញ គឺទាំងសាលាជម្រះក្តីសាលាដំបូងរាជធានី-ខេត្ត សាលាឧទ្ធរណ៍ តុលាការកំពូល មិនទាន់មានចំនួនអគារអោយសមស្របមានភាពសមាមាត្រ និងចំនួនសំណុំរឿងដែលត្រូវដោះស្រាយនូវឡើយ ដែលជាមូលហេតុនៃការយឺតយ៉ាវដល់នីតិវិធី និងការកកស្ទះនៃសំណុំរឿងក្តីដែលជាបញ្ហាប្រឈម នឹងការជះឥទ្ធិពលយ៉ាងខ្លាំងដល់សិទ្ធិសេរីភាពដល់ជាប់ចោទដែលស្ថិតនៅក្នុងការឃុំឃាំង។

យើងខ្ញុំសូមសំណូមពរ អោយរាជរដ្ឋាភិបាលជួយរៀបចំកំណែទម្រង់បន្ថែមរាល់ការខ្វះចន្លោះប្រហោងទាំងនេះ ដើម្បីពារការដល់សិទ្ធិសេរីភាពមួយចំនួនរបស់ប្រជាពលរដ្ឋដែលធ្លាប់រងគ្រោះក្នុងបញ្ហាទាំងនេះ។

# ឯកសារយោង

## ១. កម្រងឯកសារច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១១
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
- ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញាឆ្នាំ ២០១៤
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤
- ច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៤
- សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាលឆ្នាំ ២០០៩
- ច្បាប់ស្តីពីកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ២០០៩
- ច្បាប់ស្តីពីអំពីការប្រឆាំងអំពើពុករលួយ
- ច្បាប់ស្តីពីការប្រឆាំង និងភេរវកម្ម

## ២. កម្រងឯកសារមេរៀន

- សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត (បោះពុម្ពឆ្នាំ ២០១៥)
- មេរៀននីតិវិធីព្រហ្មទណ្ឌពិសេស រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ឆ្នាំ២០១៧
- មេរៀននីតិព្រហ្មទណ្ឌ រៀបរៀងដោយ លោកសាស្ត្រាចារ្យ ហ៊ី សោភា
- សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ អៀង សំណាង
- សៀវភៅនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោក ផេង គឹមស្រ៊ុន